ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥
# របស់ គ.ជ.អ.ប នៃផអ៣ទី២

ខែមីនា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥

# របស់ គ.ជ.អ.ប នៃផអ៣ទី២

ខែមីនា ឆ្នាំ២០១៥

# អារម្ភកថា

ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខែឧសភា ឆ្នាំ២០០៨) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ខែឧសភា ឆ្នាំ២០០៩) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ (ខែឧសភា ឆ្នាំ២០១៣) ការរៀបចំនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ខែមិថុនា ឆ្នាំ២០១០) ការអនុម័តនូវផែនការអនុវត្តដំណាក់កាលទីមួយ ២០១១-២០១៤ (ខែមិថុនា ឆ្នាំ២០១០) និងផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ ២០១៥-២០១៧ (ខែធ្នូ ឆ្នាំ២០១៤)នៃកម្មវិធីជាតិ បានបង្ហាញឱ្យឃើញនូវឆន្ទៈដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីកំណែទម្រង់ផ្នែកគោលនយោបាយ រដ្ឋបាល និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុងពេលនៃឆ្នាំ២០១៤កន្លងមកនេះ ការអនុវត្តផអ៣ទី១សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនគួរជាទីមោទនៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនការវិភាជថវិការដ្ឋឱ្យមូលនិធិក្រុង ស្រុកពី០,៨%ក្នុងឆ្នាំ២០១៥ទៅ០,៩%ក្នុងឆ្នាំ២០១៦ និងកើនដល់១%ក្នុងឆ្នាំ ២០១៧ និងបានបែងចែកដាច់ដោយឡែកពីគ្នានូវសមាសភាគថវិកាសម្រាប់ផ្នែករដ្ឋបាល និងសមាសភាគថវិកាសម្រាប់ផ្នែកអភិវឌ្ឍន៍ ព្រមទាំងបានធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីផ្តល់លទ្ធភាពក្នុងការផ្ទេរអធិរេកមូលនិធិក្រុង ស្រុកក្នុងឆ្នាំនីមួយៗទៅឆ្នាំបន្ទាប់។ ក្រសួងបរិស្ថានបានឯកភាពក្នុងការផ្ទេរមុខងារគ្រប់គ្រងកាកសំណល់រឹងទៅឱ្យក្រុងចំនួន២៦ តាមរយៈការវិនិយោគមូលនិធិចំនួន៥លានដុល្លារសម្រាប់អនុវត្តការងារនេះ។ ដោយមានជំនួយបច្ចេកទេសពីធនាគារពិភពលោក ផែនការសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំ ហើយសកម្មភាពនានានៃគណនេយ្យភាពសង្គមក្នុងដំណាក់កាលដំបូងត្រូវបានអនុវត្តក្នុងឃុំចំនួន៦៨នៃស្រុកចំនួន២២ ដោយមានការចូលរួមពីអង្គការ CARE, World Vision, PACT, Save the Children និង RACHA ។ ម្យ៉ាងទៀត គោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត ដែលមានគោលបំណងលើកកម្ពស់ស្វ័យភាពរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការកសាងផែនការ ការគ្រប់គ្រងធនធាននានា និងការសម្របសម្រួលការកសាងផែនការជាមួយថ្នាក់រដ្ឋបាលផ្សេងទៀត។ ដោយឡែក អនុក្រឹត្យនានាដែលកំណត់នូវមុខងារជាជម្រើស និងនីតិវិធីក្នុងការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ទោះបីមានភាពយឺតយ៉ាវជាងការគ្រោងទុកក៏ដោយ ប៉ុន្តែយើងមានវឌ្ឍនភាពក្នុងការធ្វើវិមជ្ឈការនូវការគ្រប់គ្រង ធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាពនានា។ លើសពីនេះទៀត សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំង២ថ្នាក់ក៏ត្រូវបានបង្កើត និងត្រូវបានទទួលស្គាល់ជាផ្លូវការជានីតិបុគ្គល ហើយសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក៏បានចុះបញ្ជី ជាផ្លូវការផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាល

រាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាល ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបាននូវធនធានកើនឡើងចំនួន២៣%ធៀបនឹងឆ្នាំ២០១៣។

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២(ផអ៣ទី២)នៃកម្មវិធីជាតិ ត្រូវបានរៀបចំឡើង ដោយមានការចូលរួមប្រឹក្សាយោបល់យ៉ាងសកម្មពីមន្ត្រីជាន់ខ្ពស់នានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។ ផអ៣ទី២ គឺជាឯកសារខ្លី និងងាយយល់ មានកំណត់អំពីអាទិភាពនិងលទ្ធផលរំពឹងទុកនានា មានរៀបរាប់អំពីវិធីសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍសមត្ថភាព និងបានបញ្ជ្រាបបញ្ហាបរិយាប័ន្ន និងសមធម៌សង្គមក្នុងគ្រប់ផ្នែកនៃឯកសារនេះ។ ដំណាក់កាលថ្មីនេះ នឹងផ្តល់នូវឱកាសមួយក្នុងការលើកកម្ពស់វិមជ្ឈការតាមរយៈការខិតខំរៀបចំឱ្យមានការជជែកពិភាក្សាជាប្រចាំរវាងអ្នកដឹកនាំនយោបាយជាន់ខ្ពស់នានា ។ តាមរយៈការពង្រឹងកិច្ចដំណើរការនៃការគ្រប់គ្រង និងការប្រាស្រ័យទាក់ទងនេះ យើងសង្ឃឹមថា នឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីឱ្យបានកាន់តែប្រសើរ និងប្រកបដោយតម្លាភាព។ ដូចបានធ្វើការគូសបញ្ជាក់នៅរៀងរាល់ព្រឹត្តិការណ៍សំខាន់ៗនៃកិច្ចដំណើរការរៀបចំផអ៣ទី២ គ.ជ.អ.ប បានចាត់ទុកការផ្ទេរមុខងារពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដែលមានអាទិភាពខ្ពស់បំផុតក្នុងដំណាក់កាលទី២នេះ អាស្រ័យហេតុនេះ ទាមទារឱ្យមានការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ននានា។ ជាមួយគ្នានេះដែរ ក្នុងអំឡុងពេលនៃផអ៣ទី២ រដ្ឋបាលថ្នាក់ក្រោមជាតិនានានឹងមានស្វ័យភាពកាន់តែច្រើនឡើងក្នុងការគ្រប់ គ្រងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរបស់ខ្លួនទទួលបានធនធានហិរញ្ញវត្ថុកាន់តែច្រើនឡើងសម្រាប់ឆ្លើយតបនឹងតម្រូវការក្នុងការផ្តល់សេវា និងកាន់តែមានតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សានានា ដែលត្រូវបានបោះឆ្នោតឱ្យធ្វើជាតំណាងប្រជាពលរដ្ឋនឹងកាន់តែមានសិទ្ធិអំណាច និងសមត្ថភាព ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។ ជារួម ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំលើកទី១នៃផអ៣ទី២ គឺជាឱកាសមួយ សម្រាប់ស្ថាប័នអនុវត្តទាំងអស់ក្នុងការជំរុញការងារកំណែទម្រង់ឱ្យបោះជំហានទៅមុខកាន់តែលឿន និងស៊ីជំរៅជាងមុន។

ពាក់ព័ន្ធនឹងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំលើកទី១នៃផអ៣ទី២នេះ គ.ជ.អ.ប សូមធ្វើការគូស បញ្ជាក់នូវចំណុចជាគន្លឹះមួយចំនួន ដែលមានសារៈសំខាន់សម្រាប់ភាពជោគជ័យនៃការអនុវត្តកំណែ ទម្រង់វិមជ្ឈការនៅកម្ពុជាដូចខាងក្រោម ៖

**<u>ទីមួយ</u>** ៖ មុខងារនានាត្រូវផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៥ យើងនឹងពិនិត្យមើលឡើងវិញយ៉ាងយកចិត្តទុកដាក់ទៅលើមុខងារពាក់ព័ន្ធនឹងការអប់រំកម្រិតបឋម ការថែទាំសុខភាពបឋម និងមុខងារសំខាន់ៗមួយចំនួនទៀតដែលត្រូវផ្ទេរ និងឈានទៅដល់ការផ្ទេរការិយាល័យជំនាញថ្នាក់ក្រុង ស្រុកមួយចំនួនដែលពុំមានធនធានគ្រប់គ្រាន់ឱ្យទៅរដ្ឋបាលក្រុង ស្រុក។ ជាមួយគ្នានេះដែរ ក្រសួងថ្មីចំនួន៥នឹងអនុវត្តកិច្ចដំណើរការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារជាគន្លឹះនានា របស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តក្នុងការផ្ទេរមុខងារទាំងនោះនាពេលអនាគត។

**ទីពីរ** ៖ យើងត្រូវរៀបចំបញ្ចប់នូវលិខិតបទដ្ឋាននានាសម្រាប់ការផ្ដល់សិទ្ធិអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងមន្ត្រី បុគ្គលិករបស់ខ្លួន និងការរៀបចំសេចក្ដីណែនាំ សៀវភៅណែនាំ និងនីតិវិធីនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ក្នុងការជ្រើសរើស ការតែងតាំង ការដាក់ពិន័យ និងការវាយតម្លៃអំពីការបំពេញតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិកទាំងនោះ។

**ទីបី** ៖ យើងចាំបាច់ត្រូវកែលម្អប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាថាប្រព័ន្ធកសាងផែនការនេះផ្ដោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការផ្ដល់សេវាសង្គម។

**ទីបួន** ៖ យើងត្រូវកំណត់ និងដោះស្រាយឱ្យបាននូវបញ្ហាប្រឈម និងភាពសាំញ៉ាំនៅក្នុងនីតិវិធីនៃការអនុវត្តថវិកាសម្រាប់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ក្នុងគោលបំណងពង្រឹងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបចំពោះអាទិភាពនានា ក្នុងអាណត្តិទូទៅរបស់ខ្លួន ក៏ដូចជាការធានាបាននូវគណនេយ្យភាពផ្នែកហិរញ្ញវត្ថុ។

**ទីប្រាំ** ៖ យើងត្រូវបន្តអនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់យើងនៅក្នុងស្មារតី ប្រកបដោយកិច្ចសហប្រតិបត្តិការ បើកចំហ និងមានការចូលរួមក្នុងន័យស្ថាបនាពីអ្នកពាក់ព័ន្ធនានា។ នៅក្នុងការអនុវត្តកិច្ចការនេះ ថ្នាក់ដឹកនាំនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវយកចិត្តទុកដាក់ស្ដាប់ប្រជាពលរដ្ឋ សិក្សាស្វែងយល់ពីកង្វល់និងយកចិត្តទុកដាក់នូវមតិយោបល់នានារបស់ពួកគាត់ ព្រមទាំងចាត់វិធានការជាក់លាក់ ដើម្បីធានាការផ្ដល់សេវារបស់ខ្លួនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥នេះ កំណត់នូវសកម្មភាពជាអាទិភាពចំនួន២០ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៥។ ភាពជោគជ័យក្នុងការអនុវត្តផែនការនេះអាស្រ័យលើកិច្ចខិតខំប្រឹងប្រែង ការប្រឹក្សាយោបល់ និងកិច្ចសហការប្រតិបត្តិការយ៉ាងសកម្មនៅក្នុងចំណោម និងជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតទាំងអស់។ ជាមួយគ្នានេះដែរ វាក៏អាស្រ័យលើសមត្ថភាពរបស់ថ្នាក់ដឹកនាំនានាក្នុងការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការតាមដាន និងការវាយតម្លៃ ទំនាក់ទំនង ការអភិវឌ្ឍគោលនយោបាយ និងកិច្ចដំណើរការកសាងផែនការនានា សម្រាប់កម្មវិធីរបស់យើងផងដែរ។ ជារួមរាល់កិច្ចខិតខំប្រឹងប្រែងត្រូវតែធានាថា កំណែទម្រង់ទាំងនេះនឹងផ្ដល់ផលប្រយោជន៍ពិតប្រាកដជូន ប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះនានា។

រាជធានីភ្នំពេញ ថ្ងៃទី......ខែ..........ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

# មាតិកា


អារម្ភកថា ........ i

មាតិកា ........ iv

បញ្ជីរូបភាព ........ vi

បញ្ជីតារាង ........ vi

បញ្ជីអក្សរកាត់ ........ vii

វាក្យសព្ទ និងនិយមន័យ ........ ix

សេចក្តីផ្តើម ........ ១

ក. អាទិភាពសំខាន់ៗក្នុងឆ្នាំ២០១៥ ........ ២

ខ. ថវិកានៃ ផ.ស.ថ ឆ្នាំ២០១៥ ........ ១១

ខ.១ ផែនការចំណាយ ........ ១១

ខ.២ ជំនួយបច្ចេកទេស ........ ១២

ខ.៣ ប្រភពមូលនិធិ ........ ១២

ជំពូកទី១ ÷ សមិទ្ធផលទី១ស្តីពីការគ្រប់គ្រងការងារកំណែទម្រង់ ........ ១៥

១.១. សេចក្តីផ្តើម និងចំណុចដៅ ........ ១៥

១.២. លទ្ធផលរំពឹងទុក ........ ១៦

១.៣. គម្រោងថវិកា ........ ១៨

ជំពូកទី២ ÷ សមិទ្ធផលទី២ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ........ ២០

២.១. សេចក្តីផ្តើម និងចំណុចដៅ ........ ២០

២.២. លទ្ធផលរំពឹង ........ ២១

២.៣. គម្រោងថវិកា ........ ២៤

ជំពូកទី៣ ÷ សមិទ្ធផលទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ........ ២៦

៣.១. សេចក្តីផ្តើម និងចំណុចដៅ ........ ២៦

៣.២. លទ្ធផលរំពឹងទុក ........ ២៧

៣.៣. គម្រោងថវិកា ........ ៣១

ជំពូកទី៤ ÷ សមិទ្ធផលទី៤ស្តីពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៣២

៤.១. សេចក្តីផ្តើម និងចំណុចដៅ ........ ៣២

៤.២. លទ្ធផលរំពឹងទុក ........ ៣៣

៤.៣. គម្រោងថវិកា ........ ៣៧


14

**ជំពូកទី៥ ៖ សមិទ្ធផលទី៥ស្តីពីវិមជ្ឈការហិរញ្ញវត្ថុ** ........ **៤០**
៥.១. សេចក្តីផ្តើម និងចំណុចដៅ ........ ៤០
៥.២. លទ្ធផលរំពឹងទុក ........ ៤១
៥.៣. គម្រោងថវិកា ........ ៤៦

**ឧបសម្ព័ន្ធ** ........ **៤៨**
ឧបសម្ព័ន្ធទី១ ៖ សុន្ទរកថាបិទរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប ........ ៤៩
ឧបសម្ព័ន្ធទី២ ៖ ជំនួយបច្ចេកទេស ផែនការបុគ្គលិក ........ ៥៦
ឧបសម្ព័ន្ធទី៣ ៖ ការទទួលខុសត្រូវក្នុងការអនុវត្ត ........ ៥៧
ឧបសម្ព័ន្ធទី៤ ៖ ក្របខ័ណ្ឌលទ្ធផល ចំណុចដៅ ........ ៦២

## បញ្ជីរូបភាព


រូបភាពទី១ ៖ និន្នាការស្តីពីមូលនិធិកញ្ចប់រួម (តាមប្រភពមូលនិធិ).................................១៣
រូបភាពទី២ ៖ និន្នាការស្តីពីថវិកានៃជំនួយបច្ចេកទេស.................................................១៣


## បញ្ជីតារាង


តារាងទី១ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៥......................................................១១
តារាងទី២ ៖ ទិន្នន័យនៃការផ្ទេរថវិការបស់រដ្ឋ............................................................១៣
តារាងទី៣ ៖ ព័ត៌មានលម្អិតអំពីមូលនិធិតាមប្រភព.....................................................១៤
តារាងទី៤ ៖ ចំណុចដៅរបស់សមិទ្ធផលទី១..............................................................១៥
តារាងទី៥ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី១...................................១៩
តារាងទី៦ ៖ ចំណុចដៅរបស់សមិទ្ធផលទី២..............................................................២០
តារាងទី៧ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី២...................................២៥
តារាងទី៨ ៖ ៖ ចំណុចដៅរបស់សមិទ្ធផលទី៣..........................................................២៦
តារាងទី៩ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី៣...................................៣១
តារាងទី១០ ៖ ចំណុចដៅរបស់សមិទ្ធផលទី៤...........................................................៣២
តារាងទី១១ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី៤................................៣៨
តារាងទី១២ ៖ ចំណុចដៅរបស់សមិទ្ធផលទី៥...........................................................៤០
តារាងទី១៣ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី៥................................៤៦
តារាងទី១៤ ៖ ផែនការបុគ្គលិកនៃផអ៣ទី២តាមថ្នាក់រដ្ឋបាល និងថវិកា ..........................៥៦
តារាងទី១៥ ៖ ការទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ.........................៥៧
តារាងទី១៦ ៖ ក្របខ័ណ្ឌលទ្ធផល និងសូចនាករ.........................................................៦២

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ទី១ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី១ (២០១១-២០១៤) នៃកម្មវិធីជាតិ |
| ផអ៣ទី២ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិ |
| ផ.ស.ថ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| Basket | មូលនិធិកញ្ចប់រួមគាំទ្រដោយ Sida, SDC និង EU |
| In-kind | ការចូលរួមបដិភាគមិនមែនជាថវិកាដូចជា ការផ្តល់ជំនួយបច្ចេកទេសជាដើម |
| I4C | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| JAAP | ផែនការសកម្មភាពរួមគ្នាអំពីការងារគណនេយ្យភាពសង្គម |
| IEC | ព័ត៌មាន ការអបរំ និងទំនាក់ទំនង |
| PE | ការប៉ាន់ស្មានកម្មវិធី គាំទ្រដោយសហគមន៍អឺរ៉ុប |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| Sida (ស៊ីដា) | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| EU-SPACE | កម្មវិធីគាំទ្រដោយសហគមន៍អឺរ៉ុបដើម្បីគាំទ្រការចូលរួមរបស់សង្គមស៊ីវិល |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB-PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំគម្រោង គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB-DPFSM | កម្មវិធីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB-TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB-RWS O&M | គម្រោងប្រតិបត្តិ និងថែទាំការផ្គត់ផ្គង់ទឹកជនបទគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| SDC | ទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការរបស់ប្រទេសស្វីស |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| UNCDF | មូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNCDF-LDDPHS | គម្រោងកិច្ចអភិវឌ្ឍមូលដ្ឋានតាមរយៈសេវាសុខភាពសាធារណៈបែបវិមជ្ឈការ |
| UNCDF-LGCCII | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រដោយមូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNICEF-Seth Koma | កម្មវិធីសិទ្ធិកុមារនៃមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| UN-Women | គម្រោងលើកកម្ពស់សិទ្ធិស្ត្រី និងអនុសញ្ញា ស៊ី-ដ គាំទ្រដោយយូអិន |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNDP-EU/ACES | គម្រោងលើកកម្ពស់សេវារបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រដោយយូអិនឌីភី និងសហគមន៍អឺរ៉ុប |
| UNDP/SNC Scale-up | គម្រោងបញ្ជ្រាបយុទ្ធសាស្ត្រការបំរែបំរួលអាកាសធាតុក្នុងដំណើរការកសាងផែនការ និងថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គាំទ្រដោយយូអិនឌីភី |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |
| WB-CTPP | គម្រោងសាកល្បងផ្ទេរសាច់ប្រាក់សម្រាប់លើកកម្ពស់អាហារូបត្ថម្ភ និងសុខភាពមាតា និងកុមារ គាំទ្រដោយធនាគារពិភពលោក |
| WB- RSDSD TA | គម្រោងគាំទ្រជំនួយក្នុងការផ្តល់សេវាអនាម័យជនបទតាមបែបវិមជ្ឈការ គាំទ្រដោយធនាគារពិភពលោក |
| WB-LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គាំទ្រដោយធនាគារពិភពលោក |
| SNIF (ស្នីហ្វ) | យន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| MEL | ការត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សារៀនសូត្រ |

# វាក្យស័ព្ទ និងនិយមន័យសំខាន់ៗ

**គណនេយ្យភាព** — កាតព្វកិច្ចនៃអ្នកអនុវត្តសិទ្ធិអំណាចក្នុងការឆ្លើយបំភ្លឺអំពីសកម្មភាពនានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលអាចដាក់នូវការពិន័យទោសក្នុងករណីខកខានមិនបានអនុវត្ត។

**ការគ្រប់គ្រងផ្អែកលើលទ្ធផល** — វិធីសាស្ត្រវិលជុំសម្រាប់ការគ្រប់គ្រងដែលធ្វើសមាហរណកម្មនៃយុទ្ធសាស្ត្រ មនុស្ស ធនធាន កិច្ចដំណើរការ និងវិធានការនានា ដើម្បីលើកកម្ពស់ការសម្រេចចិត្ត តម្លាភាព និងគណនេយ្យភាព។ វិធីសាស្ត្រនេះផ្តោតលើការសម្រេចបាននូវសមិទ្ធផល ការអនុវត្តនូវការវាស់វែងនៃការអនុវត្តការងារ ការសិក្សារៀនសូត្រ និងការសម្របសម្រួល ក៏ដូចជាការរៀបចំរបាយការណ៍យ៉ាងច្បាស់លាស់។

**តម្លាភាព** — ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ហើយព័ត៌មាននេះអាចទទួលបានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់។

**ការអភិវឌ្ឍសមត្ថភាព** — ជាដំណើរការមួយដែលនាំមកនូវការលើកកម្ពស់ជំនាញ (ទាំងជំនាញទូទៅ និងជំនាញជាក់លាក់) ដែលធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងការពង្រឹងស្ថាប័ន។ ការកសាងសមត្ថភាពសំដៅលើការវិនិយោគលើមនុស្ស ស្ថាប័ន និងបែបផែននៃការអនុវត្តនានា។

**ការចូលរួមរបស់សង្គមស៊ីវិល** — ជាដំណើរការនៅក្នុងសហគមន៍ដែលប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបង្កើតឡើងដើម្បីសម្រេចគោលដៅរួមនានារបស់ខ្លួននៅមូលដ្ឋាន និងធ្វើការងារជាបុគ្គល ឬរួមគ្នាតាមរយៈអង្គការសហគមន៍មិនមែនរដ្ឋាភិបាលដើម្បីមានឥទ្ធិពលទៅលើដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

**អង្គការសហគមន៍ ឬអង្គការសង្គមស៊ីវិល** — ជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញដែលមានវត្តមានក្នុងសង្គមដែលតំណាងឱ្យផលប្រយោជន៍ និងគុណតម្លៃរបស់សមាជិកខ្លួន ឬអ្នកដទៃ ដោយផ្អែកលើការយកចិត្តទុកដាក់នានាដែលមានលក្ខណៈជាក្រមសីលធម៌ វប្បធម៌ នយោបាយ វិទ្យាសាស្ត្រ សាសនា ឬសប្បុរសធម៌។

**ការវាយតម្លៃ** — ជាការវិនិច្ឆ័យទៅលើគុណតម្លៃ ផលប្រយោជន៍ និងតម្លៃនៃការងារអ្វីមួយ ជាការសិក្សាវាយតម្លៃអំពីភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព ផលប៉ះពាល់ និរន្តរភាព និងភាពពាក់ព័ន្ធនៃគម្រោងមួយ ស្របតាមគោលបំណងនានាដែលបានកំណត់។

**អភិបាលកិច្ច** — ជាប្រពៃណី និងការរៀបចំនូវស្ថាប័ននានាដែលអាជ្ញាធរនៃប្រទេសមួយបានប្រើប្រាស់។ ជាមធ្យោបាយនៃការអនុវត្តសិទ្ធិអំណាចដែលជះឥទ្ធិពលទៅលើជីវភាពសាធារណៈ ជាពិសេស ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។

**ផលប៉ះពាល់** — ការជះឥទ្ធិពលជាវិជ្ជមាន និងជាអវិជ្ជមានចំពោះមុខ និងយូរអង្វែង ដែលផ្តើមចេញពីកិច្ចអន្តរាគមន៍នៃការអភិវឌ្ឍមួយមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។

**សូចនាករ** កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់ជាមធ្យោបាយមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាដែលកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។

**ធាតុចូល** ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ ឯកសារ របាយការណ៍នានា ដែលបានប្រើប្រាស់សម្រាប់កិច្ចអន្តរាគមន៍ដល់ការអភិវឌ្ឍនានា។

**លទ្ធផលជាគន្លឹះ** ជាសកម្មភាពសំខាន់ ឬជាគន្លឹះដែលបានកំណត់ ឬដៅទុកសម្រាប់ការត្រួតពិនិត្យ ជាពិសេសពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការសម្រេចបាន។

**ការត្រួតពិនិត្យ** ជាការប្រមូល ការវិភាគ និងការប្រើប្រាស់មានលក្ខណៈជាប្រព័ន្ធ និងជាប្រចាំនូវព័ត៌មាននានាក្នុងគោលបំណងត្រួតពិនិត្យការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត។

**សមិទ្ធផល** ជាការផ្លាស់ប្តូរ ឬការធ្វើឱ្យប្រសើរឡើងដោយផ្ទាល់នូវសុខមាលភាពនៃអ្នកទទួលផល ឬអតិថិជន ដែលជាលទ្ធផលនៃការប្រើប្រាស់សេវាមួយ (ឬលទ្ធផលរំពឹងទុក)។

**លទ្ធផលរំពឹងទុក** ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានាផ្តើមចេញពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុកនានា។ ស្ថាប័ននានាត្រូវមានគណនេយ្យភាពក្នុងការសម្រេចលទ្ធផលរំពឹងទុកឱ្យបានទាន់ពេលវេលា មានគុណភាព និងបរិមាណសមស្រប។

**សកម្មភាព** ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជាមូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានគៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។

**គោលនយោបាយ (គោលនយោបាយសាធារណៈមួយ)** សកម្មភាព គោលការណ៍ ឬសំណុំនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានគោលបំណង និងភាពស៊ីសង្វាក់គ្នាមួយ ដើម្បី(១)រៀបចំឆ្លើយតបនឹងបញ្ហាមួយ (២)រៀបចំដោយដំណើរការនយោបាយជាក់លាក់ណាមួយ និង(៣)អនុម័ត អនុវត្ត និងពង្រឹងការអនុវត្តដោយស្ថាប័នសាធារណៈមួយ។

**កម្មវិធី** ជាអន្តរាគមន៍មួយដែលមានកំណត់ពេលវេលាជាក់លាក់ ដែលមានលក្ខណៈខុសគ្នាពីគម្រោង ពីព្រោះជាទូទៅ កម្មវិធី គឺមានលក្ខណៈអន្តរវិស័យ គ្របដណ្តប់លើប្រធានបទផ្សេងៗ និងឬមានតំបន់គោលដៅច្រើន ប្រើប្រាស់វិធីសាស្ត្រចំរុះ ពាក់ព័ន្ធនឹងស្ថាប័នច្រើនជាងស្ថាប័នអនុវត្តគម្រោង និងអាចគាំទ្រដោយប្រភពទុនផ្សេងៗ។

**បរិយាប័ន្ន** ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ គោលបំណងនៃបរិយាប័ន្ន គឺការផ្តល់នូវសិទ្ធិដល់ក្រុមផ្សេងគ្នាៗ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះឱ្យទទួលបាននូវឱកាសសមស្រប ព្រមទាំងធានាថាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់

ជីវភាពរស់នៅរបស់ពួកគេ ក៏ដូចជាដើម្បីធានាឱ្យពួកគេទទួលបាន និងប្រើប្រាស់ដោយស្មើភាពនូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្ត។

**សមធម៌សង្គម** ការលើកកម្ពស់សិទ្ធិក្នុងការទទួលបាន និងការប្រើប្រាស់ដោយយុត្តិធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្តសម្រាប់ការរស់នៅ និងការចូលរួមយ៉ាងពេញលេញក្នុងការងារនយោបាយ និងវប្បធម៌នៅក្នុងសង្គម ក៏ដូចជាសិទ្ធិក្នុងការកំណត់ដោយខ្លួនឯងដើម្បីសម្រេចបាននូវសេចក្តីត្រូវការជាមូលដ្ឋាននានារបស់ខ្លួន។ ក្នុងការងាររដ្ឋបាលសាធារណៈ សមធម៌សង្គមសំដៅលើការគ្រប់គ្រងស្ថាប័ននានាដែលបម្រើផលប្រយោជន៍សាធារណៈ ការផ្តល់សេវាសាធារណៈ និងការរៀបចំ និងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋាននានាប្រកបដោយយុត្តិធម៌ និងសមធម៌។

# សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២(ផអ៣ទី២)នៃកម្មវិធីជាតិ ត្រូវបានអនុម័តដោយ គ.ជ.អ.ប នៅខែធ្នូ ឆ្នាំ២០១៤។ ផែនការនេះត្រូវបានរៀបចំឡើងដោយផ្អែកលើភាពជោគជ័យនានានៃការអនុវត្ត ផអ៣ទី១ និងផ្តោតលើទិដ្ឋភាពសំខាន់ៗមួយចំនួនដូចជា ការផ្ទេរមុខងារពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិល ការលើកកម្ពស់ការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ការគ្រប់គ្រងកំណែទម្រង់ និងការអនុវត្តនូវវិធីសាស្រ្តថ្មីសម្រាប់ការអភិវឌ្ឍសមត្ថភាព។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ (ផ.ស.ថ) គឺជាកាលានុវត្តភាពដំបូងក្នុងការអនុវត្តនូវការផ្លាស់ប្តូរទាំងនេះ។

ផ.ស.ថ ឆ្នាំ២០១៥ បរិយាយអំពីសកម្មភាពជាអាទិភាព លទ្ធផលរំពឹងទុក[1] និងសកម្មភាពនានា ព្រមទាំងផែនការថវិកាសម្រាប់ការអនុវត្តកម្មវិធីជាតិក្នុងឆ្នាំទី៥ និងជាក្របខ័ណ្ឌមួយសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ។ ផ.ស.ថ ឆ្នាំ២០១៥ត្រូវបានរៀបចំឡើងចាប់ពីត្រីមាសទី៤ឆ្នាំ២០១៤រហូតដល់ដើមឆ្នាំ២០១៥ ដោយមានការចូលរួមប្រឹក្សាយោបល់ពីស្ថាប័នអនុវត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ សកម្មភាពជាអាទិភាព និងការវិភាជមូលនិធិនានាក៏បានយកមកបង្ហាញ និងពិភាក្សាក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ដែលបានរៀបចំឡើងកាលពីថ្ងៃទី០៤-០៥ ខែកុម្ភៈ ឆ្នាំ២០១៥កន្លងមកនេះដែលមានសិក្ខាកាមចូលរួមប្រមាណ៤០០នាក់ រួមមានថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្តទាំង២៥ និងក្រុង ស្រុក ខណ្ឌមួយចំនួន ប្រធាន គ.ក.ស.ក រាជធានី ខេត្ត នាយករដ្ឋបាលរាជធានី ខេត្ត ប្រធានមន្ទីរជំនាញនិងនាយកទីចាត់ការមួយចំនួននៃសាលារាជធានី ខេត្ត តំណាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការសង្គមស៊ីវិលមួយចំនួន ព្រមទាំងមន្ត្រី បុគ្គលិក និងទីប្រឹក្សានានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

បន្ទាប់ពី ផ.ស.ថ ឆ្នាំ២០១៥ ត្រូវបានអនុម័តដោយ គ.ជ.អ.ប រដ្ឋបាលរាជធានី ខេត្តទាំង២៥ តាមរយៈមណ្ឌល អភិវឌ្ឍន៍ធនធានមនុស្សរបស់ខ្លួននឹងរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពឆ្នាំ២០១៥ ដែលរួមបញ្ចូលគ្នានូវសកម្មភាពអភិវឌ្ឍន៍សមត្ថភាពផ្អែកផ្គត់ផ្គង់ដែលបានកំណត់ដោយថ្នាក់ជាតិ និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពផ្អែកតម្រូវការដែលបានរៀបចំដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស។ សកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាពផ្អែកតម្រូវការ ត្រូវរៀបចំឡើងផ្អែកតាមតម្រូវការនានានៃការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា មន្ត្រី និងបុគ្គលិកនានាដែលបានលើកឡើងក្នុងផែនការការអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួន និងផ្អែកតាមសមត្ថភាពនៃអ្នកផ្តល់សេវាបណ្តុះបណ្តាលដែលមានក្នុងរាជធានី ខេត្តនីមួយៗមានដូចជា មន្ត្រីរដ្ឋាភិបាល ទីប្រឹក្សា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

ឯកសារ ផ.ស.ថ ឆ្នាំ២០១៥ បែងចែកជា៥ជំពូកដែលបរិយាយអំពីលទ្ធផលរំពឹងទុកនានាតាម

[1] បញ្ជីលម្អិតនៃលទ្ធផលរំពឹងទុក និងសកម្មភាពនានាត្រូវបានរៀបចំ និងតាមដានក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការរៀបចំ ផ.ស.ថ (NAD) និងត្រូវបានឯកភាព និងចុះហត្ថលេខារវាង គ.ជ.អ.ប និងស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

សមិទ្ធផលនីមួយៗនៃផអ៣ទី២ដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៥។

នៅក្នុងសេចក្តីផ្តើមនៃឯកសារនេះមានរៀបរាប់សង្ខេបអំពីកិច្ចការជាចម្បងចំនួន២០ ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៥ គម្រោងថវិកាសម្រាប់ការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៥ និងធនធានសរុបដែលទទួលបានពីប្រភពផ្សេងៗ។

ក្រៅពីជំពូកទាំង៥ ឯកសារ ផ.ស.ថ ឆ្នាំ២០១៥ ក៏មានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន៤ ដើម្បីផ្តល់នូវព័ត៌មានជាក់លាក់បន្ថែមមួយចំនួនទៀត សម្រាប់ស្ថាប័នអនុវត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀត មានមូលដ្ឋានកាន់តែច្បាស់លាស់អំពីឯកសារនេះដូចជា ព័ត៌មានលម្អិតអំពីក្របខ័ណ្ឌលទ្ធផលនៃផអ៣ ទី២រួមទាំងចំណុចដៅនានា (ឧបសម្ព័ន្ធទី៤) និងសេចក្តីសង្ខេបអំពីការទទួលខុសត្រូវសម្រាប់ការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ (ឧបសម្ព័ន្ធទី៣)។ លទ្ធផលរំពឹងទុក និងសកម្មភាពទាំងអស់នៃ ផ.ស.ថ ឆ្នាំ២០១៥ត្រូវបានរៀបចំឡើងដោយផ្អែកជាមូលដ្ឋានលើចំណុចដៅក្នុងក្របខ័ណ្ឌលទ្ធផល លទ្ធភាពថវិកាដែលមាន និងសមត្ថភាពរបស់ស្ថាប័នអនុវត្តក្នុងការអនុវត្តលទ្ធផលរំពឹងទុក និងសកម្មភាពទាំងនោះ។

តារាងលម្អិតអំពីសកម្មភាព ថវិកា និងកាលវិភាគអនុវត្តសកម្មភាពនីមួយៗ នឹងត្រូវបានរៀបចំក្នុងប្រព័ន្ធទិន្នន័យសម្រាប់ការរៀបចំ ផ.ស.ថ (NAD) តាមប្រព័ន្ធអ៊ិនធឺណែត ហើយឯកសារនេះគឺជាផ្នែកមួយនៃសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប និងស្ថាប័នអនុវត្តទាំងអស់។

**គ. អាទិភាពសម្រាប់ឆ្នាំ២០១៥**

កិច្ចការចម្បងៗ ឬលទ្ធផលជាគន្លឹះចំនួន២០ដែលមានបរិយាយក្នុងឯកសារនេះត្រូវបានបង្ហាញ និងពិភាក្សាតាមក្រុមក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប ដែលបានរៀបចំឡើងកាលពីថ្ងៃទី០៤-០៥ ខែកុម្ភៈ ឆ្នាំ២០១៥។ នៅក្នុងសុន្ទរកថាបិទសិក្ខាសាលារបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ឯកឧត្តមបានគូសបញ្ជាក់ពីសារសំខាន់នៃការផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (តាមរយៈកិច្ចដំណើរការមួយដែលចូលរួម និងដឹកនាំផ្ទាល់ពីអ្នកនយោបាយ) ការបង្កើនធនធានហិរញ្ញវត្ថុនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងយន្តការត្រួតពិនិត្យនីត្យានុកូលភាពក្នុងការធានាការអនុវត្តតាមលិខិតបទដ្ឋាននានានិងផ្តល់ស្វ័យភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបាននូវមូលនិធិ និងអនុវត្តអាណត្តិនានារបស់ខ្លួន ការផ្តល់ស្វ័យភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងមន្ត្រី និងបុគ្គលិក ការរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់នីតិវិធីអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព (សុន្ទរកថាបិទសិក្ខាសាលាមានក្នុងឧបសម្ព័ន្ធទី១)។

កិច្ចការចម្បងៗ ឬលទ្ធផលជាគន្លឹះ[2] ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៥រួមមាន ៖

**សមិទ្ធផលទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់**

**១. ការពង្រឹងប្រសិទ្ធភាពនៃការរៀបចំកិច្ចប្រជុំនានារបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការ**

[2] លទ្ធផលជាគន្លឹះទាំងនេះនឹងត្រូវវាយកាណ៍លម្អិតក្នុងរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ។

នានារបស់ គ.ជ.អ.ប ដោយផ្តោតលើការបង្កើតចំណុចដៅផ្នែកគោលនយោបាយ និងការគ្រប់គ្រងការអនុវត្តការងារ (លទ្ធផលរំពឹងទុកទី១.១.១)

**ត្រីមាសទី១ ៖** ទម្រង់របាយការណ៍របស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ត្រូវបានពិនិត្យ និងកែសម្រួល

**ត្រីមាសទី២ ៖** ទម្រង់របាយការណ៍ស្តីពីការអនុវត្តការងារ សម្រាប់ដាក់ជូនកិច្ចប្រជុំរបស់ គ.ជ.អ.ប ត្រូវបានពិនិត្យ និងកែសម្រួល

**ត្រីមាសទី៤ ៖** ក្នុងចំណោមកិច្ចប្រជុំចំនួន៣របស់ គ.ជ.អ.ប យ៉ាងហោចណាស់មានកិច្ចប្រជុំចំនួន២លើកបានពិភាក្សាអំពីចំណុចដៅ និងលទ្ធផលជាគន្លឹះ និងយ៉ាងហោចណាស់មានកិច្ចប្រជុំចំនួន១លើកបានពិភាក្សាអំពីបរិយាប័ន្ន និងសមធម៌សង្គម

**ត្រីមាសទី៤ ៖** របាយការណ៍ចំនួន១ស្តីពីការរៀបចំគោលនយោបាយ និងការអនុវត្តការងារត្រូវបានរៀបចំដោយអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប នីមួយៗ

២. **ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនងដែលរួមបញ្ចូលនូវសារ/ ព័ត៌មានជាគន្លឹះដែលបានរៀបចំស្របតាមប្រភេទអ្នកពាក់ព័ន្ធនានា (ក្រសួង រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល) និងប្រើប្រាស់វិធីសាស្ត្រផ្សេងៗក្នុងការទំនាក់ទំនង (លទ្ធផលរំពឹងទុកទី១.៣.១)**

**ត្រីមាសទី១ ៖** សេចក្តីសង្ខេបអំពីយុទ្ធសាស្ត្រទំនាក់ទំនង និងអាទិភាពនានាត្រូវបានរៀបចំដែលផ្តល់នូវព័ត៌មាន និងកំណត់គោលដៅអំពីការផ្លាស់ប្តូរឥរិយាបទច្បាស់លាស់ដែលចង់បាន

**ត្រីមាសទី៤ ៖** យ៉ាងហោចណាស់មានព្រឹត្តិការណ៍សិក្សារៀនសូត្រចំនួន៣ ត្រូវបានរៀបចំ តាមវិធីសាស្ត្រទំនាក់ទំនងដែលមានការចូលរួម និងត្រូវបានសម្របសម្រួល បានល្អប្រសើរ ដើម្បីសិក្សារៀនសូត្រពីបទពិសោធន៍ជាក់ស្តែង និងដើម្បីកំណត់ ស្តាប់ ចាត់អាទិភាព និងដោះស្រាយនូវបញ្ហាប្រឈមនានាដែលថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានជួបប្រទះ

**ត្រីមាសទី៤ ៖** យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន១០០.០០០នាក់ត្រូវបានទំនាក់ទំនង តាមរយៈយុទ្ធនាការផ្សព្វផ្សាយផ្នែកសង្គម ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបទនានា

៣. **ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប រួមមានរចនាសម្ព័ន្ធ សមត្ថភាពនិងការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងផ្អែកលើលទ្ធផល ការគ្រប់គ្រងហិរញ្ញវត្ថុ ការកសាង ផ.ស.ថ និងការរៀបចំគោលនយោបាយ (លទ្ធផលរំពឹងទុកទី១.២.១)**

**ត្រីមាសទី២ ៖** សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាល និងសៀវភៅណែនាំស្តីពីនីតិវិធីហិរញ្ញវត្ថុ ត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យអនុវត្ត

**ត្រីមាសទី២ ៖** កិច្ចដំណើរការរៀបចំគោលនយោបាយត្រូវបានពិនិត្យ កែសម្រួល និងផ្សព្វផ្សាយជាសាធារណៈ

**ត្រីមាសទី២ ៖** រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ការបរិយាយអំពីតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិក និងទីប្រឹក្សា នីតិវិធីសម្រាប់រៀបចំកិច្ចប្រជុំ វិធីសាស្ត្រទំនាក់ទំនងនិងសមត្ថភាពត្រូវបានកែសម្រួល និងពង្រឹង

**ត្រីមាសទី៤ ៖** កិច្ចដំណើរការរៀបចំ ផ.ស.ថ ត្រូវបានពិនិត្យ និងកែសម្រួលឱ្យមានលក្ខណៈសាមញ្ញ មានលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធនានា ពិសេសថ្នាក់ដឹកនាំសំខាន់ៗ និងជាកិច្ចដំណើរការផ្អែកលើលទ្ធផល

**សមិទ្ធផលទី២ ៖ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

៤. **ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងស្រុកចំនួន២២ (លទ្ធផលរំពឹងទុកទី២.២.១)**

**ត្រីមាសទី១ ៖** ផែនការសកម្មភាពអំពីគណនេយ្យភាពសង្គមត្រូវបានអនុម័ត

**ត្រីមាសទី១ ៖** ការរៀបចំនានាផ្អែកអភិបាលកិច្ចត្រូវបានរៀបចំ និងអនុវត្ត

**ត្រីមាសទី២ ៖** សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិត្រូវការរៀបចំ និងអនុម័ត

**ត្រីមាសទី៤ ៖** ឃុំគោលដៅទាំងអស់អនុវត្តការលើកកម្ពស់ចំណេះដឹង និងយុទ្ធសាស្ត្រព័ត៌មាន ការអប់រំ និងទំនាក់ទំនង (IEC) ផ្តល់ព័ត៌មានដែលមានសារសំខាន់ជូនប្រជាពលរដ្ឋអំពីសិទ្ធិ ថវិកានិងការអនុវត្ត អនុវត្តប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋនិងតាមដានការអនុវត្ត រៀបចំកិច្ចប្រជុំនានាជាមួយប្រជាពលរដ្ឋ ព្រមទាំងរៀបចំនិងអនុវត្តផែនការសកម្មភាពរួមគ្នាអំពីគណនេយ្យភាពសង្គម (JAAP)

**ត្រីមាសទី៤ ៖** ទិន្នន័យដើមគ្រាត្រូវបានប្រមូល ដើម្បីបំពេញតម្រូវការនៃការវាយតម្លៃអំពីផលប៉ះពាល់នៃសកម្មភាពគណនេយ្យភាពសង្គម ដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបគ្នារវាងតំបន់មានអន្តរាគមន៍ និងតំបន់គ្មានអន្តរាគមន៍ និងផ្អែកលើសូចនាករនៃព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) និងការវាយតម្លៃអំពីប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ

**៥. វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកចំនួន៥០ ត្រូវបានអនុម័ត (លទ្ធផលរំពឹងទុកទី២.១.១)**

**ត្រីមាសទី២ ៖** សេចក្តីណែនាំ គំរូ និងលិខិតបទដ្ឋាននានា ព្រមទាំងឯកសារបណ្តុះបណ្តាលនៃវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំ និងអនុម័ត

**ត្រីមាសទី២ ៖** វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានសាកល្បង

**ត្រីមាសទី៤ ៖** វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានសម្របសម្រួលរៀបចំក្នុងក្រុង ស្រុកចំនួន៥០

**ត្រីមាសទី៤ ៖** រដ្ឋបាលក្រុង ស្រុកចំនួន៥០អនុម័តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន

**៦. យុទ្ធសាស្ត្រ នីតិវិធី សៀវភៅណែនាំ និងប្រព័ន្ធនៃការធ្វើអធិការកិច្ចត្រូវបានរៀបចំ និងអនុម័ត (លទ្ធផលរំពឹងទុកទី២.៣.១)**

**ត្រីមាសទី២ ៖** យុទ្ធសាស្ត្រនៃការធ្វើអធិការកិច្ច ត្រូវបានអនុម័តដោយថ្នាក់ដឹកនាំរបស់ក្រសួងមហាផ្ទៃរួមបញ្ចូលទាំងការរៀបចំនានាផ្នែកស្ថាប័ន ការបោះពុម្ពនិងផ្សព្វផ្សាយលទ្ធផល និងការចូលរួមរបស់វិស័យឯកជន

**ត្រីមាសទី៣ ៖** សៀវភៅណែនាំ ឧបករណ៍ និងសម្ភារៈនានាស្តីពីការធ្វើអធិការកិច្ចត្រូវបានរៀបចំ

**ត្រីមាសទី៤ ៖** ការធ្វើអធិការកិច្ចត្រូវបានសាកល្បង រៀបចំបញ្ចប់ និងអនុម័ត

**ត្រីមាសទី៤ ៖** ផែនការនៃការធ្វើអធិការកិច្ចឆ្នាំ២០១៦ត្រូវបានរៀបចំ និងមានធនធានគាំទ្រសម្រាប់ការអនុវត្ត

**៧. សមត្ថភាពរបស់សមាគមជាតិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋានរបស់ខ្លួនត្រូវបានពង្រឹងដើម្បីលើកកម្ពស់ការបំរើសមាជិករបស់ខ្លួន និងប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព (លទ្ធផលរំពឹងទុកទី២.១.១)**

**ត្រីមាសទី២ ៖** រចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានរបស់សមាគមជាតិក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត

**ត្រីមាសទី៣ ៖** យុទ្ធសាស្ត្រអំពីការផ្តល់សេវា និងការបង្កើនចំណូលសមាជិកភាពត្រូវបានអនុម័ត

**៨. សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្ត (លទ្ធផលរំពឹងទុកទី២.៤.១)**

**ត្រីមាសទី២ ៖** សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលត្រូវបានរៀបចំ និងសាកល្បង



Hv

**ត្រីមាសទី២ ៖** សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលត្រូវបានពិនិត្យ និងអនុម័ត

**ត្រីមាសទី៤ ៖** វគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាល ត្រូវបានអនុវត្តដោយមណ្ឌល អភិវឌ្ឍន៍ធនធានមនុស្ស

**៩. ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងព័ត៌មានតាមរយៈប្រព័ន្ធអ៊ិនធឺណែតនៅថ្នាក់ក្រុង ស្រុក (លទ្ធផលរំពឹងទុកទី២.៤.២)[3]**

**ត្រីមាសទី១ ៖** ប្រព័ន្ធគំរូមួយនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ក្រុង ស្រុក ត្រូវបានរៀបចំ និងធ្វើការសាកល្បង

**ត្រីមាសទី៣ ៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់ក្រុង ស្រុកទាំងអស់ត្រូវបានរៀបចំ

**ត្រីមាសទី៣ ៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់ក្រុង ស្រុកត្រូវបានសាកល្បង និងដាក់ឱ្យអនុវត្ត

**ត្រីមាសទី៤ ៖** យ៉ាងហោចណាស់ មានកិច្ចប្រជុំចំនួន១០០របស់ក្រុមប្រឹក្សាក្រុង ស្រុក បានប្រើប្រាស់ និងពិភាក្សានូវព័ត៌មានដែលបានប្រមូល តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលបានបង្កើត

## សមិទ្ធផលទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

**១០. ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករួមទាំងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៣.១.១)**

**ត្រីមាសទី២ ៖** លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័ត

**ត្រីមាសទី៤ ៖** លិខិតបទដ្ឋាន សេចក្តីណែនាំ និងសៀវភៅណែនាំនានាសម្រាប់ការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័ត

**ត្រីមាសទី៤ ៖** វគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធ និងកិច្ចដំណើរការនានានៃការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

**១១. ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីសម្រាប់ថ្នាក់ដឹកនាំនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី**

[3] ប្រព័ន្ធនេះនឹងត្រូវរៀបចំដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា បំពេញតម្រូវការរបស់ប្រើប្រាស់ និងប្រមូលនូវធាតុចូលនានាពីថ្នាក់ក្រុង ស្រុក ខណ្ឌសម្រាប់ជាព័ត៌មានរបស់ថ្នាក់ជាតិ។ ដូច្នេះ ប្រព័ន្ធគ្រប់គ្រងព័ត៌មាននេះនឹង ១). ត្រូវរៀបចំដោយមានការចូលរួមពីក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងគោលបំណងបំពេញតម្រូវការរបស់ក្រុង ស្រុក ខណ្ឌទាំងនោះ, ២). នឹងត្រូវបានប្រើប្រាស់សម្រាប់កិច្ចដំណើរការគ្រប់គ្រង, ៣). ធ្វើមែជ្ឈការការគ្រប់គ្រង និងការប្រមូលទិន្នន័យឱ្យថ្នាក់ក្រុង ស្រុក, ៤). មានភាពបត់បែនក្នុងការកំណត់ និងការកែសម្រួលសូចនាករនានា, ៥). នឹងផ្តល់នូវទិន្នន័យទាន់ពេលវេលា និងងាយយល់សម្រាប់ជាមូលដ្ឋានពិភាក្សាក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង៦). បង្កើនទិន្នន័យសម្រាប់សាធារណៈ និងអង្គការសង្គមស៊ីវិលនានា។

៣.១.៣) ៖ ថ្នាក់ដឹកនាំនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឱ្យឆ្លងកាត់វគ្គបណ្តុះបណ្តាលជាភាគពួកិច្ចមួយស្តីពីការវិភាគបញ្ហាយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងពិពិធកម្ម។ វគ្គនេះនឹងជួយឱ្យថ្នាក់ដឹកនាំនានាពង្រឹងការអនុវត្តជាក់ស្តែងនូវកិច្ចការនេះក្នុងការងារគ្រប់គ្រងប្រចាំថ្ងៃរបស់ខ្លួននៅថ្នាក់ក្រោមជាតិ និងដើម្បីលើកកម្ពស់ការឆ្លើយតប និងការពង្រឹងភាពអង់អាចដល់ស្ត្រី។

**ត្រីមាសទី២ ៖** កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំ

**ត្រីមាសទី៣ ៖** វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត ហើយថ្នាក់ដឹកនាំម្នាក់ៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានកំណត់ និងអនុវត្តសកម្មភាពជាអាទិភាពចំនួន១ ក្នុងការពង្រឹងការឆ្លើយតប និងពង្រឹងភាពអង់អាចដល់ស្ត្រី

**ត្រីមាសទី៤ ៖** ការអនុវត្តសកម្មភាពជាអាទិភាពត្រូវបានតាមដាន រៀបចំរបាយការណ៍ និងវាយតម្លៃ

**១២. ការបង្កើត និងកិច្ចដំណើរការរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងការពង្រឹងនូវការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការសម្រាប់ក្រុមប្រឹក្សា និងរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៣.៣.១)**

**ត្រីមាសទី១ ៖** សេចក្តីណែនាំស្តីពីការបង្កើត និងការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

**ត្រីមាសទី២ ៖** ការវាយតម្លៃអំពីតម្រូវការវគ្គ និងការអង្កេតអំពីអ្នកផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពក្នុងរាជធានី ខេត្តនីមួយៗត្រូវការអនុវត្ត និងបញ្ចូលក្នុងផែនការអភិវឌ្ឍសមត្ថភាពរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស

**ត្រីមាសទី៤ ៖** ការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស

**ត្រីមាសទី៤ ៖** គុណភាព និងការពេញចិត្តលើការអភិវឌ្ឍសមត្ថភាពដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានវាយតម្លៃ

**សមិទ្ធផលទី៤ ៖ *ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ***

**១៣. ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំនានាសម្រាប់ការអនុវត្តដំណាក់កាលដំបូងក្នុងឆ្នាំ២០១៦ ក្នុងវិស័យសុខាភិបាល អភិវឌ្ឍន៍ជនបទ ការអប់រំ កសិកម្ម និងបរិស្ថាន (លទ្ធផលរំពឹងទុកទី៤.២.១. និង៤.២.៣)**

**ត្រីមាសទី១ ៖** កិច្ចដំណើរការស្តីពីការផ្ទេរមុខងារត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីបង្រួញឱ្យខ្លី និងមានប្រសិទ្ធភាពជាងមុន

**ត្រីមាសទី២ ៖** សាកល្បងកិច្ចដំណើរការថ្មីដែលបានកែសម្រួលក្នុងក្រសួងចំនួន១

បន្ទាប់មកអនុវត្តជាមួយក្រសួងថ្មីចំនួន៤ផ្សេងទៀត

**ត្រីមាសទី៣ ៖** កិច្ចពិភាក្សាអន្តររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំជាមួយក្រសួងយ៉ាងតិចចំនួន៣ ដើម្បីផ្ទេរការិយាល័យជំនាញថ្នាក់ស្រុកមួយចំនួនទៅឱ្យរដ្ឋបាលក្រុង ស្រុក

**ត្រីមាសទី៣ ៖** ឯកសារគោលនយោបាយចំនួន៣អំពីវិមជ្ឈការត្រូវបានរៀបចំសម្រាប់រដ្ឋមន្ត្រី និងពិភាក្សាដែលរួមមានការអប់រំកម្រិតបឋមសិក្សា សុខភាព និងការងារមួយទៀតនឹងត្រូវកំណត់ជាក្រោយ

**ត្រីមាសទី៤ ៖** ការពិនិត្យមើលឡើងវិញនូវមុខងារត្រូវបានបន្តសម្រាប់ក្រសួងចំនួន៦ ដែលបានអនុវត្តក្នុងឆ្នាំ២០១៤

**ត្រីមាសទី៤ ៖** នៅចុងឆ្នាំ២០១៥ យ៉ាងហោចណាស់មានថវិកាចំនួន០,៥%នៃថវិការដ្ឋ ត្រូវបានផ្ទេរពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាលទ្ធផលនៃការផ្ទេរមុខងារ

**១៤. ការរៀបចំតាក់តែងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារអំពីការផ្តល់សេវាទីប្រជុំជនឱ្យទៅរដ្ឋបាលក្រុង (លទ្ធផលរំពឹងទុកទី៤.៣.១)**

**ត្រីមាសទី៣ ៖** ការវិភាគអំពីមុខងារនានាដែលគួរផ្ទេរពីរាជធានី ខេត្តឱ្យក្រុង ស្រុក ខណ្ឌត្រូវបានអនុវត្ត

**ត្រីមាសទី៤ ៖** ការធ្វើសេចក្តីសម្រេចអំពីមុខងារដែលត្រូវផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌ

**ត្រីមាសទី៤ ៖** សេចក្តីណែនាំ នីតិវិធី ផែនការ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាដែលចាំបាច់ក្នុងការអនុវត្តនូវការផ្ទេរមុខងារយ៉ាងហោចណាស់ចំនួន២ក្នុងឆ្នាំ២០១៥ ត្រូវបានរៀបចំ

**១៥. ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋាននានាស្តីពីមុខងារជាជម្រើស និងសេវាសង្គមរួមបញ្ចូលទាំងការរៀបចំភាពជាដៃគូជាមួយវិស័យឯកជន និងសង្គមស៊ីវិលក្នុងការផ្តល់សេវា (លទ្ធផលរំពឹងទុកទី៤.៥.១ និង៤.១.១)**

**ត្រីមាសទី៣ ៖** លិខិតបទដ្ឋាននានាសម្រាប់អនុវត្តមុខងារជាជម្រើសត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

**ត្រីមាសទី៣ ៖** កិច្ចប្រជុំនានាជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមវិស័យឯកជននានាត្រូវបានរៀបចំ ដើម្បីឯកភាពអំពីអនាគតនៃកិច្ចសហការក្នុងការអនុវត្តអាណត្តិទូទៅ

**ត្រីមាសទី៤ ៖** ការបណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិអំពីនីតិវិធីនានា

**ត្រីមាសទី៤ ៖** កិច្ចព្រមព្រៀងនៃភាពជាដៃគូក្នុងការផ្តល់សេវាត្រូវបានចុះហត្ថលេខា

ដោយឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌជាមួយនឹងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាដែលមានទឹកប្រាក់សរុបប្រមាណ៥០០.០០០ដុល្លារ

**សមិទ្ធផលទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ**

**១៦. ការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីលើកកម្ពស់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ពិសេសការផ្តល់សេវាសង្គម (លទ្ធផលរំពឹងទុកទី៥.៧.១)**

**ត្រីមាសទី២ ៖** ការសិក្សាអំពីបញ្ហាប្រឈមនៃការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ត្រូវបានអនុវត្តដោយផ្តោតការយកចិត្តទុកដាក់លើការផ្តល់សេវាសង្គម ហើយអនុសាសន៍នៃការសិក្សាត្រូវបានពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ត្រីមាសទី៣ ៖** សេចក្តីណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានកែសម្រួល

**ត្រីមាសទី៤ ៖** វគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធ និងនីតិវិធីដែលបានកែសម្រួលត្រូវបានរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

**១៧. ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ឱ្យបាន០,៥%នៃចំណូលក្នុងស្រុកសរុបនៃថវិការដ្ឋក្នុងឆ្នាំ២០១៦ (លទ្ធផលរំពឹងទុកទី៥.១.១)**

**ត្រីមាសទី៤ ៖** ការព្យាករណ៍អំពីធនធានរបស់រដ្ឋដែលមានសម្រាប់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៦

**ត្រីមាសទី៤ ៖** ការប្រឹក្សាយោបល់ជាមួយដៃគូអភិវឌ្ឍន៍នានាត្រូវបានរៀបចំ ដើម្បីកៀរគរធនធានសម្រាប់គាំទ្រមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ពីឆ្នាំ២០១៦-២០១៨ ឱ្យបាន០,៥%នៃចំណូលក្នុងស្រុកសរុបនៃថវិការដ្ឋស្របតាមចំណុចដៅដែលបានកំណត់

**១៨. ការរៀបចំ និងការសាកល្បងយន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់ល័ក្ខខ័ណ្ឌ (លទ្ធផលរំពឹងទុកទី៥.២.១)**

**ត្រីមាសទី២ ៖** លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងយន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានរៀបចំ និងអនុម័ត

**ត្រីមាសទី៤ ៖** នៅពេលដែលមុខងារត្រូវបានផ្ទេរ យន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានរៀបចំដើម្បីធានាថា ការផ្ទេរធនធាននឹងមិនធ្វើឱ្យមានភាពយឺតយ៉ាវដល់ការផ្ទេរមុខងារ

**ត្រីមាសទី៤ ៖** រូបមន្តនៃការវិភាជថវិកាសម្រាប់រាជធានី ខេត្ត ត្រូវបានពិនិត្យ និងកែសម្រួលដើម្បីធានាប្រសិទ្ធភាពនៃការវិភាជថវិកា

**១៩. ការបង្កើតលេខាធិការដ្ឋានទទួលបន្ទុកយន្តការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការសម្រាប់ការអនុវត្តយន្តការនេះក្នុងឆ្នាំ២០១៦ (លទ្ធផលរំពឹងទុកទី៥.៥.១)**

**ត្រីមាសទី២ ៖** លេខាធិការដ្ឋានទទួលបន្ទុកយន្តការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត

**ត្រីមាសទី២ ៖** សៀវភៅណែនាំសម្រាប់ការអនុវត្តយន្តការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត

**ត្រីមាសទី៤ ៖** ឯកសារគម្រោងស្តីពីយន្តការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានរៀបចំ និងសិក្សាវាយតម្លៃក្នុងខែមករា ឆ្នាំ២០១៦

**២០. ការពិនិត្យ និងការកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយចាប់ផ្តើមពីប្រព័ន្ធកសាងផែនការ និងការរៀបចំថវិកាក្នុងស្រុក/ឃុំនៃតំបន់ជនបទ និងក្រុង/សង្កាត់នៃតំបន់ទីប្រជុំជន សម្រាប់ប្រភេទខុសគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៥.៨.១)**

**ត្រីមាសទី២ ៖** ប្រព័ន្ធ និងសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការ/រៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួលដោយផ្អែកជាមូលដ្ឋានលើគោលនយោបាយស្តីពីការកសាងផែនការ និងដោយយកចិត្តទុកដាក់លើផែនការអភិវឌ្ឍន៍សម្រាប់រយៈពេល៥ឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេល៥ឆ្នាំ ការលើកកម្ពស់ទំនាក់ទំនងរវាងផែនការក្រុង ស្រុក និងផែនការឃុំ សង្កាត់ និងរួមបញ្ចូលនូវគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ គណនេយ្យភាពសង្គម ការប្រែប្រួលអាកាសធាតុ និងការផ្តល់សេវាសង្គម

**ត្រីមាសទី៣ ៖** សេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការ កសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ ពិភាក្សា និងអនុម័ត

**ត្រីមាសទី៤ ៖** វគ្គបណ្តុះបណ្តាលអំពីសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ២. ថវិកាសម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥

### ២.១. គម្រោងចំណាយ

ថវិការបស់ផអ៣ទី២បែងចែកជាពីរផ្នែកគឺ សកម្មភាពនានាសម្រាប់ការងារកំណែទម្រង់ និងការផ្ទេរថវិកាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណាយនានាពាក់ព័ន្ធនឹងសកម្មភាពកំណែទម្រង់បែងចែកជា៣ផ្នែកធំៗគឺ ៖

1. **ចំណាយសម្រាប់សកម្មភាព** ៖ គឺជាចំណាយផ្ទាល់សម្រាប់លទ្ធផលរំពឹងទុកនានានៃការងារកំណែទម្រង់ និងត្រូវបានគណនាដោយផ្អែកជាមូលដ្ឋានលើធាតុចូលនានាដែលត្រូវការ ដើម្បីសម្រេចបាននូវលទ្ធផលទាំងនោះ។ ចំណាយទាំងនេះរួមមាន ការរៀបចំសិក្ខាសាលា កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនានា ក៏ដូចជាចំណាយសម្រាប់ការគ្រប់គ្រងប្រព័ន្ធនានា និងចំណាយសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកម្មវិធី។
2. **ចំណាយសម្រាប់ជំនួយបច្ចេកទេស** ៖ រួមមានចំណាយសម្រាប់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានានាដែលបានជ្រើសរើស និងផ្តល់កិច្ចសន្យាប្រចាំឆ្នាំ ដើម្បីគាំទ្រការសម្រេចបាននូវលទ្ធផលរំពឹងទុកជាក់លាក់នានា។
3. **ចំណាយប្រតិបត្តិការ** ៖ ចំណាយនេះត្រូវបានវិភាជឱ្យទៅស្ថាប័នអនុវត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រចំណាយនានាដូចជា ការថែរក្សារថយន្ត ការផ្គត់ផ្គង់ការិយាល័យ និងទំនាក់ទំនងនានាសម្រាប់ការគាំទ្រដល់ការសម្រេចបាននូវព្រឹត្តិការណ៍ និងលទ្ធផលរំពឹងទុកនីមួយៗ។

សេចក្តីសង្ខេបអំពីគម្រោងចំណាយខាងលើមានរៀបរាប់ក្នុងតារាងខាងក្រោម ៖

**តារាងទី១ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៥**

| ប្រភេទសកម្មភាព | ប្រភេទចំណាយតាមប្រភព | | | សរុប |
|---|---|---|---|---|
| | ថវិកាកញ្ចប់រួម | មានគោលដៅប្រើប្រាស់ និងបដិភាគ ពុំមែនជាថវិកា | រាជរដ្ឋាភិបាល | |
| **ក. សកម្មភាព** | $5,252,392 | $18,989,018 | $0 | **$24,241,410** |
| សមិទ្ធផលទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់ | $849,813 | $1,901,180 | $0 | **$2,750,993** |
| សមិទ្ធផលទី២ ៖ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ | $642,863 | $400,000 | $0 | **$1,042,863** |
| សមិទ្ធផលទី៣ ៖ ការគ្រប់គ្រងធនធានមនុស្ស | $2,744,699 | $10,076,998 | $0 | **$12,821,697** |
| សមិទ្ធផលទី៤ ៖ ការផ្តល់សេវា និងមុខងារថ្នាក់ក្រោមជាតិ | $535,400 | $5,745,118 | $0 | **$6,280,518** |
| សមិទ្ធផលទី៥ ៖ មេដ្ឋការហិរញ្ញវត្ថុ | $479,617 | $865,722 | $0 | **$1,345,339** |
| **ខ. ជំនួយបច្ចេកទេស** | $6,073,552 | $0 | $0 | **$6,073,552** |
| **គ. ចំណាយប្រតិបត្តិការ** | $520,000 | $0 | $125,000 | **$645,000** |
| **សរុប** (ក+ខ+គ) | $11,845,944 | $18,989,018 | $125,000 | **$30,959,961** |
| **ឃ. ការផ្ទេរថវិកា** | $4,000,000 | $12,211,363 | $278,393,507 | **$294,604,870** |
| **ង. សរុបរួម** (ក+ខ+គ+ឃ) | **$15,845,944** | **$32,106,412** | **$278,518,507** | **$326,470,862** |

## ខ.២. ជំនួយបច្ចេកទេស

ក្នុងឆ្នាំ២០១៥ មានទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាសរុបចំនួន១.០១៣នាក់ដែលត្រូវការសម្រាប់គាំទ្រការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៥ ដែលមានថវិកាសរុបចំនួន៦.១លានដុល្លារ។ ការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា គឺជាកិច្ចការដ៏ចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការគាំទ្របច្ចេកទេស។ ទីប្រឹក្សាត្រូវបានជ្រើសរើស និងផ្តល់កិច្ចសន្យាការងារដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងកម្រិតប្រាក់បៀវត្សមួយដែលមានលក្ខណៈប្រកួតប្រជែងជាមួយអង្គការអន្តរជាតិនានាក្នុងគោលបំណង ១). អភិវឌ្ឍសមត្ថភាព និង ២). បំពេញកិច្ចការនានារបស់កម្មវិធីដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ។ បុគ្គលិកកិច្ចសន្យាត្រូវបានជ្រើសរើសជាបឋម ដោយថ្នាក់ក្រោមជាតិ ដោយមានកម្រិតប្រាក់បៀវត្សប្រហាក់ប្រហែលនឹងកម្រិតប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដើម្បីជួយពង្រឹងសមត្ថភាពដែលនៅខ្វះចន្លោះក្នុងការបំពេញការងារចាំបាច់នានា។ ដោយសារមានការបង្កកការជ្រើសរើសមន្ត្រីរាជការ និងភាពខ្វះខាតនៃចំនួនបុគ្គលិករបស់ក្រុង ស្រុក អាស្រ័យហេតុនេះ ការអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យា (ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងការរៀបចំក្នុងវិស័យដទៃ)។ យើងមានការសង្ឃឹមថា បុគ្គលិកកិច្ចសន្យាទាំងនេះមួយចំនួនធំនឹងត្រូវបានជ្រើសរើសជាមន្ត្រីរាជការស៊ីវិលនៅពេលដែលមានការអនុញ្ញាតឱ្យមានការជ្រើសរើសមន្ត្រីក្របខ័ណ្ឌ។ ទិន្នន័យស្តីពីបុគ្គលិកមានសង្ខេបក្នុងតារាងទី១៥ក្នុងទំព័រទី៥៦ ចំណែកនិន្នាការទូទៅស្តីពីបុគ្គលិកមានបង្ហាញក្នុងរូបភាពនៃផ្នែកបន្ទាប់។

## ខ.៣. ប្រភពមូលនិធិ

ប្រភពមូលនិធិដែលទទួលពីដៃគូអភិវឌ្ឍន៍នានារួមមាន មូលនិធិជាកញ្ចប់រួមដែលគាំទ្រសម្រាប់ការចំណាយឆន្ទានុសិទ្ធិនានា មូលនិធិមានកំណត់គោលដៅប្រើប្រាស់ (មូលនិធិរបស់គម្រោងដាច់ដោយឡែកនានា) ការចូលរួមបដិភាគពុំមែនជាថវិកា និងការផ្ទេរថវិកាដូចមានបង្ហាញក្នុងតារាងទី៤ ៖

- មូលនិធិកញ្ចប់រួម គឺជាមូលនិធិឆន្ទានុសិទ្ធិ គាំទ្រដោយ Sida, EU និង SDC ដែលមានចំនួនសរុប១១.៨៧៨.០០០ដុល្លារក្នុងឆ្នាំ២០១៥។
- រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ថវិកាគាំទ្រចំនួន២៧៨.៥លានដុល្លារ ដែលភាគច្រើនជាការផ្ទេរថវិកាពីថវិការដ្ឋ (មើលតារាងខាងក្រោម) និងថវិកាចំនួន១២៥.០០០ដុល្លារដែលគាំទ្រដោយផ្ទាល់សម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប។ ថវិកាគាំទ្ររបស់រាជរដ្ឋាភិបាលមានចំនួន៨៥,៣ភាគរយនៃមូលនិធិសរុប[4]។ ធនធានដែលបានវិភាជឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងជាលំដាប់ ហើយមូលនិធិទាំងនេះរំពឹងថានឹងត្រូវបានប្រើប្រាស់មិនគ្រាន់តែសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការផ្តល់សេវាជូនប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងត្រូវបានប្រើប្រាស់សម្រាប់គាំទ្រសកម្មភាពកំណែទម្រង់ផងដែរ។

[4] ការគណនាមូលនិធិសរុបនេះមិនបានបញ្ចូលការចំណាយនានាដែលជាថវិការបស់ក្រសួង ស្ថាប័នឡើយ។

- ថវិកាជាកម្ចីមានចំនួន២២លានដុល្លារ។ ការទូទាត់សងកម្ចីទាំងនេះ គឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល។ ថវិកាកម្ចីនេះគាំទ្រប្រមាណ៦,៧%នៃសកម្មភាពទាំងអស់។
- មូលនិធិគាំទ្រពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត តាមរយៈគម្រោងជាច់ដោយឡែកនានាមានចំនួនសរុប៥,៦លានដុល្លារ ហើយការបដិភាគពុំមែនជាថវិកាមានចំនួន២,៩លានដុល្លារ។

**រូបភាពទី១ ៖ និន្នាការស្តីពីថវិកានៃជំនួយបច្ចេកទេស**




**រូបភាពទី២ ៖ និន្នាការស្តីពីថវិកាជាកញ្ចប់រួម (ប្រភពមូលនិធិ)**




**តារាងទី២ ៖ ទិន្នន័យនៃការផ្ទេរថវិការដ្ឋឆ្នាំ២០១៥**

| ប្រភពធនធាន | គិតជារៀល | គិតជាដុល្លារ | ភាគរយ |
|---|---|---|---|
| មូលនិធិឃុំ សង្កាត់ | 271,945,000,000 | 67,146,914 | 24.12% |
| មូលនិធិក្រុង ស្រុក | 81,302,000,000 | 20,074,568 | 7.21% |
| ថវិការាជធានី ខេត្ត | 753,940,000,000 | 186,158,025 | 66.87% |
| មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ | 20,306,700,000 | 5,014,000 | 1.80% |
| **សរុប** | **1,127,493,700,000** | **278,393,506** | **100.00%** |

## តារាងទី៣ ៖ ព័ត៌មានលម្អិតស្តីពីមូលនិធិតាមប្រភព

| ប្រភពមូលនិធិ | ១.មូលនិធិជាកញ្ចប់ | ២.កំណត់គោលដៅប្រើប្រាស់ | ៣.បដិភាគពុំមែនថវិកា | ៤. កំណែទម្រង់ (១+២+៣) | % ថវិកាកំណែទម្រង់ | ការផ្ទេរឱ្យថ្នាក់ក្រោមជាតិ | សរុប | % |
|---|---|---|---|---|---|---|---|---|
| **1. ថវិការាជរដ្ឋាភិបាល** | **$0** | **$125,000** | **$0** | **$125,000** | **0.39%** | **$278,393,506** | **$278,518,506** | **85.3%** |
| **2. ថវិកាកម្ចី** | **$0** | **$11,411,382** | **$0** | **$11,411,382** | **35.77%** | **$10,572,055** | **$21,983,437** | **6.7%** |
| 2.1. ADB/DPSFM | $0 | $10,147,700 | $0 | $10,147,700 | 31.81% | $0 | $10,147,700 | 3.1% |
| 2.2. ADB/TS-PRSDP | $0 | $1,263,682 | $0 | $1,263,682 | 3.96% | $10,572,055 | $11,835,737 | 3.6% |
| **3. មូលនិធិពីដៃគូអភិវឌ្ឍន៍** | **$11,878,000** | **$5,577,636** | **$2,906,031** | **$20,361,667** | **63.83%** | **$5,639,308** | **$26,000,975** | **8.0%** |
| 3.1. Sweden/SIDA [2] | $4,290,000 | $0 | $0 | $4,290,000 | 13.45% | $4,000,000 | $8,290,000 | 2.5% |
| 3.2. EU [3] | $5,500,000 | $0 | $0 | $5,500,000 | 17.24% | $0 | $5,500,000 | 1.7% |
| 3.3. Swiss/SDC [4] | $2,088,000 | $0 | $0 | $2,088,000 | 6.55% | $0 | $2,088,000 | 0.6% |
| 3.4. ADB/RWS O&M | $0 | $125,000 | $0 | $125,000 | 0.39% | $0 | $125,000 | 0.0% |
| 3.5. ADB/PPTA | $0 | $0 | $400,000 | $400,000 | 1.25% | $0 | $400,000 | 0.1% |
| 3.6. EU-SPACE | $0 | $0 | $1,600,000 | $1,600,000 | 5.02% | $0 | $1,600,000 | 0.5% |
| 3.7. UNCDF/LDDPHS | $0 | $166,600 | $0 | $166,600 | 0.52% | $100,000 | $266,600 | 0.1% |
| 3.8. UNDP/SNC Scale-up | $0 | $124,437 | $0 | $124,437 | 0.39% | $0 | $124,437 | 0.0% |
| 3.9. UNDP-EU/ACES | $0 | $1,501,180 | $0 | $1,501,180 | 4.71% | $0 | $1,501,180 | 0.5% |
| 3.10. UNICEF/Seth Koma | $0 | $2,372,119 | $906,031 | $3,278,150 | 10.28% | $481,284 | $3,759,434 | 1.2% |
| 3.11. UNCDF/LGCC2 | $0 | $190,212 | $0 | $190,212 | 0.60% | $470,852 | $661,064 | 0.2% |
| 3.12. UN/Women | $0 | $93,246 | $0 | $93,246 | 0.29% | $0 | $93,246 | 0.0% |
| 3.13. UNFPA | $0 | $107,354 | $0 | $107,354 | 0.34% | $191,592 | $298,946 | 0.1% |
| 3.14. WB-CTPP | $0 | $241,920 | $0 | $241,920 | 0.76% | $395,580 | $637,500 | 0.2% |
| 3.15. WB-RSDSD TA | $0 | $500,000 | $0 | $500,000 | 1.57% | $0 | $500,000 | 0.2% |
| 3.16. WB-LASED | $0 | $155,568 | $0 | $155,568 | 0.49% | $0 | $155,568 | 0.0% |
| **4. សរុបរួម (1+2+3)** | **$11,878,000** | **$17,114,018** | **$2,906,031** | **$31,898,049** | **100.00%** | **$294,604,869** | **$326,502,918** | **100%** |
| % | 3.64% | 5.24% | 0.89% | 9.77% | | 90.23% | 100% | |

សម្គាល់ ៖ [1] ការផ្ទេរថវិការបស់រាជរដ្ឋាភិបាលរួមការផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងឃុំ សង្កាត់ និងការផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌពីក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ, [2] មូលនិធិថ្មីចំនួន២លានដុល្លារ ផ្ទេរពីឆ្នាំ២០១៤ចំនួន២,២៩លានដុល្លារ និងការគាំទ្រមូលនិធិក្រុង ស្រុកចំនួន៤លានដុល្លារ, [3] បដិភាគរបស់ PE-3 ចំនួន៥,៥លានដុល្លារពីខែកុម្ភៈ២០១៥-មករា២០១៦ ចំណែកប្រាក់ខែសម្រាប់ខែមករា២០១៥គាំទ្រដោយ PE-2, [4] មូលនិធិថ្មីចំនួន១,៥លានដុល្លារ និងផ្ទេរពីឆ្នាំ២០១៤ចំនួន០,៥៨៨លានដុល្លារ។

# ជំពូកទី១

# សមិទ្ធផលទី១ស្តីពីការគ្រប់គ្រងការងារកំណែទម្រង់

## ១.១. សេចក្តីផ្តើម និងចំណុចដៅ

ភាពជោគជ័យនៃដំណាក់កាលទី២ អាស្រ័យលើភាពប៉ិនប្រសព្វនៃការគ្រប់គ្រងកិច្ចដំណើរការនានានៃការផ្លាស់ប្តូរ។ សមិទ្ធផលទី១នេះនឹងដោះស្រាយនូវបញ្ហាជាគន្លឹះមួយចំនួន ដែលបានជួបប្រទះក្នុងផអ៣ដំណាក់កាលទី១ដោយចាប់ផ្តើម ៖ ១) ដោះស្រាយចរិតលក្ខណៈនយោបាយនៃកំណែទម្រង់ ២) ពង្រឹងភាពជាម្ចាស់ ៣) លើកកម្ពស់ទំនាក់ទំនង និងតម្លាភាព ៤) គ្រប់គ្រងការផ្លាស់ប្តូរ និងលទ្ធផលប្រកបដោយប្រសិទ្ធភាព ៥) ធ្វើឱ្យប្រសើរឡើងនូវការសិក្សារៀនសូត្រ និង៦) កែលម្អកិច្ចដំណើរការអភិវឌ្ឍន៍គោលនយោបាយ។

សមិទ្ធផលសំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់ ដែលត្រូវសម្រេចឱ្យបានគឺ **ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឱ្យមានការផ្លាស់ប្តូរ។**

តារាងខាងក្រោមសង្ខេបអំពីចំណុចដៅដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលនេះ។ ក្នុងផ្នែកបន្ទាប់នៃជំពូកនេះបង្ហាញអំពីលទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកា។

**តារាងទី៤៖ ចំណុចដៅសម្រាប់សមិទ្ធផលទី១**

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនកិច្ចប្រជុំរបស់ គ.ជ.អ.ប ក្នុង១ឆ្នាំ | 3 | 3 | 3 |
| ២. ចំនួនថវិកាចំណាយសម្រាប់ជំនួយបច្ចេកទេស | 5,50 | 5,00 | 4,50 |
| ៣. ចំនួនប្រជាពលរដ្ឋដែលបានទទួលការផ្សព្វផ្សាយព័ត៌មានដើម្បីបង្កើនការយល់ដឹងជាសាធារណៈ និងការផ្លាស់ប្តូរឥរិយាបថក្នុង១ឆ្នាំ | 100.000 | 100.000 | 100.000 |
| ៤. ចំនួនភាគរយនៃចំណុចដៅដែលបានសម្រេចតាមពេលវេលាបានកំណត់ | 50 | 60 | 70 |
| ៥. ចំនួនភាគរយនៃស្ថាប័នអនុវត្តកម្មវិធីដែលពេញចិត្តចំពោះការរៀបចំផែនការសកម្មភាពនិងថវិកា ការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ដែលសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប | 50 | 60 | 70 |
| ៦. ចំនួនក្រសួងដែលបានរៀបចំផ្សព្វផ្សាយព័ត៌មានជាសាធារណៈក្នុងការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ | 1 | 2 | 5 |

**១.២. លទ្ធផលរំពឹងទុក**

ផ្អែកតាមផអ៣ទី២ សមិទ្ធផលទី១ស្តីពីការគ្រប់គ្រងការងារកំណែទម្រង់មានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ប្រចាំឆ្នាំចំនួន៦ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ១.១. ការលើកកម្ពស់នូវការដឹកនាំ ការគ្រប់គ្រង និងការសម្របសម្រួលក្នុងការសម្រេចចិត្តខាងនយោបាយ និងការអនុវត្តកម្មវិធីរបស់ គ.ជ.អ.ប ដើម្បីធានាដល់ការអនុវត្តច្បាប់រៀបចំអង្គការឱ្យកាន់តែមានប្រសិទ្ធភាព**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖១.១.១. ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប តាមរយៈកិច្ចដំណើរការដែលបានកែសម្រួល**

ជម្រើសនានាសម្រាប់ការពង្រឹងទំនាក់ទំនងរវាង គ.ជ.អ.ប ជាមួយអ្នកនយោបាយជាន់ខ្ពស់អំពីការសម្រេចចិត្តជាគន្លឹះពាក់ព័ន្ធនឹងការងារកំណែទម្រង់នឹងត្រូវបានយកមកពិចារណា ដើម្បីអនុវត្ត។ ទម្រង់របាយការណ៍របស់ គ.ជ.អ.ប ដែលផ្តោតលើចំណុចដៅ និងលទ្ធផលជាគន្លឹះនឹងត្រូវបានពិនិត្យមើលឡើងវិញនិងដាក់ឱ្យអនុវត្តរួមបញ្ចូលទាំងការរៀបចំនានារវាង គ.ជ.អ.ប និងអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប ក្នុងការរៀបចំរបាយការណ៍។ គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិចចំនួន៣ដងក្នុង១ឆ្នាំ ដែលក្នុងនោះមានកិច្ចប្រជុំយ៉ាងតិចចំនួន២នឹងពិភាក្សាអំពីលទ្ធផល និងការអនុវត្តការងាររីឯកិច្ចប្រជុំមួយទៀតនឹងពិភាក្សាអំពីបរិយាប័ន្ន និងសមធម៌សង្គម។ អនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាកាតព្វកិច្ចរបស់ខ្លួន ដើម្បីពិនិត្យមើលការអនុវត្តរយៈពេលកន្លងមក និងរៀបចំផែនការសកម្មភាពសម្រាប់អនាគត (ដោយមានចំណុចដៅច្បាស់លាស់)។ លទ្ធផលរំពឹងទុកនេះនឹងដឹកនាំអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានការចូលរួមពីក្រសួង ស្ថាប័ននានាដែលជាសមាជិករបស់ គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ១.២. ការផ្លាស់ប្តូរតួនាទីលេខាធិការដ្ឋាន គ.ជ.អ.ប ពីតួនាទីប្រតិបត្តិទៅជាតួនាទីសម្របសម្រួល និងគាំទ្រការអនុវត្ត និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ១.២.១. លេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធ សមត្ថភាពនិងការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងផ្អែកលើលទ្ធផល ការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចដំណើរការរៀបចំ ផ.ស.ថ និងការអភិវឌ្ឍគោលនយោបាយ**

កិច្ចសំខាន់ៗក្នុងលទ្ធផលរំពឹងទុកនេះគឺ ការពិនិត្យមើលឡើងវិញនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងផ្អែកលើលទ្ធផល ការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីនានា ហើយលទ្ធផលនៃការពិនិត្យមើលឡើងវិញនេះនឹងយកមកបង្ហាញ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានា ដោយផ្តោត

ការយកចិត្តទុកដាក់លើវិធីសាស្ត្រនានាសម្រាប់ការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ និងកិច្ចដំណើរការពាក់ព័ន្ធផ្សេងទៀត។ បន្ទាប់មក ត្រូវរៀបចំវគ្គបណ្តុះបណ្តាលអំពីនីតិវិធីដែលបានកែសម្រួលទាំងនេះ ដោយរួមបញ្ចូលទាំងការបណ្តុះបណ្តាលអំពីការគ្រប់គ្រងផ្អែកលើលទ្ធផល ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងអនុវត្តសកម្មភាពសមត្ថភាពជាច្រើនបន្ថែមទៀត។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ១.៣. ការរៀបចំ និងការអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការចែករំលែកព័ត៌មានក្នុងចំណោមស្ថាប័នរដ្ឋនានា និងរវាងស្ថាប័នរដ្ឋជាមួយនឹងសាធារណៈជនក្នុងគោលបំណងផ្តល់ព័ត៌មានសំខាន់ៗឱ្យបានច្បាស់លាស់ និងកំណត់អំពីវិធីសាស្ត្រសមស្របសម្រាប់ផ្តល់ព័ត៌មានដល់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នា**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ១.៣.១. ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រស្តីពីទំនាក់ទំនង និងការសិក្សារៀនសូត្ររបស់ផអ៣ទី២**

កិច្ចការសំខាន់ក្នុងលទ្ធផលរំពឹងទុកនេះ គឺការកំណត់គោលការណ៍ និងអាទិភាពនានានៃទំនាក់ទំនងដោយមានការជួយគាំទ្រ និងសម្របសម្រួលពីទីប្រឹក្សារបស់គ្រឹះស្ថានអាស៊ី (TAF)។ ដូច្នេះ ក្នុងឆ្នាំ២០១៥ យ៉ាងហោចណាស់មានអាទិភាព១ក្នុងចំណោមអាទិភាពដែលបានកំណត់ទាំងនេះ នឹងត្រូវបានអនុវត្ត។ ចក្ខុវិស័យនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាំងក្នុងរយៈពេលវែងនិងរយៈពេលមធ្យម នឹងត្រូវបានផ្សព្វផ្សាយ និងមានការយល់ដឹងកាន់តែទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងបណ្តាសាធារណៈជននានា។ សេចក្តីសង្ខេបអំពីយុទ្ធសាស្ត្រជាអាទិភាពដែលមានបំណងបង្វែរការផ្តោតការយកចិត្តទុកដាក់ពីការលើកកម្ពស់ចំណេះដឹងនិងព័ត៌មាន ទៅជាការផ្លាស់ប្តូរឥរិយាបថ តាមរយៈវិធីសាស្ត្រផ្សព្វផ្សាយការងារផ្នែកសង្គម។ ម្យ៉ាងទៀត សិក្ខាសាលានានាស្តីពីការសិក្សារៀនសូត្រក៏នឹងត្រូវបានរៀបចំរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ឱកាសដល់អ្នកគ្រប់គ្រងកម្មវិធីនានាយកចិត្តទុដាក់ស្តាប់ និងសិក្សារៀនសូត្រអំពីបទពិសោធន៍របស់ប្រតិបត្តិករនានា។ ជាងនេះទៀត សង្គមស៊ីវិលនានានឹងត្រូវបានអញ្ជើញឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំយុទ្ធសាស្ត្រស្តីពីទំនាក់ទំនង និងការសិក្សារៀនសូត្រនេះ។ លទ្ធផលនេះនឹងត្រូវអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃផអ៣ ៖ ១.៤. ការពង្រឹងភាពជាម្ចាស់ និងការចូលរួមរបស់ក្រសួង ស្ថាប័ននៅក្នុងកិច្ចដំណើរការកំណែទម្រង់**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ១.៤.១. ការពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ននានាក្នុងកិច្ចដំណើរការផ្ទេរមុខងារនិងធនធាន និងការចូលរួមក្នុងកិច្ចដំណើរការនៃកំណែទម្រង់**

ការផ្ទេរមុខងារតម្រូវឲ្យក្រសួង ស្ថាប័ននានាដាក់បញ្ចូលកិច្ចដំណើរការកំណែទម្រង់ទៅក្នុង

របនាសម្ព័ន្ធ គោលនយោបាយ ការរៀបចំផែនការនិងថវិកា និងកិច្ចដំណើរការត្រួតពិនិត្យនិងវាយតម្លៃរបស់ខ្លួន។ លទ្ធផលរំពឹងទុកនេះ មានគោលបំណងពង្រឹងសមត្ថភាពរបស់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ននីមួយៗ លើកកម្ពស់ប្រសិទ្ធភាពនិងភាពទៀងទាត់នៃការរៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នដែលអនុវត្តកិច្ចដំណើរការផ្ទេរមុខងារ និងយ៉ាងហោចណាស់មានក្រសួងចំនួន១ ដែលនឹងធ្វើការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីការគាំទ្ររបស់ខ្លួនដល់ការងារកំណែទម្រង់វិមជ្ឈការ។ លទ្ធផលនេះនឹងអនុវត្តដោយក្រសួងនានាដែលអនុវត្តកិច្ចដំណើរការផ្ទេរមុខងារនិងធនធាន។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ១.៥. ការបង្កើនភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកិច្ចដំណើរការកំណែទម្រង់ និងវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ទៅតាមតម្រូវការជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ១.៥.១. ការពង្រឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រងកិច្ចដំណើរការនៃការកសាងសមត្ថភាពប្រកបដោយប្រសិទ្ធភាព តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត**

សកម្មភាពនានានៃការអភិវឌ្ឍនសមត្ថភាព នឹងត្រូវអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត។ ការផ្លាស់ប្តូរនេះតម្រូវឲ្យមានការពិនិត្យមើលឡើងវិញអំពីតួនាទី ការទទួលខុសត្រូវនិងថវិការបស់រាជធានី ខេត្តដែលទាក់ទងនឹងការកសាងសមត្ថភាព។ ដូច្នេះ ត្រូវរៀបចំសេចក្តីណែនាំនានាដែលរៀបរាប់អំពីទំនាក់ទំនងផ្នែកស្ថាប័ន និងរបៀបដែលរាជធានី ខេត្តត្រូវផ្តល់ការគាំទ្រដល់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស។ លទ្ធផលនេះនឹងត្រូវបានអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប រាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌ។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ១.៥.២. ការកែសម្រួល ការគាំទ្រ និងការពង្រឹងសមត្ថភាពរបស់សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន សម្រាប់ផ្តល់ការគាំទ្រដល់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើតឡើង។ ជាមួយគ្នានេះដែរ កិច្ចប្រជុំប្រចាំឆ្នាំរបស់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋាន និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួននឹងត្រូវរៀបចំជាប្រចាំ។ លទ្ធផលនេះនឹងអនុវត្តដោយសមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**១.៣. គម្រោងថវិកា**

ថវិកាសរុបសម្រាប់សមិទ្ធផលនេះក្នុងឆ្នាំ២០១៥មានចំនួន២,៧៥លានដុល្លារ ដូចមានលម្អិតនៅក្នុងតារាងខាងក្រោម ៖

**តារាងទី៥៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលទី១**

| លទ្ធផលរំពឹងទុកនៃ ផ.ស.ថ | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១.១.១ | ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប តាមរយៈកិច្ចដំណើរការដែលបានកែសម្រួល | $43,200 | | $43,200 | |
| ១.២.១ | លេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យមើលឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធ សមត្ថភាពនិងការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងផ្អែកលើលទ្ធផល ការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចដំណើរការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងការអភិវឌ្ឍគោលនយោបាយ។ | $625,300 | $200,000 | $825,300 | [1] |
| ១.៣.១ | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីទំនាក់ទំនង និងការសិក្សារៀនសូត្រនៅក្នុង ផអ៣ទី២ | $73,800 | | $73,800 | |
| ១.៤.១ | ការពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ននានាក្នុងកិច្ចដំណើរការផ្ទេរមុខងារនិងធនធាន និងការចូលរួមក្នុងកិច្ចដំណើរការនៃកំណែទម្រង់ | | $200,000 | $200,000 | [1] |
| ១.៥.១. | ការពង្រឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រងកិច្ចដំណើរការកសាងសមត្ថភាពប្រកបដោយប្រសិទ្ធភាព តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត | | | $0 | |
| ១.៥.២. | ការកែសម្រួល ការគាំទ្រ និងការពង្រឹងសមត្ថភាពរបស់សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | $107,513 | $1,501,180 | $1,608,693 | [2] |
| **សរុប** | | **$849,813** | **$1,901,180** | **$2,750,993** | |

<u>**សម្គាល់**</u> ៖ **ផ្សេងៗ** រួមបញ្ចូលគ្នានូវការបដិភាគពុំមែនជាថវិកា និងមូលនិធិមានកំណត់គោលដៅប្រើប្រាស់ជាក់លាក់ (១) គាំទ្រដោយ EU-SPACE និង (២) គាំទ្រដោយ UNDP-EU/ACES។

# ជំពូកទី២
# សមិទ្ធផលទី២ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

## ២.១. សេចក្តីផ្តើម និងចំណុចដៅ

គោលបំណងជាចម្បងនៃផអ៣ទី២ គឺការអភិវឌ្ឍស្ថាប័នតាមបែបប្រជាធិបតេយ្យនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអង្គតំណាងឱ្យប្រជាពលរដ្ឋ និងត្រូវឆ្លើយតបចំពោះសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ។ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសមិទ្ធផលនេះមានដូចជា ការកំណត់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងគណនេយ្យភាពរវាងគណៈអភិបាលជាមួយក្រុមប្រឹក្សា ការអនុវត្តនូវសកម្មភាពនានាស្តីពីគណនេយ្យភាពសង្គមនិងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ការពង្រឹងនូវការធ្វើអធិការកិច្ចលើការអនុវត្តតាមលិខិតបទដ្ឋាននានាដែលបានដាក់ចេញដោយថ្នាក់ជាតិ និងការធ្វើនីត្យានុកូលភាពលើលិខិតបទដ្ឋាននានាដែលដាក់ចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ នឹងមានការរៀបចំ និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធប្រតិបត្តិការនានាដូចជា ប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យាដើម្បីជួយសម្រួលការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

សមិទ្ធផលសំខាន់ពាក់ព័ន្ធនឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋានដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមក្របខណ្ឌច្បាប់ និងស្តង់ដារនានារបស់ជាតិ។**

តារាងខាងក្រោមនេះបង្ហាញអំពីសេចក្តីសង្ខេបនៃចំណុចដៅ ដែលបានកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបាននូវចំណុចដៅទាំងនេះ ព្រមទាំងទទួលខុសត្រូវក្នុងការគ្រោងលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលរួមចំណែកដល់ការសម្រេចបាននូវសមិទ្ធផលនេះ។ ជំពូកនេះបរិយាយអំពីលទ្ធផលរំពឹងទុកដែលត្រូវសម្រេចក្នុងឆ្នាំ២០១៥ និងគម្រោងថវិកា។

**តារាង៦៖ ចំណុចដៅសម្រាប់សមិទ្ធផលទី២**

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ក្របខ័ណ្ឌគតិយុត្តត្រូវបានពង្រឹងដើម្បីធានាឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ពិសេសសិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធាន និងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន | មាន | មាន | មាន |
| ២. ចំនួនក្រុង ស្រុកបានអនុម័ត និងអនុវត្តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន | 50 | 185 | 185 |

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ៣. ៨០%នៃក្រុមប្រឹក្សាក្រុង ស្រុកយល់ឃើញថាសិទ្ធិអំណាចរបស់ខ្លួនជាមួយគណៈអភិបាលមានភាពរឹងមាំជាងពីមុន | 20% | 50% | 80% |
| ៤. ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកប្រើប្រាស់ព័ត៌មាន ទទួលបានតាមរយៈប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ប្រព័ន្ធគ្រប់គ្រងតាមព័ត៌មានវិទ្យា | 100 | 300 | 591 |
| ៥. ចំនួនស្រុកដែលគ្រប់ឃុំទាំងអស់បានបិទបង្ហាញព័ត៌មានដល់សាធារណជន (ស្របតាមការណែនាំស្តីពីការបើកចំហរព័ត៌មាន) បានចូលរួមការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងបានរៀបចំផែនការសកម្មភាពគណនេយ្យភាពរួមគ្នា ដើម្បីកែលម្អការផ្តល់សេវា | 20 | 70 | 120 |
| ៦. កម្មវិធីគណនេយ្យភាពសង្គមដំណាក់កាលទី២ ត្រូវបានរៀបចំដើម្បីបញ្ចូលនូវសេវាផ្សេងៗទៀត និងថ្នាក់រដ្ឋបាលដទៃទៀត។ | គ្មាន | គ្មាន | មាន |
| ៧. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់ | 0 | 1,000 | 3,000 |
| ៨. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 0 | 500 | 1,200 |
| ៩. ចំនួនប្រជាពលរដ្ឋចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 5,000 | 7,000 | 9,000 |
| ១០. ចំនួនអង្គការសង្គមស៊ីវិលចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 500 | 700 | 900 |
| ១១. ការចូលរួមបដិភាគជាថវិការបស់ឃុំទៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា(គិតជា លានដុល្លា) | 0.10 | 0.25 | 0.50 |
| ១២. ការវាយតម្លៃពីផលប៉ះពាល់ត្រូវបានបញ្ចប់ដោយ ប្រៀបធៀបក្រុមប្រជាពលរដ្ឋទទួលផល និងក្រុមប្រជាពលរដ្ឋផ្សេងទៀត ព្រមទាំងបង្ហាញពីការកែលម្អនូវសូចនាករនៃផ្ទាំងព័ត៌មាន | គ្មាន | គ្មាន | មាន |
| ១៣. %នៃរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលត្រូវបានធ្វើអធិការកិច្ចលើការអនុវត្តតាម ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងបានទទួលនូវការពេញចិត្តតាមរយៈការវាយតម្លៃ | 20% | 30% | 40% |

## ២.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលទី២ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ប្រចាំឆ្នាំចំនួន៧ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ២.១. តួនាទី និងខ្សែគណនេយ្យភាពយ៉ាងច្បាស់លាស់រវាងគណៈអភិបាល និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង និងអនុវត្ត**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៤ ៖ ២.១.១. ការអនុម័តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកនៅក្នុងក្រុង ស្រុកចំនួន៥០**

គំរូនៃវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក និងសេចក្តីណែនាំស្តីពីកិច្ចដំណើរការនៃការរៀបចំ និងការអនុម័តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក នឹងត្រូវបានរៀបចំបញ្ចប់ដោយលេខាធិការដ្ឋាន គ.អ.ជ.ប. និងធ្វើតេស្តសាកល្បង ដោយសហការជាមួយកម្មវិធី EU-SPACE នៅក្នុងតំបន់គោលដៅ។ បន្ទាប់ពីការកែសម្រួលផ្អែកលើលទ្ធផលនៃការធ្វើតេស្ត ក្រុមប្រឹក្សាក្រុង ស្រុកមួយចំនួននឹងទទួលបានការគាំទ្រ ដើម្បីរៀបចំទៅជាវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួនផ្ទាល់។ បន្ទាប់ពីវិធានគ្រប់គ្រងផ្ទៃក្នុងបានអនុម័តដោយក្រុមប្រឹក្សា និងបានអនុវត្តដោយរដ្ឋបាលក្រុង ស្រុក លេខាធិការដ្ឋាន គ.អ.ជ.ប នឹងរៀបចំការវាយតម្លៃមួយ ដើម្បីពិនិត្យមើលពីភាពជោគជ័យ និងបញ្ហាប្រឈមនៃការអនុវត្តវិធីគ្រប់គ្រងផ្ទៃក្នុងនៅក្នុងក្រុង ស្រុកទាំងនោះ។

**លទ្ធផលរំពឹងទុកនៃ ផ.ស.៤ ៖ ២.១.២. ការពិនិត្យមើលឡើងវិញនូវប្រព័ន្ធ និងនីតិវិធីនានា ដើម្បីធានាថាតួនាទីរបស់ក្រុមប្រឹក្សាមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ និងធានាពង្រឹងការរៀបចំលិខិតបទដ្ឋានការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យមើលពីលើរបស់ក្រុមប្រឹក្សា**

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងកំណត់ វិភាគ និងធ្វើការកែសម្រួលលិខិតបទដ្ឋាននានា ប្រព័ន្ធគោលការណ៍ណែនាំ និងនីតិវិធីនានា ដើម្បីបញ្ជាក់ច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានិងគណៈអភិបាល ព្រមទាំងធានាឱ្យមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ រាល់ការផ្លាស់ប្តូរនានាពាក់ព័ន្ធការកែសម្រួលលិខិតបទដ្ឋានខាងលើត្រូវបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលនានា ដែលនឹងរៀបចំឡើងដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជធានី ខេត្ត ហើយត្រូវឆ្លុះបញ្ចាំងនៅក្នុងវិសោធនកម្មនៃក្របខ័ណ្ឌគតិយុត្តនានា ក៏ដូចជាការដាក់បញ្ចូលទៅក្នុងវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក។

**លទ្ធផលរំពឹងនៃ ផអ៣ទី២ ៖ ២.២. សម្លេងរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនានាបានឆ្លុះបញ្ចាំងកាន់តែល្អប្រសើរនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុង ស្រុក និងឃុំ សង្កាត់**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៤ ៖ ២.២.១. ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងស្រុកគោលដៅចំនួន២២ស្រុក**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងលទ្ធផលរំពឹងទុកនេះរួមមាន ការលើកកម្ពស់ចំណេះដឹង និងព័ត៌មាន ការអប់រំ និងទំនាក់ទំនង (IEC) ការផ្តល់លទ្ធភាពទទួលបាននូវព័ត៌មានសំខាន់ៗដល់ប្រជាពលរដ្ឋអំពីសិទ្ធិ ថវិកានិងការអនុវត្តការងារ ការរៀបចំប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋនិងការត្រួតពិនិត្យការអនុវត្ត ការរៀបចំកិច្ចប្រជុំនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ការរៀបចំ

ផែនការសកម្មភាពគណនេយ្យភាពរួមនិងអនុវត្តផែនការនោះ។ ជាមួយគ្នានេះដែរ គំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព ការត្រួតពិនិត្យតាមដាន ការវាយតម្លៃ និងការសិក្សារៀនសូត្រ (MEL) ក៏នឹងត្រូវបានអនុវត្ត (ដោយមានការគាំទ្រមូលនិធិពីអង្គការយូនីសេហ្វ) ក៏ដូចការរៀបចំបញ្ចប់និងការដាក់ឱ្យអនុវត្តនូវបែបផែននានាផ្នែកអភិបាលកិច្ច។ ការងារគណនេយ្យភាពសង្គមនឹងអនុវត្តដោយសាលាឃុំ សាលាបឋមសិក្សា មណ្ឌលសុខភាព អង្គការសង្គមស៊ីវិល រដ្ឋបាលស្រុក អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ២.២.២. ការរៀបចំវេទិកាសាធារណៈ និងសកម្មភាពនានាពាក់ព័ន្ធនឹងការចូលរួមរបស់សង្គមស៊ីវិលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ឯកសារបច្ចេកទេសស្តីពីការចូលរួមរបស់សង្គមស៊ីវិលនឹងត្រូវផ្សព្វផ្សាយ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។ វេទិកានានានឹងត្រូវបានរៀបចំជាប្រចាំដោយរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ នៅចុងឆ្នាំ២០១៥ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តនូវកិច្ចការនេះ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ២.២.៣. ការពិនិត្យមើលឡើងវិញ ការកែសម្រួល និងការធ្វើតេស្តសាកល្បងនូវយន្តការទទួលពាក្យបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ៗក្នុងលទ្ធផលនេះរួមមាន ការពិនិត្យមើលឡើងវិញលើការអនុវត្តយន្តការទទួលពាក្យបណ្តឹងបច្ចុប្បន្ន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំកែសម្រួលប្រព័ន្ធ ការរៀបចំគោលការណ៍ណែនាំ សៀវភៅណែនាំអនុវត្ត និងឧបករណ៍ផ្សេងៗទៀត។ ប្រព័ន្ធកែសម្រួលថ្មីនេះ នឹងត្រូវបានធ្វើការសាកល្បង បន្ទាប់មកនឹងដាក់ឱ្យអនុវត្ត តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកនៃ ផអ៣ទី២ ៖ ២.៣. ការបញ្ចូលទៅក្នុងស្ថាប័ន តម្លាភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការត្រួតពិនិត្យការអនុវត្តតាមលិខិតបទដ្ឋានបានដាក់ឱ្យអនុវត្ត**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ២.៣.១. ការរៀបចំ និងការអនុវត្តសាកល្បងនូវប្រព័ន្ធអធិការកិច្ចអំពីការអនុវត្តតាមលិខិតបទដ្ឋាននានានៅទីតាំងយ៉ាងតិចចំនួន១០កន្លែង**

នៅឆ្នាំ២០១៥ សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីអធិការកិច្ចនឹងត្រូវរៀបចំបញ្ចប់។ បន្ទាប់មក គឺការរៀបចំសៀវភៅណែនាំអនុវត្តដែលមានរៀបរាប់អំពីកិច្ចដំណើរការ បញ្ជីផ្ទៀងផ្ទាត់ និងប្រព័ន្ធដាក់ពិន្ទុការអនុវត្តសាកល្បង (រួមទាំងការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច)។ ប្រព័ន្ធអធិការកិច្ចមានវិសាលភាពគ្របដណ្តប់ទៅលើអភិបាលកិច្ច ធនធានមនុស្ស ហិរញ្ញវត្ថុនិងលទ្ធកម្ម និងកិច្ចការរដ្ឋបាលផងដែរ។ ប្រព័ន្ធនេះនឹងត្រូវបានអនុវត្ត ដោយមានសហការគ្នារវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ហើយលទ្ធផលនៃការធ្វើអធិការកិច្ចនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងត្រូវបានយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំ

របស់ក្រុមប្រឹក្សា។ លទ្ធផលរំពឹងទុកនេះនឹងត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ២.៤. ប្រព័ន្ធរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃត្រូវបានពង្រឹង**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ២.៤.១. ការរៀបចំបញ្ចប់ និងការផ្សព្វផ្សាយសៀវភៅណែនាំ និងនីតិវិធីប្រតិបត្តិការរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់នៅទូទាំងប្រទេស**

សៀវភៅណែនាំ និងនីតិវិធីប្រតិបត្តិការដែលត្រូវរៀបចំ បរិយាយអំពីរបៀបនៃការបំពេញមុខងាររបស់ការិយាល័យនីមួយៗ នីតិវិធីសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំរបាយការណ៍ ធ្វើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ ក៏ដូចជានីតិវិធីសម្រាប់ក្រុង ស្រុក ខណ្ឌអនុវត្តគម្រោងនានា។ បន្ទាប់ពីសៀវភៅណែនាំ និងនីតិវិធីទាំងនេះត្រូវបានរៀបចំរួចរាល់ រដ្ឋបាលក្រុង ស្រុក ខណ្ឌនឹងទទួលបាននូវការពង្រឹងសមត្ថភាពអំពីនីតិវិធីទាំងនេះ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។ ជាមួយគ្នានេះដែរ ជំពូកទី៣នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់នឹងត្រូវពិនិត្យមើលឡើងវិញ ដើម្បីកែសម្រួលផ្នែកមួយចំនួនពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា។ លទ្ធផលរំពឹងទុកនេះនឹងត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ និងការពង្រឹងសមត្ថភាពដឹកនាំដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ២.៤.២. ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌ តាមប្រព័ន្ធកុំព្យូទ័រដែលផ្តល់ព័ត៌មានសំខាន់ៗសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា និងស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ ព្រមទាំងដើម្បីប្រមូលធាតុចូលនានាសម្រាប់ការផ្តល់ព័ត៌មានឱ្យថ្នាក់ជាតិអំពីថ្នាក់ក្រុង ស្រុក ខណ្ឌ**

កិច្ចដំណើរការរៀបចំប្រព័ន្ធទាំងនេះបានចាប់ផ្តើមនៅក្នុងឆ្នាំ២០១៤។ ប្រព័ន្ធទាំងនេះនឹង (១) រៀបចំឡើងដោយមានការចូលរួមពេញលេញពីក្រុង ស្រុក ខណ្ឌ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌ (២) ប្រើប្រាស់ដើម្បីអនុវត្តដំណើរការគ្រប់គ្រង (ឧទាហរណ៍ ជាប្រព័ន្ធដែលមានទិន្នន័យថ្មីៗ) (៣) ធ្វើវិមជ្ឈការការងារប្រមូលទិន្នន័យដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ (៤) មានភាពបត់បែនដែលអនុញ្ញាតិឱ្យធ្វើការកំណត់សូចនាករ និងទិន្នន័យរស់រវើកប្រកបដោយប្រសិទ្ធភាព (៥) អាចរៀបចំបាននូវរបាយការណ៍ទាន់ពេលវេលានិងងាយស្រួលយល់ ដែលអាចយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង (៦) ពង្រីកវិសាលភាពទិន្នន័យឱ្យបានកាន់ច្រើនឡើងសម្រាប់ការប្រើប្រាស់ដោយសាធារណៈជន និងអង្គការសង្គមស៊ីវិលនានា។ ប្រព័ន្ធស្តីពីត្រួតពិនិត្យវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌនឹងរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងអនុវត្តដោយក្រុង ស្រុក ខណ្ឌ។

**២.៣. គម្រោងថវិកា**

ចំណាយសរុបនៃសមិទ្ធផលនេះ ក្នុងឆ្នាំ២០១៥មានចំនួនប្រមាណ១,០៤លានដុល្លារ ដូចមានបរិយាយលម្អិតដូចខាងក្រោម ៖

**តារាងទី៧៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលទី២**

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សំគាល់ |
|---|---|---|---|---|---|
| ២.១.១. | ការអនុម័តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកចំនួន៥០ | 25.890$ | 0$ | 25.890$ | |
| ២.១.២. | ការពិនិត្យមើលប្រព័ន្ធនិងនីតិវិធីនានាឡើងវិញ ដើម្បីធានាថា តួនាទីរបស់ក្រុមប្រឹក្សា មានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ និងធានាពង្រឹងការរៀបចំលិខិតបទដ្ឋាន ការធ្វើសេចក្ដីសម្រេចចិត្ត និងការត្រួតពិនិត្យមើលពីលើរបស់ក្រុមប្រឹក្សា | 74.700$ | 200.000$ | 274.700$ | [1] |
| ២.២.១. | ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងស្រុកចំនួន២២ស្រុក | 226.888$ | 0$ | 226.888$ | |
| ២.២.២. | ការរៀបចំវេទិកាសាធារណៈ និងសកម្មភាពពាក់ព័ន្ធ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | 5.000$ | 0$ | 5.000$ | |
| ២.២.៣. | ការពិនិត្យ ការកែសម្រួល និងការសាកល្បងនូវយន្តការទទួលពាក្យបណ្ដឹងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | 15.050$ | 0$ | 15.050$ | |
| ២.៣.១. | ការរៀបចំ និងការសាកល្បងប្រព័ន្ធអធិការកិច្ចអំពីការអនុវត្តតាមលិខិតបទដ្ឋាននានានៅទីតាំងយ៉ាងតិច១០កន្លែង | 52.350$ | 0$ | 52.350$ | |
| ២.៤.១. | ការរៀបចំ និងការផ្សព្វផ្សាយសៀវភៅណែនាំ និងនីតិវិធីប្រតិបត្តិការរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស | 135.185$ | 200.000$ | 335.185$ | [1] |
| ២.៤.២. | ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌតាមប្រព័ន្ធកុំព្យូទ័រ ដែលផ្ដល់ព័ត៌មានសំខាន់ៗសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា និងស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ ព្រមទាំងប្រមូលជាធាតុចូលសម្រាប់ផ្ដល់ព័ត៌មានចំពោះថ្នាក់ជាតិអំពីថ្នាក់ក្រុង ស្រុក ខណ្ឌ | 107.800$ | 0$ | 107.800$ | |
| **សរុប** | | **642.863$** | **400.000$** | **1.042.863$** | |

**សម្គាល់ ៖ ផ្សេងៗ** រួមបញ្ចូលការបដិភាគពុំមែនជាថវិកា និងការផ្ដល់មូលនិធិមានកំណត់គោលដៅប្រើប្រាស់ជាក់លាក់ និង [1] ប្រភពមូលនិធិពី EU-SPACE។

# ជំពូកទី៣

# សមិទ្ធផលទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

## ៣.១. សេចក្តីផ្តើម និងចំណុចដៅ

ចំនួនបុគ្គលិក សមាសភាព សមត្ថភាពជំនាញនិងឥរិយាបថរបស់បុគ្គលិក ការលើកទឹកចិត្តដល់បុគ្គលិក និងការផ្តល់សិទ្ធិអំណាចសមស្រប ដែលធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងបុគ្គលិកទាំងនេះប្រកបដោយភាពបត់បែន គឺជាកត្តាដ៏សំខាន់ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្នុងសមិទ្ធផលនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវស្វ័យភាពកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន (ដូចជា ការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការដាក់វិន័យជាដើម) ហើយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីខេត្តនឹងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិកទាំងអស់។ ការអភិវឌ្ឍសមត្ថភាព នឹងផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយការអភិវឌ្ឍសមត្ថភាពនេះរួមបញ្ចូលនូវ (១)ការហ្វឹកហ្វឺន (២)ការផ្តល់ព័ត៌មាន និងសម្ភារៈនានា (៣) ការឆ្លើយតបភ្លាមៗទៅនឹងសំណួរនានាតាមរយៈទូរស័ព្ទនិងអ៊ីម៉ែល (៤)សិក្ខាសាលានិងវេទិកានានា (៥)ការបណ្តុះបណ្តាលជាក់លាក់ទៅតាមការស្នើសុំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើឡើងដោយផ្ទាល់ ឬតាមរយៈអ្នកផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពផ្សេងទៀត (៦)ការបណ្តុះបណ្តាលដែលរៀបចំឡើងដោយថ្នាក់ជាតិអំពីប្រព័ន្ធ ឬលិខិតបទដ្ឋានគតិយុត្តថ្មីៗនានា (៧)ការរៀនសូត្រពីសកម្មភាព និង (៧)ការផ្លាស់ប្តូរបទពិសោធន៍នានា។

សមិទ្ធផលសំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនានាក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។**

តារាងខាងក្រោមនេះ សង្ខេបអំពីចំណុចដៅដែលបានកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តនានាទទួលខុសត្រូវសម្រេចឱ្យបាននូវចំណុចដៅទាំងនេះ និងរៀបចំលទ្ធផលរំពឹងទុក និងសកម្មភាពនានារបស់ខ្លួន ដោយផ្អែកជាមូលដ្ឋានលើចំណុចទាំងនេះ។

**តារាងទី៨ ៖ ចំណុចដៅនានានៃសមិទ្ធផលទី៣**

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយនៃបុគ្គលិករដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជ្រើសរើស តែងតាំង លើកសរសើរ និងដាក់វិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សា | 100% | 100% | 100% |
| ២. ចំនួនភាគរយនៃមន្ត្រីថ្នាក់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានការវាយតម្លៃគុណផល ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន | 50% | 75% | 95% |
| ៣. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលរាជធានី ខេត្ត ជាស្ត្រី | 8,18% | 12,12% | 16,06% |

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ៤. ចំនួនភាគរយនៃនាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត ជាស្ត្រី | 8,20% | 12,13% | 16,07% |
| ៥. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលក្រុងស្រុកខណ្ឌ ជាស្ត្រី | 16,23% | 19,15% | 22,08% |
| ៦. ចំនួនភាគរយនៃប្រធាន អនុប្រធានការិយាល័យ អង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ជាស្ត្រី | 21,03% | 22,36% | 23,68% |
| ៧. ចំនួនភាគរយនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តដែលបានផ្តល់ការគាំទ្រផ្នែកអភិវឌ្ឍសមត្ថភាពទាំង៥ប្រភេទ | 100% | 100% | 100% |
| ៨. ចំនួនភាគរយនៃអភិបាល និងប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុកខណ្ឌដែលបានទទួលវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចប្រចាំឆ្នាំអំពីការបញ្ជាបយេនឌ័រ | 95% | 95% | 95% |
| ៩. ចំនួនភាគរយនៃសមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលយល់ឃើញថា វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំគ្រប់គ្រាន់សម្រាប់ការអនុវត្តមុខងាររបស់ខ្លួន | 20% | 50% | 80% |
| ១០.ចំនួនភាគរយនៃកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលផ្អែកតាមតម្រូវការ | 30% | 40% | 50% |
| ១១.ចំនួនជាមធ្យមនៃដីកាដែលបានដាក់ចេញដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ | 0,5% | 0,7% | 1% |
| ១២.ចំនួនភាគរយនៃសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែលបានកើនឡើង | 10% | 25% | 50% |

### ៣.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ប្រចាំឆ្នាំចំនួន៧ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៣.១. ការធ្វើវិមជ្ឈការ និងការលើកកម្ពស់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៣.១.១. ការរៀបចំ ការផ្សព្វផ្សាយ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ រួមទាំងការវាយតម្លៃគុណផលបុគ្គលិក**

បន្ទាប់ពីការអនុម័តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងសៀវភៅណែនាំនានា សម្រាប់អនុវត្តលក្ខន្តិកៈនេះ។ លិខិត

បទដ្ឋានគតិយុត្តទាំងនេះ នឹងបរិយាយលម្អិតអំពីកិច្ចដំណើរការដាក់លាក់នៃការជ្រើសរើស ការជួល ការគ្រប់គ្រង ការលាឈប់និងការផ្ទេរ វិធានការដាក់វិន័យ ការអភិវឌ្ឍធនធានមនុស្ស ការវាយតម្លៃគុណផលបុគ្គលិក និងមុខងារផ្សេងទៀតក្នុងការគ្រប់គ្រងធនធានមនុស្សដែលនឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការវាយតម្លៃគុណផលដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងគណនេយ្យភាពមូលដ្ឋាន។ នៅត្រឹមដំណាច់ឆ្នាំ២០១៥ កិច្ចដំណើរការទាំងនេះមួយចំនួននឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយយ៉ាងហោចណាស់មានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចំនួនពាក់កណ្តាលត្រូវបានវាយតម្លៃគុណផលជាចំហដោយអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន។ ក្រសួងមុខងារសាធារណៈនឹងដឹកនាំក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ហើយការបណ្តុះបណ្តាលអំពីមុខងារគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការនឹងអនុវត្តតាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៣.១.២. ការ រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធកុំព្យូទ័រ និងតាមរយៈអ៊ិនធឺណែត**

ទិន្នន័យទាំងអស់អំពីបុគ្គលិកនឹងត្រូវបានកត់ត្រា ធ្វើបច្ចុប្បន្នភាព និងថែរក្សាទុកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សនឹងតាមដាននូវព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងធនធានមនុស្សមានដូចជា ការជួល ការលាឈប់ ការបណ្តុះបណ្តាល វិធានការដាក់វិន័យ និងការងារផ្សេងទៀត។ ជាមួយគ្នានេះដែរ ប្រព័ន្ធព័ត៌មាននេះនឹងអនុវត្តតាមគោលការណ៍នានាដូចតទៅ (១)ត្រូវបានរៀបចំដោយមានការចូលរួមពេញលេញពីក្រុង ស្រុក ខណ្ឌ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ក្រុង ស្រុក ខណ្ឌ (២)ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តកិច្ចដំណើរការគ្រប់គ្រងធនធានមនុស្ស (ឧទាហរណ៍ ជាប្រព័ន្ធរស់មួយ) (៣) ផលិតរបាយការណ៍ទាន់ពេលវេលា ងាយស្រួលយល់ និងត្រូវបានប្រើប្រាស់ជាធាតុចូលសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា និង(៤)សម្របសម្រួលការចែករំលែកទិន្នន័យរវាងថ្នាក់រដ្ឋបាលផ្សេងៗគ្នា។ ម៉្យាងទៀត សិក្សាមួយនឹងត្រូវបានធ្វើឡើង ដើម្បីពិនិត្យមើលពីការភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សជាមួយនឹងប្រព័ន្ធគ្រប់គ្រងប្រាក់បៀវត្ស។ ក្រសួងមុខងារសាធារណៈនឹងដឹកនាំការរៀបចំប្រព័ន្ធព័ត៌មាននេះ ចំណែកការបណ្តុះបណ្តាលនឹងត្រូវអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៣.១.៣. ការលើកកម្ពស់ការឆ្លើយតបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី**

នៅក្នុងឆ្នាំ២០១៥ ថ្នាក់ដឹកនាំនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគបញ្ហាយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់ស្ត្រីនៅក្នុងការដឹកនាំ និងពិពិធកម្ម។ វគ្គបណ្តុះបណ្តាលនេះនឹងជួយថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តជាក់ស្តែងនៅក្នុងការងារគ្រប់គ្រងប្រចាំថ្ងៃរបស់ខ្លួននៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅពង្រឹងភាពអង់អាចរបស់ស្ត្រី។ នៅដំណាច់ឆ្នាំ២០១៥ សកម្មភាពដែលត្រូវអនុវត្តដោយថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិម្នាក់ៗនឹង

ត្រូវបានវាយតម្លៃ ដើម្បីវាស់វែងផលប៉ះពាល់ទៅលើការសម្រេចចិត្តផ្នែកគ្រប់គ្រង។ លើសពីនេះទៀត ផ្អែកលើការវិភាគបញ្ហាប្រឈមឬឧបសគ្គនានា និងការពិនិត្យឡើងវិញនូវបទពិសោធន៍នានាកន្លងមក លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីនឹងរៀបចំឱ្យមានការលើកទឹកចិត្ត និងកិច្ចដំណើរការផ្សេងៗទៀតក្នុងការជំរុញឱ្យមានមន្ត្រី បុគ្គលិកជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសនៅថ្នាក់ធ្វើសេចក្តីសម្រេចចិត្ត។ សកម្មភាពទាំងនេះមានភាពចាំបាច់ ដើម្បីសម្រេចបាននូវចំណុចដៅស្តីពីចំនួនភាគរយមន្ត្រី បុគ្គលិកជាស្ត្រីដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផអ៣ទី២។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៣.២. ការរៀបចំ និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគាំទ្រការអភិវឌ្ឍស្ថាប័នផ្អែកតាមតម្រូវការ និងប្រព័ន្ធគាំទ្រការប្រឹក្សាយោបល់សម្រាប់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ៣.២.១. ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំសេចក្តីណែនាំ ល័ក្ខខ័ណ្ឌការងារ និងឯកសារដែលត្រូវការទាំងអស់ សម្រាប់កិច្ចដំណើរការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សផ្នែកគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនឹងកំណត់អ្នកផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពនានា (ពិសេសអង្គការសង្គមស៊ីវិល) ព្រមទាំងរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពដើម្បីពង្រឹងសមត្ថភាពក្រុមប្រឹក្សា។ ផែនការអភិវឌ្ឍន៍សមត្ថភាពត្រូវរៀបចំឡើង ដោយផ្អែកលើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានាដែលកំណត់ដោយថ្នាក់ជាតិ។ ផែនការនេះផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពផ្អែកតម្រូវការរបស់រដ្ឋបាលថ្នាក់ជាតិ ដែលនឹងផ្តល់អន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពតាមរយៈវិធីសាស្ត្រផ្សេងៗ ជាជាងការពឹងផ្អែកភាគច្រើនលើវគ្គបណ្តុះបណ្តាល។ ជាមួយគ្នានេះដែរ ទំនាក់ទំនងរវាងសមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋានរបស់ខ្លួននឹងត្រូវបានពង្រឹងឡើងវិញ ហើយគ្រប់សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពទាំងអស់នឹងធ្វើការបញ្ជ្រាបយេនឌ័រ និងយកចិត្តទុកដាក់ទៅលើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពផ្សេងៗគ្នារបស់បុរស និងស្ត្រី។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីខេត្ត ដោយមានការគាំទ្រ និងការណែនាំតម្រង់ទិសពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុករបស់ផអ៣ទី២ ៖ ៣.៣. ការរៀបចំ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធគាំទ្រការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពផ្អែកតាមតម្រូវការសម្រាប់គណៈអភិបាល និងមន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ៣.៣.១. ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត**

ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំសេចក្តីណែនាំ ល័ក្ខខ័ណ្ឌការងារ និងឯកសារដែលត្រូវការទាំងអស់ សម្រាប់កិច្ចដំណើរការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សផ្នែកគាំទ្រដល់

គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនឹងកំណត់អ្នកផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពនានា (ពិសេស អង្គការសង្គមស៊ីវិល) ព្រមទាំងរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាព ដើម្បីពង្រឹងសមត្ថភាពគណៈអភិបាល និងមន្ត្រី បុគ្គលិក។ ផែនការអភិវឌ្ឍន៍សមត្ថភាពត្រូវបានរៀបចំឡើង ផ្អែកតាម តម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានាដែលកំណត់ដោយថ្នាក់ជាតិ។ ផែនការនេះផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពផ្អែកតម្រូវការរបស់រដ្ឋបាលថ្នាក់ជាតិ ដែលនឹងផ្តល់អន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពតាមរយៈវិធីសាស្ត្រផ្សេងៗ ជាជាងការពឹងផ្អែកភាគច្រើនលើវគ្គបណ្តុះបណ្តាល។ ជាមួយគ្នានេះដែរ កិច្ចដំណើរការ និងសៀវភៅណែនាំ ស្តីពីការអភិវឌ្ឍស្ថាប័ននឹងត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ ហើយគ្រប់សកម្មភាពអភិវឌ្ឍន៍សមត្ថភាពទាំងអស់នឹងធ្វើការបញ្ជ្រាបយេនឌ័រ និងយកចិត្តទុកដាក់ទៅលើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពផ្សេងៗគ្នារបស់បុរស និងស្ត្រី។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយមានការគាំទ្រ និងការណែនាំតម្រង់ទិសពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៣.៤. ការរៀបចំ និងការអនុវត្តផែនការដែលបានគ្រោងនូវធនធានយ៉ាងច្បាស់លាស់មួយសម្រាប់ការរៀបចំបង្កើត និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់ការអភិវឌ្ឍសមត្ថភាពរយៈពេលវែង**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៣.៤.១. ការរៀបចំផែនការ និងគម្រោងថវិកាសម្រាប់វិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ**

សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៥នេះ គឺការសិក្សាលទ្ធភាព និងការសម្រេចអំពីផ្នែកសំខាន់ៗសម្រាប់ការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់មកត្រូវរៀបចំជម្រើស និងអនុសាសន៍នានាសម្រាប់បង្កើតវិទ្យាស្ថាននេះដែលក្នុងនោះរួមមាន ការប៉ាន់ស្មានថវិកា ផែនការបុគ្គលិក កិច្ចប្រតិបត្តិការនិងការថែទាំ និងការរៀបចំកម្មវិធីសិក្សា។ ផែនការនេះនឹងត្រូវបានរៀបចំយ៉ាងលម្អិត ដើម្បីជានាក្នុងការផ្តល់ហិរញ្ញប្បទានដែលត្រូវធ្វើការកៀរគរនៅក្នុងឆ្នាំ២០១៦។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៣.៥. ការសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤ ដើម្បីកែលម្អបរិស្ថានធ្វើការងាររបស់មន្ត្រី បុគ្គលិក**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៣.៥.១. ការសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤**

កិច្ចការសំខាន់ក្នុងឆ្នាំ២០១៥នេះ គឺការកំណត់ និងការរៀបចំរដ្ឋបាលស្រុកសម្រាប់សាងសង់ ការរៀបចំគំនូសប្លង់បច្ចេកទេស និងការរៀបចំឯកសារលទ្ធកម្មនានា ហើយការសាងសង់អគាររដ្ឋបាលសាលាស្រុកទាំង៣៤នឹងត្រូវបានបញ្ចប់ទាំងស្រុក ឬមួយចំនួនអាចស្ថិតក្នុងស្ថានភាពកំពុងដំណើរការ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយរដ្ឋបាលស្រុកដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ។

## ៣.៣. គម្រោងថវិកា

ថវិកាប៉ាន់ស្មានសរុបនៃសមិទ្ធផលនេះសម្រាប់ឆ្នាំ២០១៥ មានចំនួនប្រមាណ១២,៨០លានដុល្លារ ដែលមានបរិយាយលម្អិតនៅតារាងខាងក្រោម។

**តារាងទី៩ ៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលទី៣**

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ៣.១.១ | ការរៀបចំ ការផ្សព្វផ្សាយ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការរួមទាំងការវាយតម្លៃគុណផលបុគ្គលិក | $86,680 | $200,000 | $286,680 | [1] |
| ៣.១.២ | ការរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធកុំព្យូទ័រ និងតាមរយៈអ៊ិនធឺណែត | $58,320 | $0 | $58,320 | |
| ៣.១.៣ | ការលើកកម្ពស់ការឆ្លើយតបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី | $60,000 | $0 | $60,000 | |
| ៣.២.១ | ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត | $514,500 | $200,000 | $714,500 | [1] |
| ៣.៣.១ | ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត | $2,025,199 | $0 | $2,025,199 | |
| ៣.៤.១ | ការរៀបចំផែនការ និងថវិកាសម្រាប់វិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | $0 | $0 | $0 | |
| ៣.៥.១ | ការសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤ | $0 | $9,676,998 | $9,676,998 | [2] |
| **សរុប** | | **$2,744,699** | **$10,076,998** | **$12,821,697** | |

**<u>សម្គាល់</u> ៖ ផ្សេងៗ** រួមមានការបដិភាគពុំមែនថវិកា និងការផ្តល់មូលនិធិដែលបានកំណត់គោលដៅប្រើប្រាស់ជាក់លាក់, [1] គាំទ្រដោយ EU-SPACE និង [2] គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

# ជំពូកទី៤

# សមិទ្ធផលទី៤ស្តីពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ៤.១. សេចក្តីផ្តើម និងចំណុចដៅ

សមិទ្ធផលនេះ មានបំណងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ការងារនេះពាក់ព័ន្ធនឹងការផ្ទេរមុខងារនានាពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីបណ្តាខេត្តឱ្យទៅក្រុងនានា ការលើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ និងការបង្កើតភាពជាដៃគូក្នុងការផ្តល់សេវានិងកិច្ចអភិវឌ្ឍមូលដ្ឋានតាមរយៈអាណត្តិទូទៅ និងការពង្រឹងការផ្តល់សេវារដ្ឋបាលនានា។

សមិទ្ធផលសំខាន់ពាក់ព័ន្ធនឹងការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិអាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាពលរដ្ឋ។**

តារាងខាងក្រោមសង្ខេបអំពីចំណុចដៅនានាដែលបានកំណត់ក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងទទួលខុសត្រូវក្នុងការសម្រេចឱ្យបាននូវចំណុចដៅទាំងនេះ ហើយត្រូវកំណត់លទ្ធផលរំពឹងទុក និងសកម្មភាពនានារបស់ខ្លួនដោយផ្អែកជាមូលដ្ឋានលើចំណុចដៅទាំងនេះ។ ផ្នែកបន្ទាប់មានបរិយាយអំពីលទ្ធផលរំពឹងទុក និងគម្រោងថវិកាសម្រាប់អនុវត្តលទ្ធផលទាំងនេះ។

**តារាងទី១០ ៖ ចំណុចដៅសម្រាប់សមិទ្ធផលទី៤**

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយនៃថវិកាជាតិត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាលទ្ធផលនៃការផ្ទេរមុខងារ | 0,5 | 1 | 3,6 |
| ២. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុកនៃក្រសួង ស្ថាប័នក្នុងវិស័យសំខាន់ៗចំនួន០២ (ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល) | 0 | 2 | 5 |
| ៣. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុករបស់ក្រសួង ស្ថាប័នក្នុងវិស័យផ្សេងៗទៀតយ៉ាងតិចចំនួន០៣[5] | 5 | 50 | 185 |
| ៤. ចំនួនរដ្ឋបាលក្រុង ស្រុកយ៉ាងដែលបានទទួលនូវការផ្ទេរមុខងារនិងធនធានពាក់ព័ន្ធនឹងសេវាទីប្រជុំជន[6] ពីរដ្ឋបាលខេត្ត | 0 | 3 | 10 |

[5] ការិយាល័យដែលមានបុគ្គលិកពី១-៣នាក់។

[6] រួមបញ្ចូលការប្រមូលសំរាម ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរកាកសំណល់ ការគ្រប់គ្រង និងការអភិវឌ្ឍទីផ្សារ និងការអភិវឌ្ឍតំបន់រមណីយដ្ឋានជាដើម និងយ៉ាងហោចណាស់មានសេវា២ផ្សេងទៀត។

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ៥. ការវាយតម្លៃដោយឯករាជ្យមួយនឹងបង្ហាញឱ្យឃើញថា ការផ្តល់សេវាដែលកាន់តែប្រសើរ នៅពេលដែលមុខងារត្រូវបានផ្ទេរវិមជ្ឈការពីថ្នាក់ជាតិមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលខេត្តទៅរដ្ឋបាលក្រុង | | | មាន |
| ៦. ចំនួនភាគរយនៃការកើនឡើងនៃការចំណាយពីមូលនិធិឃុំ សង្កាត់ទៅលើសេវាសង្គម (កើនឡើងចំនួន០៣ដង) | 50 | 150 | 300 |
| ៧. ចំនួនសេវាថ្មី(មិនធ្លាប់អនុវត្តពីមុន)ដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុងស្រុកបានផ្តួចផ្តើមគំនិត និងសាកល្បងក្នុងការផ្តល់សេវា ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក | 2 | 10 | 25 |
| ៨. ចំនួនករណីនៃបទពិសោធន៍ល្អៗអំពីភាពជោគជ័យនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានប្រមូលចងក្រងជាឯកសារ | 2 | 10 | 50 |
| ៩. ចំនួនថវិកាដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តនូវការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជនសម្រាប់កម្រិតថ្នាក់រដ្ឋបាល នីមួយៗ(គិតជាលានដុល្លារ) | 0,5 | 3 | 9 |
| ១០.ចំនួនភាគរយនៃប្រជាពលរដ្ឋដែលពេញចិត្តចំពោះការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដែលជាគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 50 | 50 | 50 |
| ១១.ចំនួនការិយាល័យច្រកចេញចូលតែមួយដែលបានពង្រីកបន្ថែមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់ខេត្ត | 6 | 12 | 18 |
| ១២.យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាម លក្ខណៈច្រកចេញចូលតែមួយ (ក្រៅពីក្រុង ស្រុក ខណ្ឌ ខេត្តដែលមានការិយាល័យច្រកចេញចូលតែមួយ) ត្រូវបានរៀបចំឡើងនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅទូទាំងប្រទេស | | | |
| ១៣.ចំនួនភាគរយនៃការកើនឡើងនូវសេវារដ្ឋបាលផ្សេងៗដែលផ្តល់តាមរយៈការិយាល័យច្រកចេញចូលតែមួយ | 4 | 8 | 10 |
| ១៤.ចំនួនភាគរយកើនឡើងនៃប្រជាពលរដ្ឋដែលបានមកទទួលសេវារដ្ឋបាលតាមរយៈច្រកចេញចូលតែមួយ | 5 | 10 | 15 |

## ៤.២. គម្រោងថវិកា

ផ្អែកតាមផអ៣ទី២ សមិទ្ធផលទី៤ស្តីពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយផ្អែកលើលទ្ធផលទាំងនេះ ត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ប្រចាំឆ្នាំចំនួន៨ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៤.១. រដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្តួចផ្តើមកាន់តែច្រើនក្នុងការអនុវត្តមុខងារជាជម្រើសនានាដែលស្ថិតនៅក្រោមអាណត្តិទូទៅរបស់ខ្លួន**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.១.១. ការពិនិត្យ ការកែសម្រួល និងការផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងមុខងារជាជម្រើស និងសេវាសង្គម**

កិច្ចការសំខាន់គឺត្រូវរៀបចំសេចក្ដីណែនាំនានាដែលរៀបរាប់អំពីភាពជាដៃគូ និងការរៀបចំនានាសម្រាប់ការចែករំលែកការចំណាយ និងការផ្ដួចផ្ដើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តអនុក្រឹត្យនានាស្ដីពីមុខងារជាជម្រើស។ ជាមួយគ្នានេះដែរ មុខងារជាក់លាក់នានាដែលត្រូវផ្ទេរនឹងត្រូវបានកំណត់ច្បាស់លាស់។ ចំណុចទាំងនេះនឹងបញ្ចូលទៅក្នុងវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីលើកកម្ពស់ការផ្ដួចផ្ដើមនានា ក៏ដូចជាការរៀបចំយុទ្ធនាការពង្រឹងចំណេះដឹងជាសាធារណៈ ដើម្បីផ្ដល់នូវសារ និងព័ត៌មានច្បាស់លាស់និងមានសង្គតិភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបង្កើតនូវគំនិតផ្ដួចផ្ដើមទាំងនេះ។ម្យ៉ាងទៀត លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងត្រូវធ្វើការពិនិត្យ និងកែសម្រួលដើម្បីផ្ដល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យយកចិត្តទុកដាក់ លើការផ្ដល់សេវាសង្គមឱ្យបានកាន់តែច្រើន ជាជាងការផ្ដោតតែទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.១.២. ការរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រ និងកម្មវិធី ដើម្បីលើកកម្ពស់ការផ្ដួចផ្ដើម និងការសិក្សារៀនសូត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ក្នុងលទ្ធផលរំពឹងទុកនេះ គឺការពិនិត្យមើលបទពិសោធន៍ពីបណ្ដាលប្រទេសនានាក្នុងការលើកកម្ពស់ការផ្ដួចផ្ដើមគំនិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយលទ្ធផលនៃការពិនិត្យមើលនេះនឹងត្រូវយកមកពិនិត្យ ពិចារណាក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រ (មានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចដំណើរការនៃការរៀបចំផែនការសកម្មភាពស្ដីពីការងារគណនេយ្យភាពសង្គម) ដែលបរិយាយអំពីការលើកទឹកចិត្តនានា បែបផែនគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្ដួចផ្ដើមគំនិតផ្សេងៗទៀត។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.១.៣. ការពិនិត្យមើលឡើងវិញ និងការអនុវត្តមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រមូលនិធិដោយ ដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យមើលពីលទ្ធភាពក្នុងការធ្វើសមាហរណកម្មក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល**

ដៃគូអភិវឌ្ឍន៍នានាដែលគាំទ្រគម្រោង ឬកម្មវិធីដាច់ដោយឡែកផ្សេងៗនៅថ្នាក់ក្រោមជាតិមានដូចជា UNICEF គាំទ្រសេវាសង្គម, UNCDF គាំទ្រការប្រែប្រួលអាកាសធាតុ, WB គាំទ្រការបែបចែកដីសម្រាប់សង្គមកិច្ច និងកិច្ចអភិវឌ្ឍ, UNDP គាំទ្រការការប្រែប្រួលលអាកាសធាតុ, UNPFA គាំទ្រការងារប្រជាពលរដ្ឋ សុខភាពបន្តពូជ និងយេនឌ័រ, UN-WOMEN គាំទ្រការលើកកម្ពស់អនុសញ្ញា ស៊ី-ដ និងការប្រឆាំងអំពើហិង្សាចំពោះស្ត្រី និងគម្រោងផ្សេងទៀត។ នៅចុងឆ្នាំ២០១៥ ការសិក្សាវាយតម្លៃមួយនឹងត្រូវធ្វើឡើង ដើម្បីពិនិត្យមើលពីលទ្ធភាពក្នុងការធ្វើសមាហរណកម្មគម្រោងកម្មវិធីទាំងនេះទៅក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល។ ក្រៅពីនេះ ក៏នឹងមានរៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានាអំពីការគាំទ្រ

ផ្នែកហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃ ផអ៣ទី២ ៖ ៤.២. មុខងារជាក់លាក់ និងសមស្របត្រូវបានផ្ទេរពីក្រសួង ស្ថាប័នឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ជាទូទៅ មានវិធីសាស្ត្រខុសគ្នាចំនួន៣ដែលនឹងត្រូវប្រើប្រាស់ ដើម្បីលើកកម្ពស់ការផ្ទេរមុខងារពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ (១) ក្រសួង ស្ថាប័ននានាដែលបានបញ្ចប់ការពិនិត្យមើលឡើងវិញនូវមុខងារក្នុងឆ្នាំ២០១៤នឹងត្រូវបន្តកិច្ចដំណើរការនេះជាបន្តទៀត, (២) ការផ្ទេរការិយាល័យជំនាញមួយចំនួនឱ្យទៅរដ្ឋបាលក្រុង ស្រុកដូចជា ការិយាល័យមានបុគ្គលិកចំនួន១-៣នាក់ (ការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច។ល។) និង(៣) ការផ្ទេរការិយាល័យជំនាញមួយចំនួនទៀតឱ្យទៅរដ្ឋបាលក្រុង ស្រុក (ដូចជា ការិយាល័យអប់រំពាក់ព័ន្ធនឹងការអប់រំកម្រិតបឋមសិក្សា)។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.២.១. ការអនុវត្ត និងការវាយតម្លៃនូវការសាកល្បងអំពីការផ្ទេរមុខងារពីក្រសួងទាំង៦ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងផអ៣ទី១**

ផ្អែកលើការពិនិត្យមើលឡើងវិញនូវមុខងារដែលបានបញ្ចប់ក្នុងឆ្នាំ២០១៤ ដោយក្រសួងចំនួន៦ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាននឹងបន្តរៀបចំផែនការសម្រាប់ការសាកល្បងការផ្ទេរមុខងារក្នុងឆ្នាំ២០១៥។ ក្រសួង ស្ថាប័នទាំងនេះនឹងធ្វើការរៀបចំនានា ដើម្បីផ្ទេរជាបណ្តោះអាសន្ននូវបុគ្គលិក និងធនធានហិរញ្ញវត្ថុក៏ដូចជា ការពិនិត្យ និងកែសម្រួលនូវលិខិតបទដ្ឋាននានា និងការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកពាក់ព័ន្ធនានាដែលទទួលខុសត្រូវក្នុងការអនុវត្ត ការគាំទ្រ និងការតាមដានកិច្ចដំណើរការនៃការអនុវត្តសាកល្បង។ នៅចុងឆ្នាំ២០១៥ ការវាយតម្លៃអំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តសាកល្បងស្តីពីការផ្ទេរមុខងារនេះ នឹងត្រូវបានរៀបចំឡើង ដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាសម្រាប់ការអនុវត្តមុខងារទាំងនេះចាប់ពីឆ្នាំ២០១៦។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារ។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.២.២. ការផ្ទេរការិយាល័យជំនាញថ្នាក់ក្រុង ស្រុកចំនួន៣យ៉ាងតិចទៅឱ្យរដ្ឋបាលក្រុង ស្រុក**

កិច្ចការនេះពាក់ព័ន្ធនឹងការពិភាក្សាកម្រិតគោលនយោបាយ ដើម្បីពិចារណាក្នុងការផ្ទេរពេញលេញនូវការិយាល័យជំនាញមួយចំនួននៅថ្នាក់ស្រុក (ឧទាហរណ៍ការិយាល័យមានបុគ្គលិក១-៣នាក់) ទៅឱ្យរដ្ឋបាលក្រុង ស្រុក។ សម្រាប់ការពិភាក្សាកម្រិតគោលនយោបាយនេះ តម្រូវឱ្យមានការរៀបចំនូវឯកសារគោលនយោបាយដែលបរិយាយអំពីសនិទានភាព និងទំនាក់ទំនងថ្មីរវាងក្រសួង ស្ថាប័នជំនាញ



th

នានាជាមួយមន្ទីរ អង្គភាពជំនាញរបស់ខ្លួន និងរដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធនឹងអាណត្តិនានារបស់ស្ថាប័នជំនាញ។ នៅចុងឆ្នាំ២០១៥ នឹងត្រូវធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរយ៉ាងហោចណាស់នូវការិយាល័យចំនួន៣ឱ្យទៅរដ្ឋបាលក្រុង ស្រុក។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារ។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.២.៣. ការធ្វើសេចក្តីសម្រេចក្នុងការផ្ទេរមុខងារសំខាន់ៗចំនួន៣ពីការិយាល័យជំនាញថ្នាក់ក្រុង ស្រុកទៅឱ្យរដ្ឋបាលក្រុង ស្រុក (រួមមាន បឋមសិក្សា មណ្ឌលសុខភាព និងមុខងារមួយផ្សេងទៀត)**

កិច្ចការសំខាន់ក្នុងលទ្ធផលរំពឹងទុកនេះ គឺការរៀបចំឯកសារគោលនយោបាយមួយដែលរៀបរាប់អំពីសនិទានភាព ចំណុចខ្លាំង ចំណុចខ្សោយ និងបទពិសោធន៍ពីបណ្តាប្រទេសនានាក្នុងការធ្វើវិមជ្ឈការការអប់រំកម្រិតបឋមសិក្សា ការងារសុខភាព និងមុខងារសំខាន់មួយទៀត។ ក្នុងការរៀបចំឯកសារគោលនយោបាយនេះ ត្រូវធ្វើការវិភាគអំពីលទ្ធភាពក្នុងការផ្ទេរការិយាល័យជំនាញនានាដែលអនុវត្តមុខងារទាំងនេះឱ្យទៅរដ្ឋបាលក្រុង ស្រុក និងដើម្បីលើកកម្ពស់ការចូលរួមរបស់អ្នកនយោបាយនានា តាមរយៈកិច្ចពិភាក្សាដែលនឹងរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប។ ផ្អែកលើបទពិសោធន៍នៃការអនុវត្តសកម្មភាពទាំងនេះ ត្រូវពិនិត្យមើលឡើងវិញ និងកែសម្រួលនូវកិច្ចដំណើរការនៃការផ្ទេរមុខងារ ដែលបានអនុវត្តកន្លងមក។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ។

**លទ្ធផលរំពឹងទុកនៃ ផអ៣ទី២ ៖ ៤.៣. សេវាទីប្រជុំជនត្រូវបានផ្ទេរពីរដ្ឋបាលខេត្តឲ្យទៅដល់រដ្ឋបាលក្រុង**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.៣.១. ការអនុវត្តនូវការផ្ទេរមុខងារនៃការគ្រប់គ្រងកាកសំណល់រឹងឱ្យក្រុងចំនួន២៦ និងការរៀបចំនូវការសាកល្បងអំពីការផ្ទេរមុខងារសេវាទីប្រជុំចំនួន២បន្ថែមទៀតឱ្យទៅក្រុងនានា**

ការសម្រេចចិត្តរបស់ក្រសួងបរិស្ថាន ក្នុងការផ្ទេរមុខងារនៃការគ្រប់គ្រងសំណល់រឹងឱ្យទៅក្រុងនឹងត្រូវធ្វើឡើងតាមរយៈអនុក្រឹត្យ និងលិខិតបទដ្ឋានចាំចាច់នានា ដើម្បីអនុវត្តនៅក្នុងឆ្នាំ២០១៥នេះ។ លើសពីនេះទៀត និងដោយផ្អែកលើលទ្ធផលនៃការវិភាគនូវសំណាកដែលបានកំណត់ក្នុងបណ្តាខេត្តក្រុងនានា មានសេវាទីប្រជុំជនចំនួន២បន្ថែមទៀតត្រូវបានកំណត់ និងពិនិត្យមើលពីលទ្ធភាពក្នុងការផ្ទេរឱ្យទៅក្រុង ព្រមទាំងធ្វើការសាកល្បងក្នុងឆ្នាំ២០១៥ក្នុងគោលបំណងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងនានាដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារនេះ។

**លទ្ធផលរំពឹងទុកនៃ ផអ៣ទី២ ៖ ៤.៤. ការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយត្រូវបានពង្រឹង និងពង្រីក**

**តារាងទី១១ ៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលទី៤**

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ៤.១.១ | ការពិនិត្យ ការកែសម្រួល និងការផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងមុខងារជាជម្រើស និងសេវាសង្គម | $0 | $200,000 | $200,000 | [1] |
| ៤.១.២ | ការរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រ និងកម្មវិធីដើម្បីលើកកម្ពស់ការផ្តួចផ្តើម និងការសិក្សារៀនសូត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | $0 | $0 | $0 | |
| ៤.១.៣ | ការពិនិត្យមើលឡើងវិញ និងការអនុវត្តមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យមើលពីលទ្ធភាពក្នុងការធ្វើសមាហរណកម្មក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល | $0 | $4,553,518 | $4,553,518 | [2] |
| ៤.២.១ | ការអនុវត្ត និងការវាយតម្លៃនូវការសាកល្បងអំពីការផ្ទេរមុខងារពីក្រសួងទាំង៦ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងអំឡុងជអ៣ទី១ | $430,000 | $366,600 | $796,600 | [3] |
| ៤.២.២ | ការផ្ទេរការិយាល័យជំនាញថ្នាក់ក្រុង ស្រុកចំនួន៣យ៉ាងតិចឱ្យទៅរដ្ឋបាលក្រុង ស្រុក | $0 | $0 | $0 | |
| ៤.២.៣ | ការធ្វើសេចក្តីសម្រេចក្នុងការផ្ទេរមុខងារសំខាន់ៗចំនួន៣ពីការិយាល័យជំនាញថ្នាក់ក្រុង ស្រុកឱ្យទៅរដ្ឋបាលក្រុង ស្រុក (រួមមាន បឋមសិក្សា មណ្ឌលសុខភាព និងមុខងារមួយផ្សេងទៀត) | $15,000 | $0 | $15,000 | |
| ៤.៣.១ | ការអនុវត្តនូវការផ្ទេរមុខងារនៃការគ្រប់គ្រងកាកសំណល់រឹងឱ្យក្រុងចំនួន២៦ និងការរៀបចំនូវការសាកល្បងអំពីការផ្ទេរ នូវមុខងារសេវាទីប្រជុំចំនួន២បន្ថែមទៀតទៅឱ្យក្រុងនានា | $25,000 | $625,000 | $650,000 | [4] |
| ៤.៤.១ | ការពង្រីកការិយាល័យច្រកចេញចូលតែមួយនៅក្នុងស្រុក ខណ្ឌគោលដៅថ្មីចំនួន៥ និងការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការពង្រីកយន្តការការិយាល័យច្រកចេញចូលតែមួយនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | $65,400 | $0 | $0 | |
| ៤.៥.១ | ការសម្របសម្រួលក្នុងការចុះកិច្ចព្រមព្រៀងនានាស្តីពីភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់ | $0 | $0 | $0 | |

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.៤.១. ការពង្រីកការិយាល័យច្រកចេញចូលតែមួយនៅក្នុងស្រុក ខណ្ឌ គោលដៅថ្មីចំនួន៥ និងការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការពង្រីកយន្តការការិយាល័យច្រកចេញចូលតែមួយនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការិយាល័យច្រកចេញចូលតែមួយចំនួន៣៧ដែលមានស្រាប់ នឹងទទួលបានការគាំទ្រជាបន្តទៀត ហើយសកម្មភាពនានាដើម្បីលើកកម្ពស់ការពង្រីកវិសាលភាព និងសេវានឹងត្រូវបានអនុវត្ត។ ការិយាល័យច្រកចេញចូលតែមួយថ្មីចំនួន៥នឹងបង្កើតនៅក្រុង ស្រុក ខណ្ឌចំនួន៥។ ជាមួយគ្នានេះដែរ សកម្មភាពនៃការសិក្សាមួយនឹងត្រូវបានរៀបចំឡើង ដើម្បីកំណត់ពីលទ្ធភាពនៃសេវាបន្ថែមដែលអាចផ្ទេរពីក្រសួង ស្ថាប័ននានាឱ្យទៅដល់ក្រុង ស្រុក ខណ្ឌ និងសេវាថ្មីៗដែលអាចអនុវត្តបានដោយរាជធានី ខេត្ត និងឃុំ សង្កាត់។ ក្របខ័ណ្ឌគតិយុត្តនានាសម្រាប់សេវារដ្ឋបាលទាំងនេះនឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅក្នុងខេត្តចំនួន២។ លទ្ធផលរំពឹងទុកនេះនឹងត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធនឹងការងារនេះ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៤.៥. ការផ្តល់សេវាក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងវិស័យឯកជនត្រូវបានរៀបចំ និងអនុវត្ត**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៤.៥.១. ការសម្របសម្រួលក្នុងការចុះកិច្ចព្រមព្រៀងនានាស្តីពីភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈដែលមានទឹកប្រាក់ចំនួនប្រមាណ០,៥លានដុល្លារ**

យន្តការ និងទម្រង់បែបបទគំរូនឹងត្រូវរៀបចំឡើង ដើម្បីសម្របសម្រួលដល់ការរៀបចំភាពជាដៃគូនេះដែលជាផ្នែកមួយនៃលទ្ធផលរំពឹងទុក៤.១ សម្រាប់ការរៀបចំកិច្ចពិភាក្សានៅថ្នាក់ជាតិដូចជាការពិភាក្សាជាមួយ អង្គការសង្គមស៊ីវិល សភាពាណិជ្ជកម្ម។ល។ សំណាកនៃភាពជាដៃគូនានាដែលមានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជននឹងបានត្រូវកំណត់ ដើម្បីធ្វើការសិក្សាពីបែបផែនការនៃការអនុវត្តនាពេលបច្ចុប្បន្ននិងវិធានការនានាដែលត្រូវអនុវត្ត ក្នុងគោលបំណងលើកកម្ពស់កិច្ចសហការ និងពង្រីកការអនុវត្តនូវភាពជោគជ័យនេះ។ យន្តការ និងទម្រង់បែបបទគំរូនានានឹងត្រូវរៀបចំបញ្ចប់ និងផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលនានា ហើយបន្ទាប់មកនឹងបន្តអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងតំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

### ៤.៣. គម្រោងថវិកា

ថវិកាប៉ាន់ស្មានសរុបនៃសមិទ្ធផលនេះសម្រាប់ឆ្នាំ២០១៥ មានចំនួនប្រមាណ៦,២៨លានដុល្លារ ដែលមានបរិយាយលម្អិតនៅតារាងខាងក្រោម។

| លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|
| សេវាសាធារណៈដែលមានទឹកប្រាក់ចំនួនប្រមាណ ០,៥លានដុល្លារ | | | | |
| **សរុប** | **$535,400** | **$5,745,118** | **$6,280,518** | |

**សម្គាល់ ៖ ផ្សេងៗ** រួមមានការបដិភាគពុំមែនជាថវិកា និងការផ្តល់មូលនិធិដែលបានកំណត់គោលដៅប្រើប្រាស់ជាក់លាក់, [1] គាំទ្រដោយ EU-SPACE, [2] គាំទ្រដោយ UNICEF, UNFPA, UNDP-Scale up, UNCDF-LGCC2, WB-LASED, ADB-TS-PRSDP, UN-Women និង WB-CTPP, [3] គាំទ្រដោយ EU-SPACE, UNCDF-LDDPHS និង [4] គាំទ្រដោយ ADB-RWS O&M និង WB-RSDSD TA។

# ជំពូកទី៥

# សមិទ្ធផលទី៥ស្តីពីវិមជ្ឈការហិរញ្ញវត្ថុ

## ៥.១. សេចក្តីផ្តើម និងចំណុចដៅ

ក្នុងឆ្នាំ២០១៥នេះ យន្តការនៃផ្ទេរហិរញ្ញវត្ថុនឹងត្រូវបានរៀបចំ និងអនុវត្ត ដើម្បីជួយរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវប្រភពធនធានហិរញ្ញវត្ថុនានាដែលមានដូចជា មូលនិធិក្រុង ស្រុក មូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ យន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចការសំខាន់ក្នុងសមិទ្ធផលនេះគឺការពិនិត្យមើលឡើងវិញនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាត់បន្ថយភាពយឺតយ៉ាវក្នុងការផ្ទេរមូលនិធិ និងជួយឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួនមានលក្ខណៈប្រាកដប្រជា ព្រមទាំងមានគោលដៅច្បាស់លាស់ ដែលដឹកនាំ និងត្រួតពិនិត្យមើលដោយក្រុមប្រឹក្សា។

សមិទ្ធផលសំខាន់ពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុដែលត្រូវសម្រេចឱ្យបានគឺ **ធនធានហិរញ្ញវត្ថុត្រូវបានគ្រោងរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុងស្រុកក្នុងការអនុវត្តនូវអាណត្តិរបស់ខ្លួន។**

តារាងខាងក្រោមបង្ហាញសង្ខេបអំពីចំណុចដៅសំខាន់ៗ ដែលត្រូវសម្រេចឲ្យបានក្នុងក្របខ័ណ្ឌផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ត្រូវចូលរួមសម្រេចឲ្យបាននូវចំណុចដៅទាំងនេះ តាមរយៈការរៀបចំលទ្ធផលរំពឹងទុក និងសកម្មភាពនានា ស្របតាមចំណុចដៅដែលបានកំណត់ទាំងនេះ។ លទ្ធផលរំពឹងទុកនានា រួមទាំងតម្រូវការថវិកានៅក្នុងសមិទ្ធផលទី៥នេះមានបរិយាយនៅផ្នែកបន្ទាប់។

**តារាងទី១២ ៖ ចំណុចដៅសម្រាប់សមិទ្ធផលទី៥**

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយនៃធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តថវិការដ្ឋ | 0,5 | 0,5 | 0,5 |
| ២ .ចំនួនភាគរយនៃចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ធៀបនឹងចំណូលសរុបរបស់ខ្លួន | 0 | 2,5 | 10 |
| ៣. ចំនួនធនធានដែលសហគមន៍មូលដ្ឋានបានចូលរួមសម្រាប់គម្រោងឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក (គិតជាលានដុល្លារ) | 0,2 | 0,5 | 2 |
| ៤. យន្តការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌ ដើម្បីធានាដល់ការអនុវត្តមុខងារដែលបានផ្ទេរ | គ្មាន | គ្មាន | គ្មាន |
| ៥. ចំនួនធនធានដែលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគ (គិតជាលានដុល្លារ) | 0 | 3 | 3 |
| ៦. ចំនួនភាគរយនៃការកាត់បន្ថយនូវភាពយឺតយ៉ាវនៃការផ្ទេរធនធានពីថ្នាក់ | 10 | 25 | 50 |



HL

| ចំណុចដៅ និងសូចនាករ | 2015 | 2016 | 2017 |
|---|---|---|---|
| ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោម | | | |
| ៧. ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានប្រើប្រាស់ប្រព័ន្ធកសាងផែនការថ្មី | 100 | 100 | 100 |

**៥.២. លទ្ធផលរំពឹងទុក**

ផ្អែកតាមផអ៣ទី២ សមិទ្ធផលទី៥ស្តីពីវិមជ្ឈការហិរញ្ញវត្ថុមានលទ្ធផលរំពឹងទុកចំនួន៥ ហើយផ្អែកលើលទ្ធផលទាំងនេះ ត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ប្រចាំឆ្នាំចំនួន១២ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកនៃ ផអ៣ទី២ ៖ ៥.១. ធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុកមានចំនួនយ៉ាងតិច០,៥%ធៀបនឹងចំណូលចរន្តនៃថវិការដ្ឋ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.១.១. ការវិភាជមូលនិធិពីចំណូលចរន្តនៃថវិការដ្ឋចំនួន០,៥%សម្រាប់មូលនិធិក្រុង ស្រុកសមាសភាគអភិវឌ្ឍន៍**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការពិនិត្យ និងកែសម្រួលរូបមន្តវិភាជន៍មូលនិធិក្រុង ស្រុក ដើម្បីធានាថា ក្រុង ស្រុកមានមូលនិធិសមស្របសម្រាប់សមាសភាគអភិវឌ្ឍន៍។ ផ្អែកលើស្ថានភាពចំណូលបច្ចុប្បន្ន និងផ្អែកលើអត្រាកំណើននៃចំនួនមូលនិធិក្រុង ស្រុក ក្នុងរយៈពេលបីឆ្នាំខាងមុខ ពោលគឺនៅឆ្នាំ២០១៩នឹងអាចសម្រេចបាននូវចំណុចដៅ០,៥% សម្រាប់សមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក។ ដូច្នេះ ចាំបាច់ត្រូវស្វែងរកការគាំទ្រមូលនិធិពីខាងក្រៅបន្ថែម ដែលចំនួនមូលនិធិបន្ថែមនេះនឹងត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ក្នុងអំឡុងឆ្នាំ២០១៦-២០១៨។ ដើម្បីធានាការសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ចាប់ពីត្រីមាសទី១ឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការពិគ្រោះពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីធានាថា ដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពលនឹងគាំទ្រមូលនិធិក្រុង ស្រុកបានទាន់ពេលវេលាក្នុងអំឡុងពេលនេះ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយមានការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.២. ការរៀបចំ និងការអនុវត្តនូវយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌដើម្បីគាំទ្រដល់ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.២.១. ការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការសាកល្បងក្នុងការផ្ទេរមុខងារពីក្រសួងចំនួន៦ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងដំណាក់កាលផអ៣ទី១**

បន្ទាប់ពីការិយាល័យជំនាញនិងមុខងារត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលក្រុង ស្រុក យន្តការផ្ទេរដែលបានប្រើប្រាស់ក្នុងការផ្ទេរនឹងត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញដោយរួមបញ្ចូលទាំងការពិនិត្យ

និងការកែសម្រួលនូវរូបមន្តដែលមានបច្ចុប្បន្នប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។ ការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌចាប់ផ្តើមបានកាន់តែឆាប់កាន់តែល្អ ដើម្បីជៀសវាងការពន្យារពេលក្នុងការផ្ទេរមុខងារជាក់ស្តែង។ ក្នុងអំឡុងពេលអនុវត្តន៍ យន្តការនេះនឹងត្រូវធ្វើការតាមដាន និងវាយតម្លៃយ៉ាងទៀងទាត់ និងដោយយកចិត្តទុកដាក់។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការគាំទ្រពីក្រសួង ស្ថាប័ននានាដែលអនុវត្តកិច្ចដំណើរការផ្ទេរមុខងារនានា។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៣. ចក្ខុវិស័យ និងចំណុចដៅរយៈពេលមធ្យមមួយសម្រាប់ចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់**

**លទ្ធផលរំពឹងទុកនៃ ផ.ស.៥ ៖ ៥.៣.១. ការរៀបចំ និងការអនុម័តយុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុដែលកំណត់អំពីចក្ខុវិស័យរយៈពេលមធ្យមមួយ និងកំណត់អំពីចំណុចដៅនានាពាក់ព័ន្ធនឹងចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

យុទ្ធសាស្ត្រដែលត្រូវរៀបចំនេះ នឹងធានាឱ្យកិច្ចដំណើរការវិមជ្ឈការហិរញ្ញវត្ថុបោះជំហានទៅមុខក្នុងលក្ខណៈជាប្រព័ន្ធ តាមលំដាប់លំដោយ និងមានយុទ្ធសាស្ត្រច្បាស់លាស់។ យុទ្ធសាស្ត្រស្តីពីវិមជ្ឈការនឹងត្រូវរៀបចំស្របតាមស្មារតីនៃច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានគោលបំណងធ្វើឱ្យរដ្ឋបាលក្រុង ស្រុកក្លាយជាស្ថាប័នដ៏សំខាន់មួយក្នុងការផ្តល់សេវានៅមូលដ្ឋាន។ ម៉្យាងទៀត យុទ្ធសាស្ត្រនេះនឹងធានាឱ្យមានចំណុចដៅជាក់លាក់សម្រាប់ចំណូល (តាមប្រភេទចំណូលនីមួយៗ) ផ្អែកលើការពិនិត្យមើលឡើងវិញនូវកិច្ចប្រតិបត្តិការ និងភាពស័ក្តិសិទ្ធិនៃប្រតិបត្តិការ និងផ្អែកលើចំណាយសម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ម៉្យាងវិញទៀត យុទ្ធសាស្ត្រនេះក៏បង្ហាញឱ្យឃើញពីភាពខុសគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាទីប្រជុំជន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាតំបន់ជនបទ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើសក្តានុពលនៃប្រភពចំណូល និងតម្រូវការចំណាយរបស់រដ្ឋបាលទាំងនោះ។ ចំណុចដៅទាំងនេះ នឹងមានសារសំខាន់សម្រាប់ការកែសម្រួលរូបមន្តវិភាជន៍ធនធានមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានធនធានមូលនិធិប្រកបដោយសមធម៌សម្រាប់ការផ្តល់សេវា។ ជាមួយគ្នានេះដែរ យុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុនឹងកំណត់អំពីប្រភេទចំណូល និងចំណាយដែលនឹងត្រូវអនុវត្តសាកល្បង និងកិច្ចអន្តរាគមន៍ចាំបាច់នានាសម្រាប់ការអនុវត្តសាកល្បងនេះ និងកំណត់អំពីការងារដែលត្រូវធ្វើការវិភាគបន្ថែមអំពីតម្រូវការនៃការរៀបចំប្រព័ន្ធ និងអំពីតម្រូវការពេលវេលាដើម្បីសម្រេចបាននូវចំណុចដៅទាំងនោះ។ ការអនុវត្តយុទ្ធសាស្ត្រនេះផ្អែកលើមូលដ្ឋាននៃការវិភាគអំពីផ្នែកហិរញ្ញវត្ថុ និងការពិនិត្យឡើងវិញនូវផ្នែកប្រតិបត្តិការ និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការកំណត់អំពីតម្រូវការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងពាក់ព័ន្ធនឹងចំនួនមន្ត្រី និងរចនាសម្ព័ន្ធរដ្ឋបាលដែលចាំបាច់ ដើម្បីផ្តល់សេវាទាំងនោះប្រកបដោយប្រសិទ្ធភាព។ ក្នុងការរៀបចំចំណាយសម្រាប់ការផ្តល់សេវា គោលបំណងសំខាន់

គឺយកចំណាយពាក់ព័ន្ធនានាចេញពីធនធានថវិកាសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលទូទៅ ទៅបញ្ចូលក្នុងចំណាយនានាសម្រាប់ការផ្តល់សេវា។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការគាំទ្រជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៣.២. ការរៀបចំឧបករណ៍ស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ**

ក្នុងការរៀបចំឧបករណ៍នេះ នឹងត្រូវជ្រើសរើសទីប្រឹក្សារយៈពេលខ្លីមួយរូប ដើម្បីរៀបចំយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងឧបករណ៍នានាសម្រាប់ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឯកសារទាំងនេះនឹងត្រូវអនុម័តនៅក្នុងឆ្នាំ២០១៥ ហើយការបណ្តុះបណ្តាលនឹងចាប់ដំណើរការនៅដើមឆ្នាំ២០១៦ (ស្របគ្នាជាមួយនឹងប្រព័ន្ធកសាងផែនការដែលបានកែសម្រួល ដូចមានរៀបរាប់នៅក្នុងលទ្ធផលរំពឹងទុក៥.៨.១ខាងក្រោម)។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តរួមគ្នាដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៤. ការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៤.១. ការរៀបចំ និងអនុវត្តសាកល្បងអំពីការប្រមូលចំណូលមូលដ្ឋាន និងចូលរួមបដិភាគដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៦**

នៅក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបញ្ចប់ការវិភាគនានា ដើម្បីរៀបចំយន្តការសាកល្បង (ដោយរួមបញ្ចូលទាំងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ) អំពីការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងត្រូវដាក់ឲ្យអនុវត្តនៅឆ្នាំ២០១៦។ ដើម្បីសម្រេចការងារនេះ តម្រូវឱ្យមានការធ្វើសេចក្តីសម្រេចចិត្តសមស្របមួយអំពីប្រភពចំណូលផ្ទាល់នានា សម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ កិច្ចដំណើរការក្នុងការប្រមូលចំណូលនៃការចូលរួមបដិភាគដោយស្ម័គ្រចិត្តនឹងត្រូវធ្វើការពិនិត្យមើលឡើងវិញ ក៏ដូចជាការរៀបចំនីតិវិធីនានាសម្រាប់ការបង្កើន ឬការធ្វើឱ្យប្រសើរឡើងនូវការប្រមូលចំណូលនេះ ដោយមានការចូលរួមប្រឹក្សាយោបល់ពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ពិសេសទាក់ទងនឹងការកំណត់ថ្លៃប្រើប្រាស់ និងការចូលរួមបដិភាគរបស់សហគមន៍។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៥. យន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៥.១. ការបង្កើត និងការអនុវត្តនូវយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦**

ក្នុងឆ្នាំ២០១៥ ទាមទារឱ្យមានការធ្វើសេចក្តីសម្រេចចិត្តជាយុទ្ធសាស្ត្រ និងការរៀបចំលិខិតបទដ្ឋាន និងឧបករណ៍នានាពាក់ព័ន្ធនឹងយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យយន្តការនេះអាចចាប់ផ្តើមអនុវត្តពីខែមករាឆ្នាំ២០១៦។ ជាពិសេស ត្រូវយកចិត្តទុកដាក់លើការ

រៀបចំ និងការអនុម័ត (១)លិខិតបទដ្ឋាននានាសម្រាប់ការបង្កើតយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្របខ័ណ្ឌហិរញ្ញប្បទាន, (២)លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់លក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលលើកកម្ពស់ការអនុវត្តតាមលិខិតបទដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាពិសេស ការលើកកម្ពស់អភិបាលកិច្ចល្អមូលដ្ឋាន, (៣)នីតិវិធីនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំនិងដាក់សំណើគម្រោងវិនិយោគនានាដើម្បីស្នើសុំមូលនិធិ នីតិវិធីសម្រាប់ការពិនិត្យ ការសិក្សាវាយតម្លៃ និងការអនុម័តសំណើគម្រោងវិនិយោគ និងនីវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តសំណើម្រោងវិនិយោគទាំងនោះ, (៤)សេចក្តីសម្រេចនានាស្តីពីការបង្កើតស្ថាប័ន និងអង្គភាពសំខាន់ៗដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និង (៥) ការកៀរគរធនធានក្នុងស្រុក និងពីប្រភពខាងក្រៅសម្រាប់អនុវត្តយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៦. ការវិភាជន៍ថវិកាសម្រាប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានពិនិត្យ និងកែសម្រួល**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៦.១. ការរៀបចំ និងការអនុម័តលិខិតបទដ្ឋានស្តីពីការកែសម្រួលកិច្ចដំណើរការវិភាជថវិការាជធានី ខេត្តដើម្បីអនុវត្តក្នុងឆ្នាំ២០១៦**

កិច្ចការសំខាន់ៗក្នុងលទ្ធផលនេះពាក់ព័ន្ធនឹង (១) ការសិក្សាពីលទ្ធផលនៃការផ្លាស់ប្តូរក្រៅផ្លូវការលើរូបមន្តវិភាជន៍ថវិកាបច្ចុប្បន្ន (២) ការពិនិត្យឡើងវិញលើសក្តានុពលនៃប្រភពចំណូល និងសមត្ថភាពប្រមូលចំណូល ព្រមទាំងតម្រូវការចំណាយនានារបស់រដ្ឋបាលរាជធានី ខេត្ត (៣) ការកំណត់លក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍សម្រាប់រៀបចំបង្កើតរូបមន្តវិភាជន៍ថវិកាឱ្យទៅរដ្ឋបាលរាជធានី ខេត្ត រួមបញ្ចូលទាំងការលើកទឹកចិត្តនានាក្នុងការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលរំពឹងនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៧. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង**

**លទ្ធផលរំពឹងទុកនៃផ.ស.ថ ៖ ការកែសម្រួល និងវិសោធនកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើការវិភាគអំពីភាពមានកម្រិតនៃចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្អែកលើលទ្ធផលនៃការចុះសិក្សានៅមូលដ្ឋាន ការជួបពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបញ្ហាប្រឈមនានានៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីនៃការអនុវត្តថវិកាដែលមាននាពេលបច្ចុប្បន្ន លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមហាផ្ទៃនឹងសហការគ្នា ដើម្បីពិនិត្យ ពិភាក្សា និងរៀបចំសំណើនានាសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃប្រព័ន្ធ និងនីតិវិធីទាំងនេះ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះការផ្តល់សេវាសង្គម។ សំណើ និងអនុសាសន៍នានាពាក់ព័ន្ធនឹងការកែ

សម្រួលនឹងត្រូវរៀបចំ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានា បន្ទាប់មកនឹងត្រូវយកមកពិចារណាក្នុងការកែសម្រួលសេចក្តីណែនាំនានាសម្រាប់ដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៦។

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៧.២ ៖ ការពង្រឹង និងការរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវប្រព័ន្ធរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានទិន្នន័យក្នុងបណ្តាញអ៊ិនធឺណែតសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តនានា**

កិច្ចការសំខាន់ក្នុងលទ្ធផលនេះ គឺការពិនិត្យ និងការកែសម្រួលនូវប្រព័ន្ធ ឬសៀវភៅណែនាំនានាស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ ប្រព័ន្ធទិន្នន័យមូលដ្ឋានមួយនឹងត្រូវបានរៀបចំ ដើម្បីកត់ត្រានូវព័ត៌មានសំខាន់ៗស្តីពីចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកនៃផអ៣ទី២ ៖ ៥.៨. ប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលឱ្យស្របតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យមើលពីលើ ព្រមទាំងពង្រឹងខ្សែគណនេយ្យភាពនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងខ្សែគណនេយ្យភាពរវាងមន្ទីរ អង្គភាព និងការិយាល័យជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**លទ្ធផលរំពឹងទុកនៃ ផ.ស.ថ ៖ ៥.៨.១. ការរៀបចំ និងការសាកល្បងនូវប្រព័ន្ធកសាងផែនការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំសេចក្តីណែនាំបច្ចេកទេស និងសម្ភារៈនានា ដើម្បីពង្រីកក្នុងឆ្នាំ២០១៦**

គោលនយោបាយស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តនៅឆ្នាំ២០១៤។ ដោយសារកិច្ចដំណើរនៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំនីមួយៗ ដូច្នេះ ការកែសម្រួលសេចក្តីណែនាំ និងឧបករណ៍នានាស្តីពីការកសាងផែនការ និងការរៀបចំវគ្គបណ្តុះបណ្តាលនានាក្នុងឆ្នាំ២០១៥នេះ ពុំអាចជួយរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យរៀបចំ និងអនុម័តផែនការរបស់ខ្លួនសម្រាប់ឆ្នាំថវិកា២០១៦បានឡើយ។ អាស្រ័យហេតុនេះ រាល់ការពិនិត្យ និងការកែសម្រួលសេចក្តីណែនាំ និងនីតិវិធីនានាត្រូវអនុវត្តឱ្យបានចប់សព្វគ្រប់ក្នុងឆ្នាំ២០១៥ ចំណែកការបណ្តុះបណ្តាលនឹងត្រូវធ្វើឡើងនៅដើមឆ្នាំ២០១៦ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកសាងផែនការ និងរៀបចំថវិការបស់ខ្លួនសម្រាប់ឆ្នាំ២០១៧។ ការពិនិត្យ និងការកែសម្រួលសេចក្តីណែនាំនិងនីតិវិធីនានាស្តីពីការកសាងផែនការ និងការរៀបចំថវិកាទទួលបានការរួមចំណែកគាំទ្រដោយអង្គការយូនីសេហ្វ ហើយនឹងផ្តោតការយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាព និងបញ្ចូលនូវបញ្ហាពាក់ព័ន្ធនានាដូចជា ការងារគណនេយ្យភាពសង្គម ការបំរែបំរួលអាកាសធាតុ និងការផ្តល់ សេវាសង្គម។ លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិនានា។ ក្រសួងផែនការនឹងរៀបចំនូវលិខិតបទដ្ឋាន និងឯកសារបណ្តុះបណ្តាលនានា ចំណែកមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនឹងទទួលខុសត្រូវសម្របសម្រួលក្នុងការប្រើប្រាស់នូវប្រព័ន្ធដែលបានកែសម្រួលនេះ។

## ៥.៣. គម្រោងថវិកា

ថវិកាសរុបសម្រាប់សមិទ្ធផលនេះក្នុងឆ្នាំ២០១៥ មានចំនួនប្រមាណ១,៣៤លានដុល្លារ ដូចមានបរិយាយតាមលទ្ធផលរំពឹងទុកដូចខាងក្រោម ៖

**តារាងទី១៣៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលទី៥**

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ៥.១.១ | ការវិភាជមូលនិធិពីចំណូលចរន្តនៃថវិការដ្ឋចំនួន ០,៥%សម្រាប់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ | $0 | $0 | $0 | |
| ៥.២.១ | ការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការសាកល្បងក្នុងការផ្ទេរមុខងារពីក្រសួងចំនួន៦ ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងដំណាក់កាលផអ៣ទី១ | $0 | $73,640 | $73,640 | [1] |
| ៥.៣.១ | ការរៀបចំ និងការអនុម័តនូវយុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុដែលកំណត់អំពីចក្ខុវិស័យរយៈពេលមធ្យមមួយ និងកំណត់អំពីចំណុចដៅនានាពាក់ព័ន្ធនឹងចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | $0 | $0 | $0 | |
| ៥.៣.២ | ការរៀបចំឧបករណ៍នានាស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ | $52,500 | $0 | $52,500 | |
| ៥.៤.១ | ការរៀបចំ និងអនុវត្តសាកល្បងអំពីការប្រមូលចំណូលមូលដ្ឋាន និងការចូលរួមបដិភាគដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៦ | $0 | $85,592 | $85,592 | [1] |
| ៥.៥.១ | ការបង្កើត និងការអនុវត្តនូវយន្តការផ្តល់ហិរញ្ញ ប្បទាននិវិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦ | $0 | $256,870 | $256,870 | [1] |
| ៥.៦.១ | ការរៀបចំ និងអនុម័តលិខិតបទដ្ឋានស្តីពីការកែសម្រួលកិច្ចដំណើរការវិភាជថវិការាជធានី ខេត្តដើម្បីអនុវត្តក្នុងឆ្នាំ ២០១៦ | $0 | $49,620 | $49,620 | [1] |
| ៥.៧.១ | ការកែសម្រួល និងវិសោធនកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើការវិភាគអំពីភាពមានកម្រិតនៃចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | $96,033 | $400,000 | $496,033 | [2] |
| ៥.៧.២ | ការពង្រឹង និងការរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវប្រព័ន្ធរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាល | $10,230 | $0 | $10,230 | |

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| | ថ្នាក់ក្រោមជាតិ ដោយមានទិន្នន័យក្នុងបណ្ដាញអ៊ិនធឺណែតសម្រាប់អ្នកធ្វើសេចក្ដីសម្រេចចិត្តនានា | | | | |
| ៥.៨.១ | ការរៀបចំ និងការសាកល្បងនូវប្រព័ន្ធកសាងផែនការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំសេចក្ដីណែនាំបច្ចេកទេស និងសម្ភារៈនានា ដើម្បីពង្រីកក្នុងឆ្នាំ២០១៦ | $320,854 | $0 | $320,854 | |
| ៥.៨.២ | ការពិនិត្យ និងការកែសម្រួលឧបករណ៍នានាស្ដីពីការកសាងផែនការតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីគាំទ្រដំណើរការកសាងផែនការ | $0 | $0 | $0 | |
| **សរុប** | | **$479,617** | **$865,722** | **$1,345,339** | |

**<u>សម្គាល់</u> ៖ ផ្សេងៗ** រួមមានការបដិភាគពុំមែនជាថវិកា និងការផ្ដល់មូលនិធិដែលមានកំណត់គោលដៅប្រើប្រាស់ជាក់លាក់, [1] គាំទ្រដោយ ADB/DPSFM និង [2] គាំទ្រដោយ ADB/PPTA។



H

# ឧបសម្ព័ន្ធនានា

**ឧបសម្ព័ន្ធទី១**

# សិក្ខាសាលាជាតិ

## ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥

## របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី៤-៥ ខែកុម្ភៈ ឆ្នាំ២០១៥**

---

## សុន្ទរកថាបិទ

**ឯកឧត្តម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

- **ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីសមាជិក សមាជិកានៃ គ.ជ.អ.ប**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីសមាជិក សមាជិកាអង្គសិក្ខាសាលាជាទីមេត្រី!**

ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមពិធីបិទសិក្ខាសាលាស្តីពី**ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប** ដែលបានប្រព្រឹត្តទៅអស់រយៈពេលជិតពីរថ្ងៃកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានខិតខំប្រឹងប្រែងចូលរួមចំណែកក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥នេះ បើទោះបីជាក្នុងរយៈពេលជាង៦ខែកន្លងមកនេះ យើងទាំងអស់គ្នាមានការមមាញឹកបំផុតក្នុងការរៀបចំតាក់ តែងផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ ដើម្បីបន្តជំរុញកិច្ចដំណើរការកំណែទម្រង់របស់យើងឈានឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅ និងគោលបំណងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក៏ដោយ។ ពាក់ព័ន្ធនឹងកិច្ច

ការនេះ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានា ដែលបានបន្តគាំទ្រទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះអង្គការសង្គមស៊ីវិលនានា ដែលបានចូលរួមចំណែកនិងផ្តល់ការគាំទ្រនៅក្នុងកិច្ចការសំខាន់ៗមួយចំនួននៃកិច្ចដំណើរការកំណែទម្រង់ជាទូទៅ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ដោយសារយើងបោះជំហានពីដំណាក់កាលទី១ទៅដំណាក់កាលទី២នៃផអ៣ អាស្រ័យហេតុនេះ វាជាឱកាសដ៏មានសារៈសំខាន់មួយ សម្រាប់យើងក្នុងការគិតគូរពិចារណាអំពីទិសដៅរយៈពេលមធ្យមថ្មីមួយ ដើម្បីធានាដល់ការឈានឆ្ពោះទៅសម្រេចនូវកិច្ចការចាំបាច់ថ្មីៗបន្ថែម ទៀតនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់យើង។ នៅក្នុងឱកាសបិទសិក្ខាសាលានេះ ខ្ញុំមានបំណងលើកឡើងពីបញ្ហាប្រឈមដ៏សំខាន់មួយ មុននឹងគូសបញ្ជាក់អំពីកិច្ចការជាអាទិភាពមួយចំនួនដែលយើងចាំបាច់ត្រូវយកចិត្តទុកដាក់សម្រេចឱ្យបាននៅក្នុងផអ៣ដំណាក់កាលទី២នេះ។

ប្រសិនបើយើងប្រមើលមើលថយក្រោយឡើងវិញ យើងត្រូវទទួលស្គាល់ថាមានកិច្ចការជាច្រើនដែលយើងសម្រេចបាននៅក្នុងផអ៣ដំណាក់កាលទី១ ក៏ប៉ុន្តែយើងក៏យល់ថា ប្រសិនយើងបានប្រើប្រាស់ឱ្យបានពេញលេញនូវកាលានុវត្តភាពដែលបានផ្តល់ឱ្យយើង និងមានការចូលរួមយ៉ាងសកម្មថែមទៀតពីក្រសួង ស្ថាប័ននានា នោះយើងពិតជាអាចសម្រេចបាននូវកិច្ចការល្អប្រសើរជាងនេះទៅទៀត។

ផអ៣ដំណាក់កាលទី១មានគោលដៅជាសំខាន់ គឺការរៀបចំដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋាននានា ដែលឆ្លុះបញ្ចាំងនៅក្នុងទស្សនៈវិស័យនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីបង្កើតឡើងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិថ្មីមួយប្រកបដោយគណនេយ្យភាព និងដែលត្រូវបានផ្តល់ស្វ័យភាពជាបណ្តើរៗក្នុងការផ្តួចផ្តើមគំនិតថ្មីសម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងការលើកកម្ពស់ការផ្តល់សេវាចាំបាច់នានាជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននីមួយៗ។ នោះគឺជាដំណាក់កាលដែលតម្រូវឱ្យមានការធ្វើសេចក្តីសម្រេចចិត្តនានា និងការរៀបចំមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៃកំណែទម្រង់។ យ៉ាងណាមិញ បើយើងក្រឡេកមើលទៅក្រោយវិញ យើងពិតជាមើលឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានបង្កើតឡើងជាថ្មីអស់រយៈពេលប្រមាណ៤ឆ្នាំកន្លងមកនេះ ពិតជាពុំទាន់មានមុខងារជាក់លាក់ណាមួយដែលត្រូវបានផ្ទេរពីក្រសួង ស្ថាប័ននានានៅឡើយ។ ពាក់ព័ន្ធនឹងបញ្ហានេះ ប្រសិនបើយើងពិនិត្យមើលទៅលើក្រសួងបរិស្ថានដែលបានធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័សក្នុងការផ្ទេរមុខងារស្តីពីការគ្រប់គ្រង និងប្រមូលសំរាមទៅឱ្យថ្នាក់ក្រុង ស្រុក យើងពិតជាយល់ឃើញថា អ្វីដែលធ្វើឱ្យយើងមានការយឺតយ៉ាវនៅក្នុងដំណាក់កាលទី១នៃផអ៣ គឺពាក់ព័ន្ធមួយចំណែកទៅលើការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រសួង ស្ថាប័ននានា។ អាស្រ័យហេតុនេះ នៅក្នុងដំណាក់កាលបន្ទាប់នេះ ក្នុងនាមរាជរដ្ឋាភិបាល និង គ.ជ.អ.ប ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវប្រធានស្ថាប័នទាំងឡាយចាត់ទុកថា វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកិច្ចការស្នូលរបស់ក្រសួង ស្ថាប័ននីមួយៗ ពោលគឺមិនមែនជាកិច្ចការដោយឡែកមួយ ដែលត្រូវដោះស្រាយដោយមន្ត្រីបច្ចេកទេសមួយក្រុមរបស់ក្រសួង

ស្ថាប័ននីមួយៗនោះឡើយ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

បច្ចុប្បន្ននេះ យើងកំពុងឈានចូលដំណាក់កាលទី២នៃផអ៣ អាស្រ័យហេតុនេះ ខ្ញុំសូមឆ្លៀតឱកាសនេះ គូសបញ្ជាក់អំពីលទ្ធផលរំពឹងទុកមួយចំនួន ដែលបានពិភាក្សាស្រុះស្រួលគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងចុងក្រោយត្រូវបានសម្រេចដោយ គ.ជ.អ.ប ដែលគ្រោងនឹងសម្រេចឱ្យបានក្នុងរយៈពេល៣ឆ្នាំខាងមុខនេះដែលមានជាអាទិ៍៖

**<u>ទីមួយ</u> ៖** មុខងារសមស្របនានា ចាំបាច់ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក។ ជាការពិតណាស់ យើងមិនអាចពិចារណាតែទៅលើការផ្ទេរមុខងារដែលគ្មានថវិកា ឬដែលមានថវិកាបន្តិចបន្តួចនោះឡើយ។ ផ្អែកតាមច្បាប់រៀបចំអង្គការបានកំណត់ថា មុខងារដែលត្រូវផ្ទេរ គឺជា***មុខងារដែលបម្រើនិងផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ និងដែលរំពឹងថា នឹងមានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ។*** នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលបែបវិមជ្ឈការ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិទទួលខុសត្រូវក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយ ស្តង់ដារ ការតាមដាន ព្រមទាំងការកៀរគរ និងបែងចែកធនធាននានា។ ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការគ្រប់គ្រងចាត់ចែងដោយផ្ទាល់នូវការផ្តល់សេវាសាធារណៈនានា។ ដើម្បីអនុវត្តនូវប្រព័ន្ធនេះបាន រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្តល់នូវសិទ្ធិក្នុងការគ្រប់គ្រងមន្ត្រី និងហិរញ្ញវត្ថុដែលមានភាពចាំបាច់ក្នុងការផ្តល់សេវាឱ្យដល់ដៃអ្នកដែលត្រូវទទួលបានសេវាទាំងនោះ។ ប្រសិនបើស្តង់ដារនៃការផ្តល់សេវាត្រូវបានបំពេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ នោះថ្នាក់ជាតិក៏មិនចាំបាច់ត្រូវគ្រប់គ្រងចាត់ចែងយ៉ាងល្អិតល្អន់នោះឡើយ។

ជារួម យើងទាំងអស់គ្នាត្រូវយល់ថា មានហេតុផលជាច្រើនដែលតម្រូវឱ្យយើងធ្វើការសម្រេចចិត្តក្នុងការធ្វើវិមជ្ឈការនូវមុខងារនានា។ អ្វីដែលសំខាន់បំផុតគឺការបង្វិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាឱ្យទៅកៀកជិតជាមួយប្រជាពលរដ្ឋ។ ប្រព័ន្ធអភិបាលកិច្ចនេះ នឹងជួយលើកកម្ពស់ដល់ការបង្កើតគំនិតផ្តួចផ្តើមថ្មីៗ។ វានឹងផ្តល់នូវផ្លូវកាត់ដ៏ខ្លីមួយនៃគណនេយ្យភាព ពីព្រោះថាប្រសិនបើមានប្រជាពលរដ្ឋម្នាក់មិនពេញចិត្តនឹងការផ្តល់សេវាណាមួយ នោះគាត់អាចទៅជួបសមាជិកក្រុមប្រឹក្សារបស់ខ្លួនតែម្តង។

មកទល់បច្ចុប្បន្ននេះ ក្រសួងមួយចំនួននៅមានភាពស្ទាក់ស្ទើរ ឬពុំទាន់មានបំណងក្នុងការផ្ទេរអំណាចរបស់ខ្លួននៅឡើយដែលខ្ញុំយល់ថា នេះគឺជាការគិតគូរដ៏ចាំបាច់ត្រូវពិចារណាឡើងវិញ។ ជាការពិតណាស់ វិមជ្ឈការមិនមែនមានន័យថា ជាការកាត់បន្ថយនូវអំណាចនោះឡើយ ប៉ុន្តែគ្រាន់តែជាការកំណត់ឡើងវិញថាតើអំណាចនោះត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?។ ខ្ញុំអាចលើកយកការអប់រំកម្រិតបឋមសិក្សាធ្វើជាឧទាហរណ៍មួយ។ ក្រសួងអប់រំ យុវជន និងកីឡានៅតែត្រូវទទួលខុសត្រូវលើការអប់រំដដែល វាគ្រាន់តែទៅអនាគត ក្រសួងនឹងមិនផ្តល់ការអប់រំកម្រិតបឋមសិក្សានេះដោយផ្ទាល់ តាមរយៈមន្ទីរ អង្គភាពខ្សែបណ្តោយដ៏វែងរបស់ខ្លួននោះឡើយ។ មានន័យថា ក្រសួងនឹងទទួលខុសត្រូវក្នុងការ

កំណត់ថាតើត្រូវរៀបចំ និងដាក់ចេញនូវគោលនយោបាយយ៉ាងដូចម្តេច ដើម្បីធ្វើឱ្យកុមារទាំងអស់ទទួលបានការអប់រំសិក្សា? តើក្មេងត្រូវរៀនអំពីអ្វី? តើគ្រូបង្រៀនត្រូវមានគុណភាពកម្រិតណា និងត្រូវប្រតិបត្តិយ៉ាងដូចម្តេច?។ ផ្អែកតាមការរៀបចំគោលនយោបាយ ក្រសួងទទួលខុសត្រូវក្នុងការកំណត់អំពីចក្ខុវិស័យនៃ វិស័យអប់រំ ដើម្បីធានាថា កុមាររបស់យើងនឹងក្លាយជាប្រជាពលរដ្ឋល្អ និងមានវិជ្ជាជីវៈចាំបាច់សម្រាប់ទីផ្សារពលកម្មដ៏ទំនើបមួយ។ ជាមួយគ្នានេះដែរ ក្រសួងក៏ត្រូវទទួលខុសត្រូវក្នុងការធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែបំពេញនូវស្តង់ដារនៃវិស័យអប់រំរបស់ជាតិផងដែរ។ ហេតុដូច្នេះវាមានន័យថា អំណាចវានៅតែស្ថិតនៅក្រសួង ក៏ប៉ុន្តែវាគ្រាន់តែត្រូវបានអនុវត្តក្នុងបែបផែនថ្មីមួយតែប៉ុណ្ណោះ។ បែបផែនអនុវត្តនេះ មិនមែនជាគំនិតផ្តួចផ្តើមថ្មីសម្រាប់កម្ពុជាយើងនោះឡើយ វាជាបែបផែនដែលធ្លាប់បានអនុវត្តនៅក្នុងប្រទេសកម្ពុជាយើងក្នុងទសវត្សឆ្នាំ៨០កន្លងមក ហើយប្រទេសនានាក្នុងតំបន់ និងក្រៅតំបន់ក៏បានប្រើប្រាស់បែបផែននៃការធ្វើវិមជ្ឈការក្នុងវិស័យអប់រំនេះប្រកបដោយជោគជ័យរួចមកហើយផងដែរ។

**<u>ទីពីរ</u>** ៖ ធនធានចាំបាច់នានាត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអ្វីដែលសំខាន់បំផុត គឺការបង្កលក្ខណៈឱ្យក្រុង ស្រុកមានលទ្ធភាពចាប់ផ្តើមអនុវត្តនូវគម្រោងអភិវឌ្ឍមូលដ្ឋានមួយចំនួន។ ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមស្នើអង្គសិក្ខាសាលាទាំងមូល យកចិត្តទុកដាក់ទៅលើអនុសាសន៍នានារបស់ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធាន គ.ជ.អ.ប ដែលបានសង្កត់ធ្ងន់ទៅលើវិមជ្ឈការហិរញ្ញវត្ថុនៅក្នុងការថ្លែងសុន្ទរកថាបើកនាព្រឹកម្សិលមិញនេះ។

**<u>ទីបី</u>** ៖ ប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាពរបស់យើងចាំបាច់ត្រូវបន្តពង្រឹងឱ្យបានសមស្រប ដើម្បីធានាដល់ការអនុវត្តស្របតាមច្បាប់ ក៏ប៉ុន្តែមិនត្រូវធ្វើឱ្យនីតិវិធីទាំងនេះក្លាយទៅជាការគ្រប់គ្រងចាត់ចែងពីលើយ៉ាងលម្អិតពេកនោះឡើយ។ យើងពិតជាត្រូវធានាឱ្យបាននូវការការពារសុវត្ថិភាព ក៏ប៉ុន្តែការរៀបចំប្រព័ន្ធនេះក៏មិនត្រូវធ្វើឱ្យមានការយឺតយ៉ាវក្នុងការផ្ទេរថវិកា ដែលធ្វើឱ្យបាត់បង់នូវតម្លៃថវិកានោះឡើយ។ ឆ្នាំ២០១៥នេះ យើងចាំបាច់ត្រូវធ្វើការពិនិត្យឡើងវិញនូវនីតិវិធីនានាស្តីពីការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាមិនឱ្យមានការអូសបន្លាយដូចដែលធ្លាប់បានកើតឡើងនាឆ្នាំកន្លងមក។ ដោយឡែក អង្គភាពពាក់ព័ន្ធនានារបស់ក្រសួងមហាផ្ទៃ ត្រូវធ្វើការវាយតម្លៃអំពីការបំពេញការងាររបស់មន្ត្រីទាំងឡាយដែលត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋាននានា ហើយក្នុងករណីរកឃើញថា មានមន្ត្រីដែលមិនអនុវត្តតាមច្បាប់នោះត្រូវមានវិធានការដាក់ចេញជាបន្ទាន់។ ជាមួយគ្នានេះដែរ ប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាពនេះ ក៏ចាំបាច់ត្រូវរៀបចំឡើងដោយដាក់បញ្ចូលទាំងប្រព័ន្ធផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលបំពេញការងារបានល្អ និងការដាក់ពិន័យដល់មន្ត្រីដែលមានកំហុសឆ្គងផងដែរ។

**<u>ទីបួន</u>** ៖ ការផ្តល់នូវស្វ័យភាពដល់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមន្ត្រី បុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ គឺជាកត្តាដ៏ចាំបាច់ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពរបស់មន្ត្រី បុគ្គលិកទាំងនោះចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញការងាររបស់ខ្លួន ព្រមទាំងបង្កើននូវការទទួលខុសត្រូវ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ពាក់ព័ន្ធនឹងកិច្ចការនេះ ក្នុងអំឡុងពេលនៃផអ៣ទី១ រាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មអំណាចជាបណ្តើរៗឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងចាត់ចែងមន្ត្រី បុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំជាសេចក្តីព្រាងរួចរាល់ហើយ ប៉ុន្តែអាស្រ័យដោយមានការកែសម្រួលគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ធ្វើឱ្យការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអូសបន្លាយមក ល់ពេលនេះ។ អាស្រ័យហេតុនេះ ក្នុងផអ៣ទី២នេះ ខ្ញុំសូមស្នើក្រសួងមុខងារសាធារណៈសហការជាមួយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិបន្តជំរុញកិច្ចការនេះ ដោយចាត់ទុកការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាទិភាពដ៏ចម្បងនៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ខ្លួន។

ទន្ទឹមគ្នានេះ ក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបន្តជំរុញ និងពង្រឹងការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀតដោយផ្តល់អាទិភាពជាសំខាន់ទៅលើការរៀបចំបង្កើតនូវមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅតាមរាជធានី ខេត្ត និងការរៀបចំបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្របសម្រួលការកៀរគរការគាំទ្រ និងការពង្រឹងប្រសិទ្ធភាពក្នុងការផ្តល់អន្តរាគមន៍អភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**<u>ទីប្រាំ</u>** ៖ នៅចុងឆ្នាំ២០១៤កន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់ការពិនិត្យឡើងវិញ និងការកែសម្រួលនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ខ្ញុំសូមស្នើក្រសួងផែនការសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាឱ្យប្រព័ន្ធនេះមានលក្ខណៈសមស្របតាមដំណើរការផ្ទេរមុខងារ និងធនធានទៅតាមប្រភេទផ្សេងៗគ្នារវាងតំបន់ទីប្រជុំជននិងតំបន់ជនបទ ការដាក់បញ្ចូលនូវការងារគណនេយ្យភាពសង្គម ការប្រែប្រួលអាកាសធាតុ និងសេវាសង្គមនានាដោយមានការយកចិត្តទុកដាក់ដល់ក្រុមជនងាយរងគ្រោះទាំងឡាយ ជាពិសេសស្ត្រី កុមារ ជនពិការ និងជនជាតិដើមភាគតិច ព្រមទាំងកំណត់នូវប្រតិទិនយ៉ាងច្បាស់លាស់ សម្រាប់ការកសាងផែនការដែលមានលក្ខណៈអាចសម្របសម្រួលគ្នាបានរវាងថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

មកទល់បច្ចុប្បន្ននេះ ស្ថានភាពជាទូទៅទាំងក្នុងវិស័យនយោបាយនិងក្នុងវិស័យសេដ្ឋកិច្ច និង

សង្គមនៅក្នុងប្រទេសកម្ពុជាមានការវិវត្តយ៉ាងលឿនទៅមុខគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះដែរ តាមរយៈបច្ចេកវិទ្យាព័ត៌មាន ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សបានបង្កលក្ខណៈឱ្យប្រជាពលរដ្ឋមានលទ្ធភាពកាន់តែច្រើនឡើងក្នុងការទទួលបាននូវព័ត៌មាននានា។ តាមរយៈព័ត៌មានទាំងនោះ ប្រជាពលរដ្ឋមានការយល់ដឹងអំពីអ្វីដែលកំពុងតែប្រព្រឹត្តទៅ និងកើតមានឡើងនៅទូទាំងប្រទេស។

ក្នុងនាមជាមន្ត្រីសាធារណៈ យើងមានភារកិច្ចចាំបាច់ត្រូវបម្រើប្រជាពលរដ្ឋ និងធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានជំនឿជឿជាក់លើការបំពេញការងារ ដោយការទទួលខុសត្រូវរបស់យើងម្នាក់ៗ។ យើងមិនអាចគ្រាន់តែនិយាយអំពីការអភិវឌ្ឍន៍ អំពីការធ្វើវិមជ្ឈការ អំពីការផ្ទេរអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការលើកកម្ពស់ការផ្តល់សេវានិងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនោះឡើយ។ យើងចាំបាច់ត្រូវតែមានវិធានការក្នុងការរៀបចំ និងអនុវត្តសកម្មភាពទាំងនោះ ដោយមានការសម្រេចចិត្តយ៉ាងច្បាស់លាស់។ រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ថាប័នដែលមានការប្រាស្រ័យទាក់ទងជាប្រចាំជាមួយប្រជាពលរដ្ឋ។ រដ្ឋបាលទាំងនេះ គឺជាកន្លែងទំនាក់ទំនងដំបូងគេបំផុតរវាងប្រជាជន និងរដ្ឋ។ ក្នុងន័យនេះ បើសិនជាយើងពុំបានពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬពុំបានផ្ទេរមុខងារ និងធនធាន ព្រមទាំងផ្តល់សិទ្ធិសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គ្រប់គ្រង និងចាត់ចែងមុខងារ និងធនធានទាំងនោះទេ នោះយើងប្រាកដជាពុំអាចឆ្លើយតបបានទៅនឹងតម្រូវការដែលជាការរំពឹងទុករបស់ប្រជាពលរដ្ឋបានឡើយ។

ក្នុងន័យនេះ ការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុត ដើម្បីធានាដល់ការសម្រេចបាននូវចំណុចដៅ និងលទ្ធផលរំពឹងទុកនានាដែលបានកំណត់នៅក្នុងផអ៣ទី២។ នេះជាឱកាសដ៏មានសារៈសំខាន់មួយក្នុងការរៀបចំនូវកម្មវិធី ដោយផ្អែកលើមូលដ្ឋាននៃសមិទ្ធផលដែលយើងបានបង្កើតឡើងនាពេលកន្លងមក និងផ្អែកលើយុទ្ធសាស្ត្រថ្មីៗដែលធានាដល់ការដោះស្រាយ និងឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងប្រកបដោយប្រសិទ្ធភាព។

ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមគូសបញ្ជាក់អះអាងសារជាថ្មីថា រាជរដ្ឋាភិបាលមានការតាំងចិត្តផ្នែកនយោបាយយ៉ាងច្បាស់លាស់អំពីការអនុវត្តកំណែទម្រង់នេះ ហើយឆន្ទៈនេះត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់លាស់តាមរយៈសមិទ្ធផលដ៏ធំធេងនានា ដែលយើងទាំងអស់គប្បីទទួលស្គាល់។ ទោះបីយ៉ាងនេះក្តី យើងនៅតែនៅត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាក្នុងរយៈពេលមធ្យមមួយដែលនៅតែជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការឈានឆ្ពោះទៅសម្រេចគោលបំណងចុងក្រោយនៃកំណែទម្រង់។

ជំនួសមុខឲ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបាន និងកំពុងបន្តផ្តល់ការគាំទ្រប្រកបដោយភាពយោគយល់ដល់កិច្ចដំណើរការកំណែទម្រង់នៅកម្ពុជា ហើយខ្ញុំសូមធានាអះអាងថា ជំនួយទាំងនេះនឹងត្រូវបានប្រើប្រាស់ប្រកបដោយគណនេយ្យភាព និងតម្លាភាព។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់យោបល់របស់តំណាងអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នៅក្នុងសិក្ខាសាលានេះ។ យើងនឹងខិតខំបន្តពង្រីក

ពូនជ្រំនូវភាពជាដៃគូប្រកបដោយភាពស្ថាបនា និងស្មោះស្ម័គ្រជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីរួមគ្នាឆ្លើយតបឱ្យបានពេញលេញទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួម និងផ្តល់មតិយោបល់ក្នុងសិក្ខាសាលារយៈពេលពីរថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងរៀបចំ និងសម្របសម្រួលរាល់កិច្ចការដែលធ្វើឲ្យសិក្ខាសាលាទទួលបានលទ្ធផលជាផ្លែផ្កាតាមការគ្រោងទុក។

ជាទីបញ្ចប់ ជាមួយសមិទ្ធផលដែលសម្រេចបានក្នុងសិក្ខាសាលានេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និង**សូមប្រកាសបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**

**សូមអរគុណ**

# ឧបសម្ព័ន្ធទី២ ៖ ជំនួយបច្ចេកទេស ផែនការបុគ្គលិក

## តារាងទី១៤ ៖ ផែនការបុគ្គលិកនៃជអ៣ទី២តាមថ្នាក់រដ្ឋបាល និងថវិកា

| ថ្នាក់រដ្ឋបាល និងស្ថាប័ន | ទីប្រឹក្សា | | បុគ្គលិកកិច្ចសន្យា | | សរុប | |
|---|---|---|---|---|---|---|
| | ចំនួន | ប្រាក់ខែ | ចំនួន | ប្រាក់ខែ | ចំនួន | ប្រាក់ខែ |
| 1. **ថ្នាក់ជាតិ** | 29 | $1,158,892 | 97 | $595,380 | 126 | $1,754,272 |
| 1.1. លេខាធិការដ្ឋាន គ.ជ.អ.ប | 20 | $944,428 | 74 | $455,280 | 94 | $1,399,708 |
| 1.1.1. ទីប្រឹក្សាអន្តរជាតិ | 3 | $536,968 | | | 3 | $536,968 |
| 1.1.2. ទីប្រឹក្សាជាតិ និងបុគ្គលិកកិច្ចសន្យា | 17 | $407,460 | 74 | $455,280 | 91 | $862,740 |
| 1.1.2.1. អង្គភាពអភិវឌ្ឍគោលនយោបាយ | 6 | $130,860 | 6 | $51,600 | 12 | $182,460 |
| 1.1.2.2. អង្គភាពគ្រប់គ្រងកម្មវិធី | 3 | $79,020 | 6 | $51,300 | 9 | $130,320 |
| 1.1.2.3. អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ | 2 | $52,380 | 47 | $235,200 | 49 | $287,580 |
| 1.1.2.4. អង្គភាពតាមដាន និងវាយតម្លៃ | 6 | $145,200 | 13 | $101,340 | 19 | $246,540 |
| 1.1.2.5. ក្រុមការងារសវនកម្មផ្ទៃក្នុង | 0 | $0 | 2 | $15,840 | 2 | $15,840 |
| 1.2. ក្រសួងមហាផ្ទៃ | 7 | $160,344 | 10 | $59,400 | 17 | $219,744 |
| 1.3. ក្រសួងមុខងារសាធារណៈ | 1 | $27,060 | 2 | $11,280 | 3 | $38,340 |
| 1.4. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 1 | $27,060 | 4 | $14,220 | 5 | $41,280 |
| 1.5. សមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 0 | $0 | 7 | $55,200 | 7 | $55,200 |
| 2. **ថ្នាក់ក្រោមជាតិ** | 97 | $1,771,080 | 790 | $2,548,200 | 887 | $4,319,280 |
| 2.1. រាជធានី ខេត្ត | 97 | $1,771,080 | 180 | $692,400 | 277 | $2,463,480 |
| 2.2. ក្រុង ស្រុក ខណ្ឌ | 0 | $0 | 610 | $1,855,800 | 610 | $1,855,800 |
| 3. **សរុប (1 + 2)** | **126** | **$2,929,972** | **887** | **$3,143,580** | **1013** | **$6,073,552** |

<u>**សម្គាល់**</u> ៖ ថវិកាសរុបនេះរួមបញ្ចូលថ្លៃធានារ៉ាប់រងសុខភាព និងចំណាយពាក់ព័ន្ធផ្សេងទៀត។

## ឧបសម្ព័ន្ធទី៣ ÷ ការទទួលខុសត្រូវក្នុងការអនុវត្ត

### តារាងទី១៥ ៖ សេចក្តីសង្ខេបអំពីការទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ

| លេខកូដ | សមិទ្ធផលនៃផអ៣ទី២ និងលទ្ធផលរំពឹងទុករបស់ ផ.ស.ថ ឆ្នាំ២០១៥ |
|---|---|
| | **គ.ជ.អ.ប** |
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្តូរ |
| ១.១.១. | ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប តាមរយៈកិច្ចដំណើរការដែលបានកែលម្អ និងកែសម្រួល |
| | **លេខាធិការដ្ឋាន គ.ជ.អ.ប** |
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្តូរ |
| ១.២.១. | ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប រួមបញ្ចូលទាំងសមត្ថភាព ការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងផ្អែកលើលទ្ធផល ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំ ផ.ស.ថ និងការរៀបចំគោលនយោបាយ |
| ១.៣.១. | ការរៀបចំ និងអនុវត្តនូវយុទ្ធសាស្ត្រស្តីពីទំនាក់ទំនង និងការចែករំលែកព័ត៌មាននៃផអ៣ដំណាក់កាលទី២ |
| ១.៥.១. | ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រងកិច្ចដំណើរការអភិវឌ្ឍសមត្ថភាពនានា ប្រកបដោយប្រសិទ្ធភាព តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស |
| ១.៥.២. | ការកែសម្រួលរចនាសម្ព័ន្ធ គាំទ្រ និងពង្រឹងសមត្ថភាពពរបស់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២. | រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមនូវច្បាប់លិខិតបទដ្ឋានគតិយុត្តិនានា និងស្តង់ដាររបស់ជាតិ |
| ២.១.១. | ការពិនិត្យ និងអនុម័តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកចំនួន៥០ |
| ២.១.២. | ការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានា ដើម្បីធានាថាតួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ ក៏ដូចជាពង្រឹងមុខងារនានារបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការត្រួតពិនិត្យមើល ការធ្វើសេចក្តីសម្រេចចិត្ត និងអំណាចផ្នែកបញ្ញត្តិ |
| ២.២.១. | ការអនុវត្តសកម្មភាពនានាក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមនៅក្នុងស្រុកចំនួន២២ |
| ២.៤.២. | ការរៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្តល់ព័ត៌មានមានសារប្រយោជន៍សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឆ្លើយតបនឹងតម្រូវការរបស់អ្នកប្រើប្រាស់ និងដើម្បីប្រមូល និងផ្តល់ធាតុចូលដល់ថ្នាក់ជាតិអំពីថ្នាក់ក្រុង ស្រុក ខណ្ឌ |
| ៣. | រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្តល់សេវារបស់ខ្លួន |
| ៣.១.៣. | ការលើកកម្ពស់ភាពឆ្លើយតបចំពោះយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិ |
| ៣.២.១. | ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត |
| ៣.៣.១ | ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់គណៈអភិបាល មន្ត្រី និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត |

| លេខកូដ | សមិទ្ធផលនៃផអ៣ទី២ និងលទ្ធផលរំពឹងទុករបស់ ផ.ស.៥ ឆ្នាំ២០១៥ |
|---|---|
| ៤. | រដ្ឋបាលថ្នាក់ក្រោមជាតិ អាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាជន |
| ៤.១.១. | ការពិនិត្យ ការកែសម្រួល និងការផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងមុខងារឃាជម្រើស និងសេវាសង្គម |
| ៤.១.២. | ការរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រ និងកម្មវិធី ដើម្បីលើកកម្ពស់ការផ្ដួចផ្ដើម និងការសិក្សារៀនសូត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៤.២.១. | ការអនុវត្ត និងការវាយតម្លៃនូវការសាកល្បងអំពីការផ្ទេរមុខងារពីក្រសួងទាំង៦ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងអំឡុងពេលនៃផអ៣ទី១ |
| ៤.២.២. | ការផ្ទេរការិយាល័យជំនាញថ្នាក់ក្រុង ស្រុកចំនួន៣យ៉ាងតិចទៅឱ្យក្រុង ស្រុក |
| ៤.២.៣. | ការធ្វើសេចក្ដីសម្រេចក្នុងការផ្ទេរមុខងារសំខាន់ៗចំនួន៣ពីការិយាល័យជំនាញថ្នាក់ក្រុង ស្រុកទៅឱ្យក្រុង ស្រុក (រួមមាន បឋមសិក្សា មណ្ឌលសុខភាព និងមុខងារមួយផ្សេងទៀត) |
| ៤.៣.១. | ការអនុវត្តនូវការផ្ទេរមុខងារនៃការគ្រប់គ្រងកាកសំណល់រឹងឱ្យក្រុងចំនួន២៦ និងការរៀបចំនូវការសាកល្បងអំពីការផ្ទេរ នូវមុខងារសេវាទីប្រជុំចំនួន២បន្ថែមទៀតទៅឱ្យក្រុងនានា |
| ៤.៥.១. | ការសម្របសម្រួលក្នុងការចុះកិច្ចព្រមព្រៀងនានាស្ដីពីភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្ដល់សេវាសាធារណៈដែលមានទឹកប្រាក់ចំនួន០,៥លានដុល្លារ |
| | **សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ** |
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្ដូរ |
| ១.៥.២. | ការកែសម្រួលរចនាសម្ព័ន្ធ គាំទ្រ និងពង្រឹងសមត្ថភាពរបស់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| ៥. | ធនធានហិរញ្ញវត្ថុត្រូវបានគ្រោងយ៉ាងត្រឹមត្រូវ និងចាត់ចែងបានយ៉ាងល្អ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុក ក្នុងការឆ្លើយតបទៅនឹងការអនុវត្តមុខងារតាមអាណត្តិរបស់ខ្លួន |
| ៥.១.១. | ការវិភាជមូលនិធិពីចំណូលចរន្តនៃថវិការដ្ឋចំនួន០,៥%សម្រាប់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ |
| ៥.២.១. | ការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការសាកល្បងក្នុងការផ្ទេរមុខងារពីក្រសួងចំនួន៦ដែលបានបញ្ចប់កិច្ចដំណើរការពិនិត្យមើលឡើងវិញនូវមុខងារក្នុងដំណាក់កាលផអ៣ទី១ |
| ៥.៣.១. | ការរៀបចំ និងការអនុម័តយុទ្ធសាស្ត្រស្ដីពីវិមជ្ឈការហិរញ្ញវត្ថុដែលកំណត់អំពីចក្ខុវិស័យរយៈពេលមធ្យមមួយ និងកំណត់អំពីចំណុចដៅនានាពាក់ព័ន្ធនឹងចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៥.៣.២. | ការរៀបចំឧបករណ៍នានាស្ដីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ |
| ៥.៤.១. | ការរៀបចំ និងការអនុវត្តសាកល្បងអំពីការប្រមូលចំណូលមូលដ្ឋាន និងចូលរួមបដិភាគដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៦ |
| ៥.៥.១. | ការបង្កើត និងការអនុវត្តនូវយន្តការផ្ដល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦ |
| ៥.៦.១. | ការរៀបចំ និងការអនុម័តលិខិតបទដ្ឋានស្ដីពីការកែសម្រួលកិច្ចដំណើរការវិភាជថវិការាជធានី ខេត្តដើម្បីអនុវត្តក្នុងឆ្នាំ២០១៦ |
| ៥.៧.១. | ការកែសម្រួល និងវិសោធនកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើការវិភាគអំពីភាពមានកម្រិតនៃចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៥.៧.២. | ការពង្រឹង និងការរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវប្រព័ន្ធរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយមាន ទិន្នន័យក្នុងបណ្ដាញអ៊ិនធឺណែតសម្រាប់អ្នកធ្វើសេចក្ដីសម្រេចចិត្តនានា |

| លេខកូដ | សមិទ្ធផលនៃផអ៣ទី២ និងលទ្ធផលរំពឹងទុករបស់ ផ.ស.ថ ឆ្នាំ២០១៥ |
|---|---|
| | **ក្រសួងមហាផ្ទៃ** |
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្តូរ |
| ១.៤.១. | ការលើកកម្ពស់ភាពជាម្ចាស់ និងការចូលរួមក្នុងកិច្ចដំណើរការកំណែទម្រង់របស់ក្រសួងនានាដែលអនុវត្តការផ្ទេរមុខងារ |
| ២. | រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមនូវច្បាប់លិខិតបទដ្ឋានគតិយុត្តិនានា និងស្តង់ដាររបស់ជាតិ |
| ២.២.៣. | ពិនិត្យ សម្រួល និងអនុវត្តសាកល្បងយន្តការដោះស្រាយពាក្យបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ |
| ២.៣.១. | ការរៀបចំ និងសាកល្បងប្រព័ន្ធអធិការកិច្ចនៃការអនុវត្តតាមលិខិតបទដ្ឋាននានាឱ្យបានយ៉ាងហោចណាស់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១០កន្លែង |
| ២.៤.១. | ការរៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំ និងនីតិវិធីប្រតិបត្តិនានាសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| ៣. | រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាពដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្តល់សេវារបស់ខ្លួន |
| ៣.៣.១. | ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពនានាដល់គណៈអភិបាល មន្ត្រី និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត |
| ៣.៤.១. | ការរៀបចំផែនការ និងថវិកាសម្រាប់ការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣.៥.១. | ការសាងសង់អគារសាលាស្រុកចំនួន៣៤ |
| ៤. | រដ្ឋបាលថ្នាក់ក្រោមជាតិ អាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាជន |
| ៤.១.៣ | ការពិនិត្យមើលឡើងវិញ និងការអនុវត្តមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យពីលទ្ធភាពក្នុងការធ្វើសមាហរណកម្មក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល |
| ៤.៤.១. | ការពង្រីកការិយាល័យច្រកចេញចូលតែមួយនៅក្នុងស្រុក ខណ្ឌគោលដៅថ្មីចំនួន៥ និងការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការពង្រីកយន្តការការិយាល័យច្រកចេញចូលតែមួយនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ |
| | **ក្រសួងជំនាញនានា** |
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្តូរ |
| ១.៤.១. | ការលើកកម្ពស់ភាពជាម្ចាស់ និងការចូលរួមក្នុងកិច្ចដំណើរការកំណែទម្រង់របស់ក្រសួងនានាដែលអនុវត្តការផ្ទេរមុខងារ |
| ៤. | រដ្ឋបាលថ្នាក់ក្រោមជាតិ អាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាជន |
| ៤.២.១. | ការអនុវត្ត និងការវាយតម្លៃនូវការសាកល្បងអំពីការផ្ទេរមុខងារពីក្រសួងទាំង៦ដែលបានបញ្ចប់កិច្ចដំណើរការ |



+4

ពិនិត្យមើលឡើងវិញនូវមុខងារក្នុងដំណាក់កាលទី១

| | |
|---|---|
| ៤.៣.១. | ការអនុវត្តនូវការផ្ទេរមុខងារនៃការគ្រប់គ្រងកាកសំណល់រឹងឱ្យក្រុងចំនួន២៦ និងការរៀបចំនូវការសាកល្បងអំពីការផ្ទេរនូវមុខងារសេវាទីប្រជុំចំនួន២បន្ថែមទៀតទៅឱ្យក្រុងនានា |

**ក្រសួងមុខងារសាធារណៈ**

| | |
|---|---|
| ៣. | រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្ដល់សេវារបស់ខ្លួន |
| ៣.១.១. | ការរៀបចំ និងដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគាំទ្រការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលទាំងការវាយតម្លៃបុគ្គលិក |
| ៣.១.២. | ការរៀបចំប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធកុំព្យូទ័រ និងតាមរយៈប្រព័ន្ធអ៊ិនធឺណែត |

**ក្រសួងផែនការ**

| | |
|---|---|
| ៥. | ធនធានហិរញ្ញវត្ថុត្រូវបានគ្រោងយ៉ាងត្រឹមត្រូវ និងចាត់ចែងបានយ៉ាងល្អ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុក ក្នុងការឆ្លើយតបទៅនឹងការអនុវត្តមុខងារតាមអាណត្តិរបស់ខ្លួន |
| ៥.៨.១. | ការរៀបចំ និងការសាកល្បងនូវប្រព័ន្ធកសាលផែនការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំសេចក្ដីណែនាំបច្ចេកទេស និងសម្ភារៈនានា ដើម្បីពង្រីកក្នុងឆ្នាំ២០១៦ |
| ៥.៨.២. | ការពិនិត្យ និងការកែសម្រួលឧបករណ៍នានាស្ដីពីការកសាងផែនការតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីគាំទ្រដំណើរការកសាងផែនការ |

**ក្រសួងកិច្ចការនារី**

| | |
|---|---|
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្ដល់សេវារបស់ខ្លួន |
| ៣.១.៣. | ការលើកកម្ពស់ភាពឆ្លើយតបចំពោះយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិ |

**រដ្ឋបាលថ្នាក់ក្រោមជាតិ**

| | |
|---|---|
| ១. | ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្ដូរ |
| ១.៥.១. | ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រងកិច្ចដំណើរការអភិវឌ្ឍសមត្ថភាពនានា ប្រកបដោយប្រសិទ្ធភាព តាមរយៈមណ្ឌលធនធានមនុស្ស |
| ២. | រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមនូវច្បាប់លិខិតបទដ្ឋានគតិយុត្តិនានា និងស្តង់ដាររបស់ជាតិ |
| ២.២.១. | ការអនុវត្តសកម្មភាពនានាក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមនៅក្នុងស្រុកចំនួន២២ |
| ២.២.២. | ការរៀបចំវេទិកាសាធារណៈ និងសកម្មភាពនានាពាក់ព័ន្ធនឹងការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិលនៅថ្នាក់រាជ ធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| ៣. | រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្ដល់សេវារបស់ខ្លួន |
| ៣.៥.១. | ការសាងសង់អគារសាលាស្រុកចំនួន៣៤ |

| លេខកូដ | សមិទ្ធផលនៃដំណាក់កាលទី២ និងលទ្ធផលរំពឹងទុករបស់ គ.ស.ថ ឆ្នាំ២០១៥ |
|---|---|
| ៤. | រដ្ឋបាលថ្នាក់ក្រោមជាតិ អាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាជន |
| ៤.១.៣. | ការពិនិត្យមើលឡើងវិញ និងការអនុវត្តមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យពីលទ្ធភាពក្នុងការធ្វើសមាហរណកម្មក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល |
| ៤.៥.១. | ការសម្របសម្រួលក្នុងការចុះកិច្ចព្រមព្រៀងនានាស្តីពីភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈដែលមានទឹកប្រាក់ចំនួនប្រមាណ០,៥ លានដុល្លារ |

# ឧបសម្ព័ន្ធទី៤ ÷ ក្របខ័ណ្ឌលទ្ធផល/ ចំណុចដៅ

## តារាងទី១៦ ៖ ក្របខ័ណ្ឌលទ្ធផល និងសូចនាករ

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ | | | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ | |
| **គោលបំណង ៖** លើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងអស់ និងពង្រឹងភាពអង់អាចប្រជាពលរដ្ឋនៅមូលដ្ឋាន (ពីគ្រប់ក្រុមនានាក្នុងសង្គម) តាមរយៈកិច្ចដំណើរការផ្នែកនយោបាយ និងផ្នែកផ្សេងទៀត ដើម្បីជានាសមភាព យុត្តិធម៌ និងកិច្ចការពារសិទ្ធិជាមូលដ្ឋាននានា។ | ១. ភាគរយភាពក្រីក្រដែលជាគោលដៅទីមួយនៃការអភិវឌ្ឍន៍សហវត្សរបស់កម្ពុជា | | 15,9% | 14,9% | 13,9% | ក្រសួងផែនការ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ |
| **គោលដៅ ៖** លើកកម្ពស់សមត្ថភាពការគ្រប់គ្រងអភិបាលកិច្ច ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាសម្រេចបាននូវអាណត្តិនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរបស់ខ្លួន។ | ២. សន្ទស្សន៍អំពីភាពពេញចិត្តនៃការផ្តល់សេវា និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(**) | | 74,19 | 76,00 | 77,81 | អង្កេតអភិបាលកិច្ចដែលចែកតាមភេទ ភាពក្រីក្រ...។ល។ |
| | ៣. សន្ទស្សន៍អភិបាលកិច្ច(**) | | 57,80 | 59,21 | 60,62 | ដូចខាងលើ |
| | ៤. សន្ទស្សន៍សមត្ថភាពក្រុង ស្រុក ខណ្ឌ(**) | | 50,49 | 51,72 | 52,95 | ការវាយតម្លៃសមត្ថភាពដែលចែកតាមក្រុងស្រុក តាមមុខងារ តាមការិយាល័យ តាមភេទ ...។ល។ |
| | ៥. ពិន្ទុអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ(**) | ពុំទាន់មាន | | +5% | +10% | |
| | ៦. សន្ទស្សន៍វិមជ្ឈការ ឬស្វ័យភាព | ពុំទាន់មាន | | +5% | +10% | |
| **សមិទ្ធផលទី១ ៖** ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឱ្យមានការផ្លាស់ប្តូរ | ៧. ចំនួនកិច្ចប្រជុំរបស់ គ.ជ.អ.ប ក្នុង១ឆ្នាំ | គ្មាន | 3 | 3 | 3 | |
| | ៨. ចំនួនថវិកាចំណាយសម្រាប់ជំនួយបច្ចេកទេស | 5,9 | 5,50 | 5,00 | 4,50 | |
| | ៩. ចំនួនប្រជាពលរដ្ឋដែលបានទទួលការផ្សព្វផ្សាយព័ត៌មានដើម្បីបង្កើនការយល់ដឹងជាសាធារណៈ និងការផ្លាស់ប្តូរឥរិយាបថ ក្នុង១ឆ្នាំ | 0 | 100000 | 100000 | 100000 | |
| | ១០.ចំនួនភាគរយនៃចំណុចដៅដែលបានសម្រេចតាមពេលវេលាបាន | 14 | 50 | 60 | 70 | ការអង្កេតស្ថាប័នអនុវត្តកម្មវិធី |

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ ២០១៥ | ២០១៦ | ២០១៧ | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | កំណត់(**) | | | | | |
| | ១១.ចំនួនភាគរយនៃស្ថាប័នអនុវត្តកម្មវិធីដែលពេញចិត្តចំពោះការរៀបចំផែនការសកម្មភាពនិងថវិកា ការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ដែលសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប | | 50 | 60 | 70 | |
| | ១២.ចំនួនក្រសួងដែលបានរៀបចំផ្សព្វផ្សាយព័ត៌មានជាសាធារណៈក្នុងការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ | 0 | 1 | 2 | 5 | |
| **សមិទ្ធផលទី២ ៖** រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមក្របខណ្ឌច្បាប់ និងស្តង់ដារនានារបស់ជាតិ | ១៣.ក្របខណ្ឌគតិយុត្តត្រូវបានពង្រឹងដើម្បីធានាឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ពិសេសសិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធាន និងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន | | មាន | មាន | មាន | |
| | ១៤.រដ្ឋបាលក្រុង ស្រុកនីមួយៗបានអនុម័ត និងដាក់ឱ្យអនុវត្តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន(*) | 0 | 50 | 185 | 185 | |
| | ១៥.ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាក្នុង១ឆ្នាំ ដែលបានរៀបចំឡើងដើម្បីពិភាក្សាអំពីព័ត៌មានដែលទទួលបានពីការងារត្រួតពិនិត្យ និងវាយតម្លៃ ឬទទួលបានពីប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងតាមបច្ចេកវិទ្យាព័ត៌មាន | | 100 | 300 | 591 | |
| | ១៦.ចំនួនភាគរយសមាជិកក្រុមប្រឹក្សាក្រុង ស្រុកដែលយល់ថាគណៈអភិបាលកាន់តែមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាច្រើនជាងពីមុន | | 20 | 70 | 120 | អង្កេតអភិបាលកិច្ចដែលចែកតាមភេទ ភាពក្រីក្រ...។ល។ |
| | ១៧.រដ្ឋបាលឃុំទាំងអស់ក្នុងស្រុកចំនួន១២០បានបិទផ្សាយព័ត៌មានដល់សាធារណជន គាំទ្រដល់ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃរបស់ប្រជាពលរដ្ឋ និងរៀបចំផែនការសកម្មភាពរួមគ្នាស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា(*) | | | | | |



ន

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ | | | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ | |
| | ១៨.ដំណាក់កាលទី២នៃផែនការអនុវត្តគណនេយ្យភាពសង្គមនឹងត្រូវរៀបចំដោយបញ្ចូលនូវប្រភេទសេវាផ្សេងៗទៀត និងអនុវត្តនៅថ្នាក់រដ្ឋបាលផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | គ្មាន | គ្មាន | គ្មាន | មាន | |
| | ១៩.ចំនួនភាគរយនៃសំណើ សំណូមពរ និងពាក្យបណ្តឹងដែលបានទទួលដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានឆ្លើយតបទៅនឹងសំណើ ឬសំណូមពរ និងសម្រុះសម្រួលដោះស្រាយ | | 20 | 50 | 70 | |
| | ២០.ចំនួនប្រជាពលរដ្ឋដែលបានចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 50.000 | 70.000 | 10.000 | |
| | ២១. ចំនួនតំណាងអង្គការសង្គមស៊ីវិលដែលបានចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 500 | 700 | 900 | |
| | ២២.ចំនួនថវិការួមចំណែករបស់រដ្ឋបាលឃុំនៃស្រុកចំនួន១២០ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងដោយប្រជាពលរដ្ឋតាមរយៈសកម្មភាពគណនេយ្យភាពសង្គម (គិតជាដុល្លារ) | | 100000 | 250000 | 500000 | |
| | ២៣.ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងឃុំដែលអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គមបានល្អប្រសើរឡើង(ដូចមានក្នុងសូចនាករកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងប័ណ្ណដាក់ពិន្ទុសហគមន៍) | គ្មាន | គ្មាន | គ្មាន | មាន | |
| | ២៤.ចំនួនភាគរយរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុកខណ្ឌដែលត្រូវបានធ្វើអធិការកិច្ចលើការអនុវត្តតាមក្របខណ្ឌច្បាប់ និងដែលទទួលបាននូវការវាយតម្លៃអំពីការពេញចិត្តលើការអនុវត្តតាមក្របខណ្ឌច្បាប់(*) | 0 | 20 | 30 | 40 | |
| **សមិទ្ធផលទី៣ ៖** រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនានាក្នុងការផ្តល់ | ២៥.ចំនួនភាគរយនៃបុគ្គលិករដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជ្រើសរើស តែងតាំង លើកសរសើរ និងដាក់វិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សា | 0 | 100 | 100 | 100 | ការវាយតម្លៃសមត្ថភាពក្រុង ស្រុក ខណ្ឌ |
| | ២៦.ចំនួនភាគរយនៃមន្ត្រីថ្នាក់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | 0 | 50 | 75 | 95 | ការវាយតម្លៃសមត្ថភាពក្រុង ស្រុក |

| ការពិពណ៌នា | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | |
| សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន | មានការវាយតម្លៃគុណផល ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន | | | | | ខណ្ឌ |
| | ២៧.ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលរាជធានី ខេត្ត ជាស្ត្រី(*) | 0,3 | 8 | 12 | 16 | សម្រេចឱ្យបាន២០%នៅឆ្នាំ ២០១៨ |
| | ២៨.ចំនួនភាគរយនៃនាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត ជាស្ត្រី(*) | 0,3 | 8 | 12 | 16 | ដូចខាងលើ |
| | ២៩.ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលក្រុងស្រុកខណ្ឌ ជាស្ត្រី(*) | 18 | 16 | 19 | 22 | សម្រេចឱ្យបាន២៥%នៅឆ្នាំ ២០១៨ |
| | ៣០.ចំនួនភាគរយនៃប្រធាន អនុប្រធានការិយាល័យ អង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ជាស្ត្រី(*) | 17 | 21 | 22 | 23 | ដូចខាងលើ |
| | ៣១.ចំនួនភាគរយនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តដែលបានផ្តល់ការគាំទ្រផ្នែកអភិវឌ្ឍសមត្ថភាពទាំង៥ប្រភេទ | 0 | 100 | 100 | 100 | |
| | ៣២.ចំនួនភាគរយនៃអភិបាល និងប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុកខណ្ឌដែលបានទទួលវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចប្រចាំឆ្នាំអំពីការបញ្ជ្រាបយេនឌ័រ | 0 | 95 | 95 | 95 | |
| | ៣៣.ចំនួនភាគរយនៃនៃសមាជិកក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលយល់ឃើញថា វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំគ្រប់គ្រាន់សម្រាប់អនុវត្តមុខងាររបស់ខ្លួន | គ្មាន | 20 | 50 | 80 | ការអង្កេតនានា |
| | ៣៤.ចំនួនភាគរយនៃកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលផ្អែកតាមតម្រូវការ | គ្មាន | 30 | 40 | 50 | |
| | ៣៥.ចំនួនជាមធ្យមនៃដីកាដែលបានដាក់ចេញដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ | | 0,5 | 0,7 | 1 | |
| | ៣៦.ចំនួនភាគរយនៃសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែលបានកើនឡើង | | 10 | 25 | 50 | |

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ ២០១៥ | ២០១៦ | ២០១៧ | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| **សមិទ្ធផលទី៤ ៖** រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងការអភិវឌ្ឍមូលដ្ឋាន ហើយការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានសំខាន់ៗនានា នឹងត្រូវបានអនុវត្តដោយថ្នាក់រដ្ឋបាលដែលមានលក្ខណៈសមស្រប និងនៅកៀកជិតបំផុតនឹងប្រជាពលរដ្ឋ។ | ៣៧.ចំនួនភាគរយនៃថវិកាជាតិត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាលទ្ធផលនៃការផ្ទេរមុខងារ(*) | | 0,5 | 1 | 3,6 | |
| | ៣៨.ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុកនៃក្រសួង ស្ថាប័នក្នុងវិស័យសំខាន់ៗចំនួន០២( ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ) | | 0 | 2 | 5 | |
| | ៣៩.ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុករបស់ក្រសួង ស្ថាប័នក្នុងវិស័យផ្សេងៗទៀតយ៉ាងតិចចំនួន០៣[7] | | 5 | 50 | 185 | |
| | ៤០.ចំនួនរដ្ឋបាលក្រុង ស្រុកយ៉ាងដែលបានទទួលនូវការផ្ទេរមុខងារនិងធនធានពាក់ព័ន្ធនឹងសេវាទីប្រជុំជន[8]ពីរដ្ឋបាលខេត្ត | | 0 | 3 | 10 | |
| | ៤១.ការវាយតម្លៃដោយឯករាជ្យមួយនឹងបង្ហាញឱ្យឃើញថា ការផ្តល់សេវាដែលកាន់តែប្រសើរ នៅពេលដែលមុខងារត្រូវបានផ្ទេរមែជ្ឈការពីថ្នាក់ជាតិមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលខេត្តទៅរដ្ឋបាលក្រុង | | | | មាន | |
| | ៤២.ចំនួនភាគរយនៃការកើនឡើងនៃការចំណាយពីមូលនិធិឃុំ សង្កាត់ទៅលើសេវាសង្គម (កើនឡើងចំនួន០៣ដង) | | 50 | 150 | 300 | |
| | ៤៣.ចំនួនសេវាថ្មី( មិនធ្លាប់អនុវត្តពីមុន )ដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុងស្រុកបានផ្តួចផ្តើមគំនិត និងសាកល្បងក្នុងការផ្តល់សេវាដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក | | 2 | 10 | 25 | |
| | ៤៤.ចំនួនករណីនៃបទពិសោធន៍ល្អៗអំពីភាពជោគជ័យនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានប្រមូលចងក្រងជាឯកសារ | | 2 | 10 | 50 | |

[7] ការិយាល័យមានបុគ្គលិកពី១-៣នាក់។

[8] រួមបញ្ចូលការប្រមូលសំរាម ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរកាកសំណល់ ការគ្រប់គ្រង និងការអភិវឌ្ឍទីផ្សារ និងការអភិវឌ្ឍតំបន់បៃតងសាធារណៈជាដើម និងយ៉ាងហោចណាស់មានសេវា២ផ្សេងទៀត។

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ | | | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ | |
| | ៤៥.ចំនួនថវិកាដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុវត្តនូវការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជន សម្រាប់កម្រិតថ្នាក់រដ្ឋបាលនីមួយៗ(គិតជាលានដុល្លារ) | | 0,5 | 3 | 9 | រំពឹងថា នឹងមានចំនួនប្រមាណ ១០%នៃមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុក |
| | ៤៦.ចំនួនភាគរយនៃប្រជាពលរដ្ឋដែលពេញចិត្តចំពោះការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដែលជាគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 50 | 50 | 50 | |
| | ៤៧.ចំនួនការិយាល័យច្រកចេញចូលតែមួយដែលបានពង្រីកបន្ថែមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់ខេត្ត | | 6 | 12 | 18 | |
| | ៤៨.យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមលក្ខណៈច្រកចេញចូលតែមួយ (ក្រៅពីក្រុង ស្រុក ខណ្ឌ ខេត្តដែលមានការិយាល័យច្រកចេញចូលតែមួយ) ត្រូវបានរៀបចំឡើងនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅទូទាំងប្រទេស | | | | | |
| | ៤៩.ចំនួនភាគរយនៃការកើនឡើងនូវសេវារដ្ឋបាលផ្សេងៗដែលផ្តល់តាមរយៈការិយាល័យច្រកចេញចូលតែមួយ | | 4 | 8 | 10 | |
| | ៥០.ចំនួនភាគរយកើនឡើងនៃប្រជាពលរដ្ឋដែលបានមកទទួលសេវារដ្ឋបាលតាម រយៈច្រកចេញចូលតែមួយ | | 5 | 10 | 15 | |
| **សមិទ្ធផលទី៥ ៖** ធនធានហិរញ្ញវត្ថុត្រូវបានគ្រោងរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តនូវអាណត្តិរបស់ខ្លួន។ | ៥១.ចំនួនភាគរយនៃធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តថវិការដ្ឋ | | 0,5 | 0,5 | 0,5 | |
| | ៥២.ចំនួនភាគរយនៃចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ធៀបនឹងចំណូលសរុបរបស់ខ្លួន | | 0 | 2,5 | 10 | |
| | ៥៣.ចំនួនធនធានដែលសហគមន៍មូលដ្ឋានបានចូលរួមសម្រាប់គម្រោងឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក (គិតជាលានដុល្លារ) | | 0,2 | 0,5 | 2 | |
| | ៥៤.យន្តការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌ ដើម្បីជានាដល់ការអនុវត្ត | | គ្មាន | គ្មាន | គ្មាន | |

| ការពិពណ៌នា | សូចនាករ | ដើមគ្រា ២០១៤ | ចំណុចដៅ | | | ប្រភពទិន្នន័យ, កំណត់សម្គាល់ និងការបែងចែក |
|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ | |
| | មុខងារដែលបានផ្ទេរ | | | | | |
| | ៥៥.ចំនួនធនធានដែលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគ (គិតជាលានដុល្លារ) | | 0 | 3 | 3 | |
| | ៥៦.ចំនួនភាគរយនៃការកាត់បន្ថយនូវភាពយឺតយ៉ាវនៃការផ្ទេរធនធានពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោម | | 10 | 25 | 50 | |
| | ៥៧.ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានប្រើប្រាស់ប្រព័ន្ធកសាងផែនការថ្មី | 0 | 100 | 100 | 100 | |